សមាសភាគកសាងផែនការបន្សាំ និងភាពធន់នៅតំបន់ឆ្នេរ

# ការវាយតម្លៃយុទ្ធសាស្ត្រដោះទ័លក្នុងតំបន់ឆ្នេរកម្ពុជា



Cambodia Climate Change Alliance (CCCA)

Implemented by: Supported by:

Ministry of Environment · European Union · UNDP Empowered lives Resilient nations · Danida · SWEDEN

UNEP-DHI CENTRE
for Water and Environment

UNEP · DHI

២០១២

# មាតិកា


**បុព្វកថា** ..... iii

**សេចក្តីថ្លែងអំណរគុណ** ..... iv

**ពាក្យបំព្រួញ និងអក្សរកាត់** ..... v

**សេចក្តីសង្ខេបប្រតិបត្តិ** ..... vi

**សេចក្តីផ្តើម** ..... ១

**វិធីសាស្ត្រ** ..... ២

សហគមន៍គោលដៅ ..... ២

ការគូសបញ្ជាក់និយមន័យនៃពាក្យ ..... ៤

ការប្រមូលទិន្នន័យ ..... ៥

**តំបន់ឆ្នេរ** ..... ៨

**ការប្រែប្រួលអាកាសធាតុនៅកម្ពុជា** ..... ១០

តំបន់ឆ្នេរ ..... ១១

ក្របខ័ណ្ឌស្ថាប័ន ..... ១១

ក្របខ័ណ្ឌគោលនយោបាយ ..... ១៣

ការយល់ឃើញរបស់កម្ពុជាអំពីការប្រែប្រួលអាកាសធាតុ ..... ១៤

ព័ត៌មានអំពីការប្រែប្រួលអាកាសធាតុ ..... ១៥

យុទ្ធសាស្ត្រដោះទ័លនៅខេត្តកោះកុង និងខេត្តព្រះសីហនុ ..... ១៦

ខេត្តកោះកុង - ឃុំពាមក្រសោប និងទួលគរគី ..... ១៦

ខេត្តព្រះសីហនុ - ឃុំព្រៃនប់ និងអូរឧកញ៉ាហេង ..... ១៨

**ការវាយតម្លៃ** ..... ៤៣

យុទ្ធសាស្ត្រដោះទ័ល ..... ៤៣

ព័ត៌មាន ..... ៤៧

ការយល់ឃើញ ..... ៤៨

**ឯកសារយោង** ..... ៥០

## បុព្វកថា

ខ្ញុំមានក្តីសោមនស្សរីករាយ បង្ហាញរបាយការណ៍ ស្តីពីយុទ្ធសាស្ត្រដោះទ័លក្នុងតំបន់ឆ្នេរកម្ពុជា ដែលជាសមិទ្ធផលនៃកិច្ចសហប្រតិបត្តិការប្រកបដោយផ្លែផ្កាវវាងស្ថាប័នរដ្ឋគ្រប់កំរិត ដូចជា ថ្នាក់ខេត្ត ស្រុក និងអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗ គម្រោង និងកម្មវិធី ដែលទាក់ទងជាមួយការអភិវឌ្ឍន៍តំបន់ឆ្នេរ និង ការប្រែប្រួលអាកាសធាតុ ។ របាយការណ៍នេះ នឹងរៀបរាប់សង្ខេបពីសកម្មភាពអនុវត្តគម្រោងនិងវិធីសាស្ត្រ ដើម្បីបញ្ជ្រាបសកម្មភាព និងវិធីសាស្ត្រការបន្សុំាការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ និងរៀបចំរចនាសម្ព័ន្ធ និងកសាងសមត្ថភាពដើម្បីអនុវត្តន៍វិធានការបន្សុំាការប្រែប្រួលអាកាសធាតុ ។

របាយការណ៍នេះ ផ្តោតលើយុទ្ធសាស្ត្រដោះទ័លនៅតំបន់គោលដៅអនុវត្តគម្រោងក្នុងឃុំចំនួន០៦ ក្នុងស្រុកព្រៃនប់ ខេត្តព្រះសីហនុ និងឃុំចំនួន ០២ នៅស្រុក មណ្ឌលសីមា ខេត្តកោះកុង ។ របាយការណ៍នេះ រៀបចំឡើងដោយយោងតាមរបាយការណ៍ ដែលទទួលបានតាមរយៈការធ្វើសម្ភាសន៍តាមឃុំដែលបានជ្រើសរើស និងបង្ហាញទស្សនៈទូលំទូលាយអំពីយុទ្ធសាស្ត្រដោះទ័លក្នុងតំបន់ឆ្នេរកម្ពុជា នាពេលបច្ចុប្បន្ន ។

ភាពសម្បូរណ៍បែបនៃធនធានធម្មជាតិ និងបរិស្ថាននៅតំបន់ឆ្នេរសមុទ្រកម្ពុជា បានរងផលប៉ះពាល់រយៈពេលជាច្រើនឆ្នាំពីសកម្មភាពអភិវឌ្ឍន៍ ។ លើសពីនេះទៀត ការប្រែប្រួលអាកាសធាតុក៏បង្កឲ្យមានផលប៉ះពាល់ដល់ជីវភាពរស់នៅតំបន់ឆ្នេរសមុទ្រ ជាពិសេសតំបន់ទំនាបដូចជា ទឹកជំនន់ ការជ្រាបចូលទឹកសមុទ្រ និងការហូរច្រោះឆ្នេរ ។ សេចក្តីត្រូវការលើការកែលម្អលើការគ្រប់គ្រង គឺដើម្បីធានាដល់ការកែលម្អដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមនៅក្នុងតំបន់ដោយមិនបង្កឲ្យមានផលប៉ះពាល់ដល់ធនធានធម្មជាតិ និងបរិស្ថាន ជាពិសេស វាជាការបន្ទាន់ទាក់ទងនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុចំពោះជីវភាពរស់នៅនាពេលបច្ចុប្បន្ន ដែលសហគមន៍តំបន់ឆ្នេរកំពុងតែបង្កើតការបន្សុំា និងបង្កើនភាពធន់ដល់សហគមន៍ ។ នៅពេលជាមួយគ្នា វាអាចប្រើប្រាស់សម្រាប់អនុវត្ត និងពង្រីកទៅផ្នែក ដ៏ទៃទៀតនៅតំបន់ឆ្នេរ និងខេត្តដ៏ទៃទៀត ។

របាយការណ៍នេះ មានសារៈសំខាន់ចំពោះអាជ្ញាធរឃុំ ស្រុក និងខេត្ត ព្រមទាំងមន្ទីរជំនាញនៅក្នុងខេត្តនៅតំបន់ឆ្នេរសមុទ្រកម្ពុជា ដើម្បីដោះស្រាយបញ្ហាស្មុគស្មាញទាក់ទងនឹងការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម និងការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិប្រកបដោយចីរភាព ។ របាយការណ៍នេះ នឹងបង្ហាញពីសារប្រយោជន៍ដល់អ្នកអានមានដូចជា អ្នករៀបចំគោលនយោបាយនៅថ្នាក់ជាតិ អ្នកធ្វើផែនការ និងស្ថាប័នរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល គម្រោងផ្សេងៗ និងផ្នែកឯកជន ព្រមទាំងជាមូលដ្ឋានដល់ការអប់រំ ការស្រាវជ្រាវផងដែរ ។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា អ្នកអានទាំងអស់នឹងស្វែងយល់ពីរបាយការណ៍នេះ ដែលជាធនធានដ៏មានតម្លៃសម្រាប់ការងារការប្រែព្រួលអាកាសធាតុនៅកម្ពុជា ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៤

**អគ្គនាយកបច្ចេកទេស**

**និងជាប្រធានគណៈកម្មាធិការដឹកនាំគម្រោង**

**វេជ្ជ. ឡុញ ហ៊ាល**

# សេចក្តីថ្លែងអំណរគុណ

របាយការណ៍ ស្តីពីការវាយតម្លៃភាពងាយរងគ្រោះ និងហានិភ័យពីការប្រែប្រួលអាកាសធាតុ នៃសហគមន៍ក្នុងតំបន់ឆ្នេរកម្ពុជានេះ ត្រូវបានរៀបរៀងឡើងនៅក្រោមសមាសភាគកសាងផែនការបន្សាំ និង ភាពធន់ក្នុងតំបន់ឆ្នេរសមុទ្រកម្ពុជា ក្រោមកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា។ របកគំហើញក្នុង របាយការណ៍នេះ បានផ្អែកលើមេរៀននានា ដែលទទួលបានពីសកម្មភាពដែលអនុវត្តនៅក្រោមសមាសភាគនេះ។

តាងនាមឲ្យក្រុមការងារតំបន់ឆ្នេរសមុទ្រកម្ពុជា ខ្ញុំបាទសូមសំដែងការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាអនុប្រធានគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ដែលតែងតែជម្រុញ ណែនាំ និងគាំទ្រយ៉ាងខ្លាំងក្លាដល់កិច្ចប្រឹងប្រែងរបស់ក្រុមការងារ ដើម្បីសម្រេចបានរបាយការណ៍នេះ។ ខ្ញុំក៏សូមថ្លែងអំណរគុណដល់ឯកឧត្តម លោក លោកស្រី ជាសមាជិកគណៈកម្មាធិការដឹកនាំគម្រោង ក្រុមការងារជនបង្គោលថ្នាក់ជាតិ ក្រុមការងារបច្ចេកទេសថ្នាក់ខេត្ត ទីប្រឹក្សាជាតិ និងអន្តរជាតិ រួមទាំងភាគីពាក់ព័ន្ធទាំងអស់ ដែលបានរួមចំណែកផ្តល់មតិល្អៗ ចំពោះការចងក្រងរបាយការណ៍នេះ ។

ជាចុងក្រោយ សូមថ្លែងអំណរគុណដល់កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា ចំពោះការឧបត្ថម្ភគាំទ្រដល់សមាសភាគកសាងផែនការ និងភាពធន់ដល់ប្រែប្រួលអាកាសធាតុនៅតំបន់ឆ្នេរសមុទ្រកម្ពុជា តាមរយៈភ្នាក់ងារអនុវត្ត DHI សហការល្អជាមួយក្រសួងបរិស្ថាន។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៤

**គណៈកម្មាធិការដឹកនាំគម្រោង**

**អនុប្រធានអចិន្ត្រៃយ៍**

**បណ្ឌិត វ៉ាន់ មុនីនាថ**

# ពាក្យបំព្រួញ និងអក្សរកាត់

| | | |
|---|---|---|
| ADB | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| AFD | Agence Française de Développement | ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ |
| CARP | Coastal Adaptation and Resilience Planning Component | សមាសភាគផែនការបន្សុាំ និងភាពធន់នៅតំបន់ឆ្នេរសមុទ្រ |
| CCCA | Cambodia Climate Change Alliance | សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា |
| CCD | Climate Change Department | នាយកដ្ឋានប្រែប្រួលអាកាសធាតុ |
| CDP | Commune Development Plan | ផែនការអភិវឌ្ឍន៍ឃុំ |
| IUCN | International Union of Conservation of Nature | សហភាពអន្តរជាតិដើម្បីអភិរក្សធម្មជាតិ |
| KAP-study | Understanding Public Perception of Climate Change in Cambodia study | ការសិក្សាស្វែងយល់អំពីទស្សនៈរបស់សាធារណៈជនអំពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា |
| MFI | Microfinance | មីក្រូហិរញ្ញប្បទាន |
| MoE | Ministry of Environment | ក្រសួងបរិស្ថាន |
| MoWRAM | Ministry of Water Resources and Meterology | ក្រសួងធនធានទឹក និងឧតុនិយម |
| NAPA | National Adaptation Program of Actions to Climate Change | កម្មវិធីសកម្មភាពជាតិបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ |
| NCCC | National Climate Change Committee | គណៈកម្មការធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ |
| RGC | Royal Government of Cambodia | រាជរដ្ឋាភិបាលកម្ពុជា |
| SLR | Sea Level Rise | កំណើនកំពស់ទឹកសមុទ្រ |

# សេចក្តីសង្ខេបប្រតិបត្តិ

របាយការណ៍នេះ គឺជាការវាយតម្លៃអំពីយុទ្ធសាស្ត្រដោះទ័លបច្ចុប្បន្ននៃសហគមន៍គោលដៅនៅក្នុងសមាសភាគកសាងផែនការបន្សាំនិងភាពធន់នៅតំបន់ឆ្នេរ (CARP) ដែលទាក់ទងនឹងទឹកជំនន់គ្រោះរាំងស្ងួត និងព្រឹត្តិការណ៍មិនប្រក្រតីដទៃទៀត។ ការសិក្សានេះត្រូវបានអនុវត្តនៅក្នុងសហគមន៍ចំនួនពីរនៃស្រុកព្រៃនប់ក្នុងខេត្តព្រះសីហនុ និងស្រុកមណ្ឌលសីមាក្នុងខេត្តកោះកុង។ របាយការណ៍នេះបានផ្អែកលើឯកសារដែលមានស្រាប់និងការប្រមូលទិន្នន័យពិស្តារនៅក្នុងសហគមន៍គោលដៅចំនួនពីរដែលធ្វើឡើងតាមរយៈការសិក្សានេះ។

នៅក្នុងឯកសារដែលមានស្រាប់មានការឯកភាពជាទូទៅថា តំបន់ឆ្នេរកម្ពុជានឹងរងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុខ្លាំងជាងបច្ចុប្បន្ន។ មុខសញ្ញាគ្រោះថ្នាក់ធាតុអាកាសដូចជាគ្រោះរាំងស្ងួតទឹកជំនន់ការជ្រាបចូលនៃទឹកប្រៃ សត្វចង្រៃបំផ្លាញដំណាំ និងគ្រោះមហន្តរាយដទៃទៀតនឹងនៅតែកើតមានប៉ុន្តែមានការព្យាករណ៍ថាទៅអនាគតបាតុភូតទាំងនេះនឹងកើតមានកាន់តែញឹកញាប់និងខ្លាំងក្លាជាងមុន។

សហគមន៍គោលដៅទាំងពីរនៅខេត្តកោះកុង និងព្រះសីហនុ បានឆ្លងកាត់ផលប៉ះពាល់ទាំងនេះនៃការប្រែប្រួលអាកាសធាតុដូច ដែលបានអធិប្បាយនៅក្នុងឯកសារដែលមានស្រាប់។ បាតុភូតទាំងនេះមានឥទ្ធិពលអវិជ្ជមានមកលើអ្នកភូមិនៅក្នុងសហគមន៍គោលដៅទាំងខាងសេដ្ឋកិច្ចមុខរបរ និងសុខភាព។

សហគមន៍គោលដៅទាំងពីរមានយុទ្ធសាស្ត្រដោះទ័លសម្រាប់អនុវត្តដែលគាំទ្រពួកគេក្នុងការជំនះផលវិបាកនៃការប៉ះពាល់បណ្តាលពីប្រែប្រួលអាកាសធាតុ។ ទោះជាយ៉ាងណាក៏ដោយ យុទ្ធសាស្ត្រដោះទ័លទាំងនេះបានផ្អែកលើសមត្ថភាពបច្ចេកទេសកម្រិតទាប និងការគាំទ្រខាងស្ថាប័នក្នុងកម្រិតកំណត់ជាលទ្ធផលគ្មានយុទ្ធសាស្ត្រដោះទ័លណាមួយទំនងជាមានប្រសិទ្ធភាពពេញលេញស្របនឹងសក្តានុពលរបស់ខ្លួនឡើយ។

ទិន្នន័យនៅក្នុងរបាយការណ៍នេះ មានភាពស្របគ្នាជាមួយឯកសារដែលមានស្រាប់ក្នុងការកំណត់អត្តសញ្ញាណភាពខ្វះចន្លោះរវាងការយល់ឃើញរបស់អ្នកភូមិ និងនិយមន័យបច្ចេកទេសអំពីការប្រែប្រួលអាកាសធាតុ។

ការវាយតម្លៃនៅក្នុងរបាយការណ៍នេះ កំណត់ឃើញភាពខ្វះចន្លោះនៃប្រព័ន្ធចាត់ចែងព័ត៌មានដែលផ្តល់ព័ត៌មានអំពីមុខសញ្ញាគ្រោះថ្នាក់ធាតុអាកាសទៅឲ្យអ្នកភូមិ និងមកពីអ្នកភូមិនៅក្នុងសហគមន៍គោលដៅដែលជាបញ្ហាគន្លឹះមួយក្នុងការធានាប្រសិទ្ធភាពនៃយុទ្ធសាស្ត្រដោះទ័ល ដែលមានស្រាប់។ ជាផ្នែកមួយនៃការវាយតម្លៃនេះនៅក្នុងរបាយការណ៍នេះមានការផ្តល់អនុសាសន៍ ដែលទាក់ទងនឹងវិធី ដែលប្រព័ន្ធព័ត៌មានមួយគួរតែរៀបចំឡើងនិងប្រភេទព័ត៌មានដែលគួរតែជាមូលដ្ឋានសម្រាប់ប្រើប្រាស់។

# សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជាបានកំណត់យកតំបន់ឆ្នេរជាគោលដៅសម្រាប់ការងាររបស់កម្ពុជា ក្នុងការបន្សាំទៅនឹងផលប៉ះពាល់នៃការប្រែប្រួលដែលមានបច្ចុប្បន្ន និងទៅអនាគត។ តំបន់ឆ្នេរកម្ពុជាកំពុងរងការគំរាមកំហែងពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុដូចជា ខ្យល់ព្យុះ ព្យុះសមុទ្រ កំណើនកំពស់ទឹកសមុទ្រ និងការជ្រាបចូលនៃទឹកប្រៃ។

របាយការណ៍នេះបង្ហាញពីការវាយតម្លៃភាពយុទ្ធសាស្រ្តដោះទ័លបច្ចុប្បន្នក្នុងឃុំគោលដៅនៃ CARP ដែលទាក់ទងនឹងទឹកជំនន់ គ្រោះរាំងស្ងួត និងព្រឹត្តិការណ៍ធាតុអាកាសមិនប្រក្រតី។ គោលបំណងនៃការវាយតម្លៃនេះត្រូវបានបង្កើតឡើងជាគោលបំណង២.២នៃCARP។ លើសពីនេះ ការវាយតម្លៃខ្លីមួយអំពីសមត្ថភាពស្ថាប័ននៅក្នុងក្របខ័ណ្ឌ CARPក៏បានធ្វើឡើងផងដែរ។

សមាសភាគ CARP មានគោលដៅកសាងសមត្ថភាពបន្សាំនៃតំបន់ឆ្នេរនៅកម្រិតជាតិនិងកម្រិតខេត្ត និងកសាងផែនការបន្សាំសម្រាប់តំបន់ឆ្នេរតាមរយៈលំហាត់កសាងសមត្ថភាពតាមបែបធ្វើផងរៀនផង ដែលទាក់ទងជាមួយអ្នកពាក់ព័ន្ធទាំងអស់។ បន្ទាប់មកផែនការបន្សាំនឹងត្រូវបម្លែងទៅជាវិធានការបន្សាំសម្រាប់ការអនុវត្តបង្ហាញជាក់ស្តែងដែលត្រូវអនុវត្តនៅក្នុងសហគមន៍ងាយរងគ្រោះសម្រាប់កសិកម្ម និងតំបន់ព្រៃកោងកាងមួយចំនួន។[1] ដើម្បីសម្រេចគោលដៅនេះ ជំហានដំបូងមួយគឺត្រូវផ្តួចផ្តើមការវាយតម្លៃនេះ។ របាយការណ៍នេះនឹងបង្កើតលទ្ធផលជាទិន្នន័យគោលសម្រាប់ CARP លើប្រធានបទចំនួនបីដូចតទៅ៖

- ការយល់ឃើញបច្ចុប្បន្នរបស់ប្រជាជនដែលរស់នៅក្នុងតំបន់ឆ្នេរអំពីការប្រែប្រួលអាកាសធាតុ
- ព័ត៌មានដែលបានផ្តល់ឲ្យប្រជាជននៅក្នុងតំបន់ឆ្នេរអំពីការប្រែប្រួលអាកាសធាតុនិងមុខសញ្ញាគ្រោះថ្នាក់ធាតុអាកាស
- យុទ្ធសាស្រ្តដោះទ័លដែលមានស្រាប់ដែលប្រជាជននៅក្នុងតំបន់ឆ្នេរបានអនុវត្តនិងឥទ្ធិពលនៃយុទ្ធសាស្រ្តទាំងនោះនៅក្នុងតំបន់ឆ្នេរ។

ប្រធានបទនីមួយៗទាំងនេះនឹងមានចែងពិស្តារនៅក្នុងផ្នែកបន្ទាប់នេះ។

ការកសាងសមត្ថភាពដើម្បីបង្កើនភាពធន់នឹងការប្រែប្រួលអាកាសធាតុ តាមរយៈការកសាងផែនការបន្សាំអាស្រ័យដោយការរួមបញ្ចូលចំណេះដឹង ព័ត៌មាន និងឧបករណ៍នានា ទៅក្នុងបរិបទជីវិតបច្ចុប្បន្នរបស់ប្រជាជនដែលរស់នៅក្នុងតំបន់ឆ្នេរ។

1 Cambodia Climate Change Alliance, "Coastal Adaptation and Resilience Planning Component", 2010, p. 34

# វិធីសាស្ត្រ

ការវាយតម្លៃនេះបានផ្អែកមួយចំណែកធំលើឯកសារដែលមានស្រាប់។ ទោះជាយ៉ាងណាក៏ដោយការស្រាវជ្រាវនៅតាមទីតាំងភូមិសាស្ត្រក៏បានធ្វើឡើងផងដែរ ដើម្បីបង្ហាញទិន្នន័យជាក់លាក់ តាមទីតាំងអំពីអថេរជ្រើសរើសមួយចំនួនផងដែរ។

ចាប់តាំងពីឆ្នាំ២០០៩ មក ការសិក្សាមួយចំនួនអំពីការប្រែប្រួលអាកាសធាតុបានធ្វើឡើងនៅកម្ពុជា។ ការស្រាវជ្រាវនេះ ត្រូវបានប្រើប្រាស់ទូលំទូលាយដោយរួមផ្សំជាមួយទិន្នន័យដែលប្រមូលបានពីទីតាំងជាក់លាក់នានាផងដែរ។

## សហគមន៍គោលដៅ

ការសិក្សានេះបានធ្វើឡើងក្នុងសហគមន៍គោលដៅចំនួនពីរដែលបានជ្រើសរើសទុកជាមុន។ ទីតាំងទាំងពីរនោះគឺៈ

- **ស្រុកព្រៃនប់ក្នុងខេត្តព្រះសីហនុ**
- **ស្រុកមណ្ឌលសីមាក្នុងខេត្តកោះកុង**

ដូចមានចែងនៅក្នុង CARP "ស្រុកព្រៃនប់និងមណ្ឌលសីមាត្រូវបានជ្រើសរើសជាស្រុកសាកល្បងនៅក្នុងពេលពិគ្រោះយោបល់រវាងក្រសួងបរិស្ថាន(MoE), អាជ្ញាធរខេត្ត និងស្រុកនៅតំបន់ឆ្នេរ នាយកដ្ឋានប្រែប្រួលអាកាសធាតុនិងទីប្រឹក្សាជាតិនិងអន្តរជាតិ។ ការជ្រើសរើសនេះបានផ្អែកលើប្រការដែលថាតំបន់ទាំងពីរនេះស្ថិតនៅជាប់នឹងខ្សែឆ្នេរសមុទ្រ និងមានផ្ទៃដីទំនាបជាច្រើនដូច្នេះស្រុកទាំងនេះងាយរងគ្រោះជាខ្លាំងដោយសារ SLR ព្យុះសមុទ្រការជ្រាបចូលនៃទឹកប្រៃនិងខ្យល់ព្យុះត្រូពិក។"

ខាងក្រោមនេះជាការបង្ហាញជូនដោយគ្រួសៗអំពីសហគមន៍គោលដៅ។

### ស្រុកព្រៃនប់ ខេត្តព្រះសីហនុ

ស្រុកព្រៃនប់មាន១៨.៥៤៤គ្រួសារនិងប្រជាជន៩៣.១៤១នាក់។ ស្រុកនេះស្ថិតនៅក្នុងតំបន់ទំនាបដែលមានផ្ទៃដីសរុប ១០.០០០ ហិកតា សម្រាប់ការផលិតស្រូវដែលស្ថិតក្រោមកិច្ចការពារពីប្រព័ន្ធទំនប់មួយ។ ប្រព័ន្ធទំនប់នេះ ត្រូវបានស្តារឡើងវិញនៅក្នុងរយៈពេលបួនឆ្នាំតាមរយៈមូលនិធិពីទីភ្នាក់ងារបារាំងដើម្បីអភិវឌ្ឍន៍ (AFD)។

ឧទាហរណ៍ចំនួនពីរ អំពីប្រតិទិនរបរប្រចាំរដូវសម្រាប់ភូមិចំនួនពីរក្នុងស្រុកព្រៃនប់[2] មានបង្ហាញជូនដូចខាងក្រោម។ ផ្អែកតាមប្រតិទិននេះ យើងអាចឃើញមូលដ្ឋាននៃប្រាក់ចំណូលរបស់អ្នកភូមិទាំងពីរនេះនៅក្នុងខែខុសៗគ្នា។

2Adaptation Knowledge Platform, "Climate Change Adaptation: Finding the appropriate responses, Annex 1, Cambodia, 2011

ប្រតិទិនមុខរបរនៅភូមិអូរតាសេកឃុំអូរឧកញ៉ាហេងស្រុកព្រៃនប់ខេត្តព្រះសីហនុ

| មុខរបរ | ប្រតិទិនគិតតាមខែ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
| **ផ្នែកលើកសិកម្ម** | | | | | | | | | | | | |
| • ស្រូវដើមរដូវនិងចុងរដូវ | | | | | ↔ | ↔ | ↔ | | | | | |
| • សណ្តែកកួរ | | | | | ↔ | ↔ | ↔ | ↔ | ↔ | ↔ | | |
| • ឪឡឹក | | | | | | | | ↔ | ↔ | ↔ | | |
| • ត្រសក់ | | | | | ↔ | ↔ | | | | | | |
| • ត្រឡាច | | | | | | | | | ↔ | ↔ | | |
| • ដំឡូងមី | | | | | | | | ↔ | ↔ | ↔ | | |
| **ការនេសាទ** | | | | | | | | | | | | |
| • ទឹកសាប | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ |
| • សមុទ្រ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ |
| **ព្រៃឈើ** | | | | | | | | | | | | |
| • ការប្រមូលយកគ្រប់អនុផលដែលពួកគេអាចរកបាន - មិនមែនសម្រាប់ជាមុខរបរឡើយ | | | | | | | | | | | | |
| **ការចិញ្ចឹមសត្វ** | | | | | | | | | | | | |
| • មាន់ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ |
| • ទា | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ |
| • ជ្រូកគោក្របី | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ |
| **កម្មករ** | | | | | | | | | | | | |
| • ក្នុងសហគមន៍ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ |
| • កម្មករកាត់ដេរឆ្នាំសន្តិសុខ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ |
| *របបអាកាសធាតុ | | រដូវប្រាំង | | | | | រដូវវស្សា | | | | | រដូវប្រាំង |

ប្រតិទិនមុខរបរនៅភូមិបត់ត្រង់ ឃុំព្រៃនប់ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ

| មុខរបរ | ប្រតិទិនគិតតាមខែ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
| **ផ្នែកលើកសិកម្ម** | | | | | | | | | | | | |
| • ដំណាំស្រូវ | | | | | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | |
| **ការនេសាទ** | | | | | | | | | | | | |
| • ការផលិត/ការប្រមូលផល | | | | | | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ |
| **ការចិញ្ចឹមសត្វ** | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ |
| **កម្មករ** | | | | | | | | | | | | |
| • កម្មការតាមការដ្ឋានសាងសង់និងកម្មករនេសាទនៅរដូវប្រាំង | ↔ | ↔ | ↔ | ↔ | ↔ | ↔ | | | | | | |
| • កម្មករកាត់ដេរ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ | ↔ |
| *របបអាកាសធាតុ | រដូវប្រាំង | | | | | រដូវវស្សា | | | | | | រដូវប្រាំង |

## ស្រុកមណ្ឌលសីមាខេត្តកោះកុង

យោងតាមព័ត៌មានថ្មីៗ ភាគច្រើនដែលទាក់ទងនឹងសហគមន៍នៅមណ្ឌលសីមាចំនួនគ្រួសារសរុបក្នុងសហគមន៍នេះគឺ ១.៨៨៣ ដែលមានប្រជាជនសរុប ៩.១៥២ នាក់។ អ្នកភូមិជិត ៩៥% ដែលរស់នៅក្នុងសហគមន៍ពាមក្រសោបពឹងផ្អែកលើការនេសាទជាប្រភពចំបងនៃប្រាក់ចំណូល។ បន្ទាប់ពីមានកិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាល ដើម្បីបញ្ឈប់ការបំផ្លាញព្រៃកោងកាងនៅក្នុងដែនបម្រុងទុក ប្រជាពលរដ្ឋជាច្រើនក្នុងមូលដ្ឋាននេះបានប្តូរមុខរបរទៅចិញ្ចឹមមាន់ និងទា នេសាទក្តាម និងខ្យង នេសាទត្រី និងជំនួញខ្នាតតូច បរបាញ់ បើកទូកតូចៗដឹកភ្ញៀវ ជួសជុលទូក និងឧបករណ៍នេសាទ ក្រងស្បូវ កែច្នៃត្រី និងជួសជុលផ្ទះ។[3]

ខាងក្រោមនេះជាឧទាហរណ៍អំពីប្រតិទិនមុខរបរនៅមណ្ឌលសីមា។[4] ការប្រៀបធៀបប្រតិទិនមុខរបរសម្រាប់ភូមិទាំងពីរនៅព្រៃនប់ភាគច្រើននៃប្រភពប្រាក់ចំណូលរបស់ភូមិនៅមណ្ឌលសីមា គឺការនេសាទ ដែលស្របជាមួយរបាយការណ៍ស្ថានភាពនៃសហគមន៍គោលដៅទាំងពីរនេះ។

3Cambodia Climate Change Alliance, "Coastal Adaptation and Recilience Planning Component", 2010, p. 23 - 24

4Adaptation Knowledge Platform, "Climate Change Adaptation: Finding the appropriate responses, Annex 2, Cambodia, 2011

ប្រតិទិនមុខរបរសម្រាប់ភូមិតាចាតឃុំទួលគរគីស្រុកមណ្ឌលសីមាខេត្តកោះកុង




# ការគូសបញ្ជាក់និយមន័យនៃពាក្យ

ការគូសបញ្ជាក់ខ្លីមួយអំពីពាក្យចំនួនពីរគឺជាការចាំបាច់។ ពាក្យទាំងពីរនោះគឺ៖

- យុទ្ធសាស្ត្របន្សាំ
- យុទ្ធសាស្ត្រដោះទ័ល

មូលហេតុនៃការគូសបញ្ជាក់នេះគឺ "ការបន្សាំ" ជាពាក្យដែលមានប្រើប្រាស់ជាធម្មតានៅក្នុងការជជែកអំពីការប្រែប្រួលអាកាសធាតុ។ ទោះជាយ៉ាងណាក៏ដោយ ជាញឹកញាប់មានការប្រើប្រាស់មិនត្រឹមត្រូវក្នុងការអធិប្បាយអំពីសមត្ថភាពរបស់បុគ្គល និងគ្រួសារក្នុងការទប់ទល់នឹងការប្រែប្រួលអាកាសធាតុ ដែលអាចឲ្យនិយមន័យបានត្រឹមត្រូវថាជាយុទ្ធសាស្ត្រដោះទ័ល។

ដើម្បីបញ្ចៀសការច្រឡំបែបនេះ ផ្នែកនេះនឹងពិភាក្សាពាក្យចំនួនពីរ និងវិធីនៃការឲ្យនិយមន័យនៅក្នុងការស្រាវជ្រាវអំពីការប្រែប្រួលអាកាសធាតុ។

## យុទ្ធសាស្ត្របន្សាំ

ការបន្សាំត្រូវបានប្រើប្រាស់សម្រាប់កំណត់និយមន័យសមត្ថភាពនៃប្រព័ន្ធមួយ ក្នុងការសម្របទៅតាមការប្រែប្រួលអាកាសធាតុ-ដែលរួមទាំងវិសមរូបអាកាសធាតុ និងភាពមិនប្រក្រតីនៃអាកាសធាតុ។ តាមរយៈ *ការកែតម្រូវ* មានន័យថាសមត្ថភាពរបស់ប្រព័ន្ធមិនត្រឹមតែកាត់បន្ថយការខូចខាត និងផលវិបាកដែលអាចកើតមានប៉ុណ្ណោះទេ ប៉ុន្តែក៏អាចប្រើប្រាស់ឱកាសដែលកើតចេញពីការប្រែប្រួលអាកាសធាតុផងដែរ។ ជាបឋមមធ្យោបាយសម្រាប់កែតម្រូវនៃប្រព័ន្ធណាមួយ មានការផ្សារភ្ជាប់ជាមួយការកែសម្រួលឥរិយាបថនៅកម្រិតជាតិប្រើប្រាស់ធនធាននិងបច្ចេកវិទ្យា។[5]

[5]Intergovernmental Panel on Climate Change, "The Fourth Assessment Report of the Intergovernmental Panel on Climate Change", 2007.

### និយមន័យអំពីយុទ្ធសាស្រ្តដោះទ័ល

*យុទ្ធសាស្ត្រដោះទ័ល* ផ្តោតលើកម្រិតមីក្រូឬជាក់លាក់ជាងនេះ គឺមធ្យោបាយសម្រាប់ប្រជាជន និង អង្គការនានាប្រើប្រាស់ធនធានដែលមាន និងពង្រឹងសកម្មភាពរបស់ពួកគេក្នុងការទប់ទល់នឹងផលវិបាកនៃការ ប្រែប្រួលអាកាសធាតុ។

សញ្ញាណសំខាន់នៃយុទ្ធសាស្រ្តដោះទ័ល គឺយុទ្ធសាស្រ្តនេះមិនគួរមានដំណើរការតែនៅក្នុងលក្ខខណ្ឌ ធាតុអាកាសមិនប្រក្រតី ឬអវិជ្ជមានប៉ុណ្ណោះទេ វាក៏ត្រូវតែអាចប្រើការបានផងដែរនៅក្នុងពេលធម្មតាផងដែរ។ ជាលទ្ធផលយុទ្ធសាស្រ្តដោះទ័លមួយគួរតែដាក់ឲ្យអនុវត្ត និងដំណើរការទៅបាននៅមុនការកើតឡើងនៃមុខ សញ្ញាគ្រោះថ្នាក់ធាតុអាកាសណាមួយផងដែរ។[6]

លើសពីនេះ យុទ្ធសាស្រ្តដោះទ័លដែលមាននិរន្តរភាព ត្រូវតែផ្អែកលើមូលដ្ឋាននៃការជូនដំណឹងអំពី ទិន្នន័យដែលពាក់ព័ន្ធដូចជាការព្យាករណ៍ធាតុអាកាស។

## ការប្រមូលទិន្នន័យ

ដូចដែលបានកត់សំគាល់ពីខាងដើម នៅកម្ពុជាមានការស្រាវជ្រាវយ៉ាងច្រើនរួចមកហើយអំពីការប្រែ ប្រួលអាកាសធាតុ ហើយទិន្នន័យនេះមានសារៈសំខាន់ណាស់សម្រាប់របាយការណ៍នេះ។ ទោះជាយ៉ាងណាក៏ ដោយ នៅក្នុងតំបន់គោលដៅដែលបានជ្រើសរើសការស្រាវជ្រាវបឋមបន្ថែមត្រូវបានធ្វើឡើង ដើម្បីទទួលបាន ទិន្នន័យអំពីសូចនាករដែលបានជ្រើសរើស ពោលគឺ សូចនាករដែលនឹងមានចែងពិស្តារបន្ថែមនៅខាងក្រោយ។ ទិន្នន័យដែលប្រមូលរួមមានទិន្នន័យបរិមាណនិងគុណភាព។ ការប្រមូលទិន្នន័យចែកចេញជាបួនផ្នែក៖

- បញ្ជីសំណួរនៅកម្រិតភូមិ
- ការពិភាក្សាជាក្រុមនៅកម្រិតគណៈកម្មការសហគមន៍
- ការពិភាក្សាតាមក្រុមនៅកម្រិតក្រុមប្រឹក្សាឃុំ
- បញ្ជីសំណួរនៅកម្រិតក្រុមប្រឹក្សាឃុំ

### បញ្ជីសំណួរ

ផ្នែកដំបូងនៃការប្រមូលទិន្នន័យបានផ្អែកលើបញ្ជីសំណួរ៥ទំព័រ( សូមអានឧបសម្ព័ន្ធ១ )។ បញ្ជីសំណួរ ត្រូវបានបំពេញនៅក្នុងពេលសម្ភាសទល់មុខ។ បញ្ជីសំណួរដែលប្រើប្រាស់បានផ្អែកលើប្រធានបទចំនួន ៣ ដូច តទៅ៖

*ការយល់ឃើញ៖*

ការស្រាវជ្រាវបានបង្ហាញថា ការយល់ឃើញរបស់ប្រជាជនអំពីការប្រែប្រួលអាកាសធាតុមានការទាក់ ទងដោយផ្ទាល់ទៅនឹងសមត្ថភាពរបស់ពួកគេ ក្នុងការបង្ហាញភាពខុសគ្នារវាងវិធានការឆ្លើយតបនឹងការប្រែប្រួល អាកាសធាតុដោយប្រសិទ្ធភាពនិងដោយគ្មានប្រសិទ្ធភាព។[7] ដូច្នេះ ដូចដែលមានចែងនៅក្នុងផ្នែកនេះ "ការគូស បញ្ជាក់អំពីនិយមន័យពាក្យ" អំពីយុទ្ធសាស្រ្តដោះទ័លដែលមាននិរន្តរភាពត្រូវតែបានបង្កើតនិងធ្វើឡើងដោយ

6 UNISDR, "UNISDR Terminology on Disaster Risk Reduction", p 8, 2009

7Oxfam America, "Understanding Public Perception of Climate Change in Cambodia", p 1, 2011

មានការយល់ដឹងជាមុនអំពីសាវតា។ ដើម្បីមានព័ត៌មានអំពីសាវតាប្រការសំខាន់គឺត្រូវជានាថា ការយល់ឃើញរបស់ប្រជាជនអំពីការប្រែប្រួលអាកាសធាតុមានភាពស្របគ្នាជាមួយនិយមន័យបច្ចេកទេស អំពីការប្រែប្រួលអាកាសធាតុ។ ផ្ទុយទៅវិញវាអាចមានហានិភ័យនៃការប្រាស្រ័យទាក់ទងគ្នាមិនត្រឹមត្រូវរវាងធាតុផ្សំខាងបច្ចេកទេសនៃ CARP និងសហគមន៍គោលដៅ។ នៅក្នុងរយៈពេលវែងការប្រាស្រ័យទាក់ទងគ្នាមិនត្រឹមត្រូវបែបនេះនឹងនាំឲ្យមានការបន្សាំមិនត្រឹមត្រូវ។

*ព័ត៌មាន៖*

ទីមួយយុទ្ធសាស្ត្រដោះទ័លមួយត្រូវតែផ្អែកលើព័ត៌មានអំពីសាវតា។ ទោះជាយ៉ាងណាក៏ដោយការសិក្សានានាបានបង្ហាញថា កម្ពុជាច្រើនខ្វះព័ត៌មាននៅពេលមុខសញ្ញាគ្រោះថ្នាក់ធាតុអាកាសកើតឡើង ហើយជាលទ្ធផលមានលទ្ធភាពក្នុងកម្រិតកំណត់ក្នុងការបង្កើតយុទ្ធសាស្ត្រដោះទ័លដែលមានប្រសិទ្ធភាព។

ទីពីរ ប្រសិនបើមានព័ត៌មានដែលជាគោលដៅសម្រាប់បង្កើតចំណេះដឹង ព័ត៌មាននោះត្រូវតែផ្អែកលើការយល់ឃើញដែលមានស្រាប់អំពីការប្រែប្រួលអាកាសធាតុ។ ដូច្នេះប្រការសំខាន់គឺត្រូវយល់អំពីចំណងទាក់ទងរវាងការយល់ឃើញអំពីសហគមន៍គោលដៅ និងវិធីដែលសហគមន៍គោលដៅបានទទួលព័ត៌មានអំពីការប្រែប្រួលអាកាសធាតុ។

*យុទ្ធសាស្ត្រដោះទ័ល*

ប្រធានបទនេះ គឺត្រូវយល់ថាតើសហគមន៍គោលដៅបានបង្កើតយុទ្ធសាស្ត្រដោះទ័លណាមួយឬទេ បើទោះជាយុទ្ធសាស្ត្រទាំងនោះមាន ឬគ្មានប្រសិទ្ធភាពក៏ដោយ។

ដោយពិចារណាអំពីចំណុចនេះប្រធានបទទី ៣ មានសារៈសំខាន់ជាសារវន្តដោយសាររបាយការណ៍នេះមានគោលដៅបកស្រាយអំពីយុទ្ធសាស្ត្រដោះទ័ល។ ទី២ ប្រធានបទនេះនឹងគាំទ្រដល់ការវិភាគអំពីភាពស្របគ្នារវាងការយល់ឃើញរបស់អ្នកភូមិ អំពីការប្រែប្រួលអាកាសធាតុ និងនិយមន័យបច្ចេកទេសដោយផ្តល់ទិន្នន័យអំពីការយល់ឃើញរបស់អ្នកភូមិអំពីអ្វីដែលជាយុទ្ធសាស្ត្រដោះទ័ល។

និយមន័យនៃពាក្យ "*យុទ្ធសាស្ត្រដោះទ័ល*" ត្រូវបានពង្រីកនិងប្រៀបធៀបជាមួយនិយមន័យតាមទ្រឹស្តីដែលមានបង្ហាញក្នុងផ្នែកនេះ "*ការគូសបញ្ជាក់អំពីនិយមន័យពាក្យ*"។ នៅក្នុងការប្រមូលទិន្នន័យគឺការយល់ឃើញរបស់អ្នកឆ្លើយអំពីអ្វីដែលជាយុទ្ធសាស្ត្រដោះទ័ល។ ការយល់ឃើញរបស់អ្នកឆ្លើយអាចពុំស្របគ្នាជាមួយនិយមន័យតាមទ្រឹស្តីសម្រាប់ពាក្យនេះឡើយ។ ចំណុចនេះនឹងមានវិភាគបន្ថែមទៀតនៅក្នុងរបាយការណ៍នេះ។

## ការពិភាក្សាជាក្រុម និងបញ្ជីសំណួរ

ផ្នែកទី២ នៃការប្រមូលទិន្នន័យផ្សំដោយការពិភាក្សាជាពីរបែប។ គោលបំណងនៃផ្នែកនេះគឺបកស្រាយឲ្យកាន់តែពិស្តារអំពីការពិភាក្សាដែលបានឆ្លុះបញ្ចាំងអំពីមុខសញ្ញាគ្រោះថ្នាក់ធាតុអាកាស ដែលបានកើតឡើងនៅក្នុងសហគមន៍គោលដៅ។

ការពិភាក្សាជាក្រុមតាមវិធីទាំងពីរនេះ ត្រូវបានអនុវត្តនៅក្នុងដំណើរការដែលមានការសម្របសម្រួល។ ការពិភាក្សាមួយបែបធ្វើឡើងជាមួយសមាជិកគណៈកម្មការសហគមន៍ និងមួយទៀតជាមួយសមាជិកក្រុមប្រឹក្សាឃុំនៅក្នុងសហគមន៍គោលដៅ។

សម្រាប់ការពិភាក្សាជាក្រុមជាមួយគណៈកម្មការសហគមន៍មានការរៀបចំតារាងម៉ាទ្រិកមួយ។ តារាងនេះសង្ខេបលទ្ធផលនៃការពិភាក្សាជាក្រុម។តារាងទាំងអស់ដែលបានរៀបចំឡើងមាននៅក្នុងឧបសម្ព័ន្ធ២។

សម្រាប់ក្រុមប្រឹក្សាឃុំការពិភាក្សាជាក្រុមបានធ្វើឡើងទៅតាមបញ្ជីសំណួរ។ លើសពីនេះសមាជិកម្នាក់ៗនៃក្រុមប្រឹក្សាឃុំបានឆ្លើយនឹងបញ្ជីសំណួរដោយផ្តល់ពិន្ទុសម្រាប់សំណួរនីមួយៗ។ ឯកសារទាំងពីរនេះមាននៅក្នុងឧបសម្ព័ន្ធ១។

## កម្រិតកំណត់

របាយការណ៍នេះមានដែនកំណត់មួយចំនួនដែលភាគច្រើនទាក់ទងនឹងការប្រមូលទិន្នន័យ។

ការប្រែប្រួលអាកាសធាតុគឺជាសញ្ញាណដែលផ្អែកលើនិយមន័យបច្ចេកទេសខ្លាំងណាស់ ហើយដោយសារពាក្យបច្ចេកទេសទាំងនេះ ការយល់ពាក្យទាំងនេះ អាចជាបញ្ហានៅពេលពិភាក្សានៅតាមតំបន់ដាច់ស្រយាល និងប្រមូលទិន្នន័យ។ ដូច្នេះក៏ធ្វើឲ្យពាក្យទាំងនេះមានលក្ខណៈសាមញ្ញគឺជាការចាំបាច់ដើម្បីធ្វើការស្រាវជ្រាវនៅតាមមូលដ្ឋាន។ ទោះជាយ៉ាងណាក៏ដោយ ប្រការនេះបង្កើតជាបញ្ហាសុពលភាពនៅក្នុងការវិភាគទិន្នន័យដែលទាក់ទងនឹងទិន្នន័យប្រែប្រួលអាកាសធាតុ ដែលមានលក្ខណៈបច្ចេកទេសកាន់តែខ្លាំង។

"ការយល់ឃើញអំពីការប្រែប្រួលអាកាសធាតុ" គឺជាសញ្ញាណសំខាន់មួយនៅក្នុងរបាយការណ៍នេះ។ នេះជាគោលគំនិតដែលមានប្រើប្រាស់នៅក្នុងឯកសារដទៃទៀតផងដែរ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងការយល់ឃើញនោះគ្មាននិយមន័យអំពីអ្វីដែលជាធាតុផ្សំនៃការប្រែប្រួលអាកាសធាតុឡើយ ហើយបើតាមគោលការណ៍បច្ចេកទេសវាគ្រាន់តែជាការយល់ដឹងអំពីទម្រង់នៃធាតុអាកាសប៉ុណ្ណោះ។ និយាយម្យ៉ាងទៀតថាតើការយល់ដឹងកម្រិតណាអំពីទម្រង់នៃធាតុអាកាស គឺជាផ្នែកមួយនៃការយល់ឃើញផ្ទាល់ខ្លួននោះអំពីការប្រែប្រួលអាកាសធាតុ? សំណួរនេះពុំមែនជាអ្វីដែលឯកសារមានស្រាប់អាចផ្តល់ចម្លើយបានច្បាស់លាស់ឡើយ។ ដោយសារតែខ្វះចម្លើយច្បាស់លាស់ វាមានផលប៉ះពាល់មកលើសុពលភាពនៃការសិក្សាប្រៀបធៀបអំពីការយល់ឃើញជាសាធារណៈនៃការប្រែប្រួលអាកាសធាតុផងដែរ។

នៅពេលធ្វើការស្រាវជ្រាវតាមមូលដ្ឋានរយៈពេលថ្ងៃក្នុងតំបន់ឆ្នេរការស្រាវជ្រាវមានភាពលំអៀងដោយស្វ័យប្រវត្តិលើយេនឌ័រ។ តាមធម្មតា នៅពេលថ្ងៃបុរសចេញទៅនេសាទឬធ្វើការនៅតាមវាលស្រែ ដូច្នេះពួកគេគ្មានពេលសម្រាប់ការសម្ភាសឡើយ។ នេះមានន័យថាពុំមានចំណែកស្មើគ្នាខាងយេនឌ័រឡើយក្នុងចំណោមអ្នកឆ្លើយនៅក្នុងការប្រមូលទិន្នន័យ។ មានវិធីសម្រាប់ជំនះភាពលំអៀងនេះ ប៉ុន្តែមិនមាននៅក្នុងក្របខ័ណ្ឌនៃរបាយការណ៍នេះដើម្បីប្រើប្រាស់វិធីបែបនោះឡើយ។ វិធីទូទៅមួយសម្រាប់ជំនះភាពលំអៀងនេះ គឺត្រូវទូទាត់សំណាងដល់អ្នកឆ្លើយដែលបានជ្រើសរើសដោយធានាថា ពួកគេនឹងមិនចេញពីផ្ទះឡើយនៅក្នុងពេលប្រមូលទិន្នន័យជំនួសការចេញទៅនេសាទឬចេញទៅស្រែ។ លើសពីនេះ វិធីនេះទាមទារឲ្យមានការចាត់ចែងកំណត់ពេលទុកជាមុន។ ប៉ុន្តែកិច្ចការនេះមានរយៈពេលខ្លី ដែលពុំមានលៃថវិកាឬពេលវេលាដើម្បីអនុវត្តវិធីនេះឡើយ។ ភាពលំអៀងនេះពិតជាមានផលប៉ះពាល់ខ្លះៗ មកលើទិន្នន័យដែលបានប្រមូល។ ដោយសារអ្នកឆ្លើយទៅនឹងសំណួរ គឺជាអ្នកភូមិដែលស្នាក់នៅនិងធ្វើការជុំវិញផ្ទះនេះ ក៏ជាទស្សនទានមួយផងដែរ ដែលជាទូទៅមានលក្ខណៈជាតំណាងនៅក្នុងទិន្នន័យដែលប្រមូលបានទាំងនេះ។ ទោះជាយ៉ាងណាក៏ដោយ នេះជាកម្រិតដែលក្រុមពិភាក្សាអាចធ្វើបានជាមួយគណៈកម្មការសហគមន៍។ សមាជិកគណៈកម្មការសហគមន៍ភាគច្រើនជា

បុរសដែលធ្វើការនៅក្រៅផ្ទះ។ ទោះជាយ៉ាងណាក៏ដោយសម្រាប់របាយការណ៍នេះមានការចាត់ចែងដើម្បីឲ្យសមាជិកគណៈកម្មការសហគមន៍បានចូលរួមនៅមុនការពិភាក្សាជាក្រុមដូចដែលបានកត់សំគាល់។

ទិន្នន័យដែលប្រមូលបានសម្រាប់របាយការណ៍នេះ មានភាពទូលំទូលាយជាបង្គួរ និងត្រូវបានប្រើប្រាស់ដើម្បីបង្កើតកម្រងទិន្នន័យទូលំទូលាយមួយ។ ការសិក្សានេះពុំធ្វើការវិភាគចំណុចពិស្តារទាំងអស់នៃទិន្នន័យទាំងនេះទេ។ ផ្ទុយទៅវិញការយកចិត្តទុកដាក់បានផ្តោតលើការវាយតម្លៃពិស្តារ ដោយប្រើប្រាស់ទិន្នន័យដែលទាញយកពីកម្រងទិន្នន័យនេះ។

## តំបន់ឆ្នេរ

តំបន់ឆ្នេរកម្ពុជាចែកចេញជាខេត្តចំនួនបួន(កំពតកោះកុងព្រះសីហនុនិងកែប)។ ផ្ទៃដីសរុបក្នុងខេត្តទាំងនេះមានប្រមាណ១៧.២៣៧គ.ម$^{2}$។ខ្សែឆ្នេរមានប្រវែង៤៣៥គ.មស្ថិតនៅក្នុងឈូងសមុទ្រថៃ។ នៅតាមឆ្នេរសមុទ្រមានកំពង់ផែសមុទ្រទឹកជ្រៅមួយ ស្ថិតនៅក្រុងព្រះសីហនុនិងត្រូវបានចាត់ទុកថាជាមជ្ឈមណ្ឌលសេដ្ឋកិច្ចចំបងនៅកម្ពុជា។[8]

អាកាសធាតុក្នុងតំបន់ឆ្នេរត្រូវបានឲ្យនិយមន័យថា ជាអាកាសធាតុមូសុងត្រូពិកដែលមានកំពស់ទឹកភ្លៀងរវាង២.០០០ និង ៤.០០០ម.ម។ បរិមាណនេះខ្ពស់ជាងក្នុងតំបន់ផ្សេងទៀតនៃប្រទេសកម្ពុជា។[9]

តំបន់ឆ្នេរមានប្រភពទឹកសាបជាច្រើនដែលបានពីស្ទឹងទន្លេនិងបឹងនានា ដែលហូរកាត់តំបន់នេះ។ បើទោះជាមានប្រភពទឹកសាបប្រកបដោយសក្តានុពលបែបនេះក៏ដោយ កង្វះទឹកសាបគឺជាបញ្ហាមួយក្នុងតំបន់នេះ។

នៅក្នុងរដូវភ្លៀងទន្លេស្ទឹង និងបឹងមានទឹកជំនន់បណ្តាលពីការធ្លាក់ភ្លៀងខ្លាំងដែលបំផ្លាញដំណាំនៅក្នុងតំបន់ទំនាប។ នៅរដូវប្រាំងទឹកក្នុងទន្លេនៅតំបន់ខ្សែទឹកខាងក្រោមទទួលបានល្បាយទឹកប្រៃ និងទឹកសាបដែលធ្វើឲ្យទឹកនេះមិនសមស្របសម្រាប់គោលបំណងនៃការស្រោចស្រពឡើយ។[10]

83/2-2012, http://www.wepa-db.net/policies/state/cambodia/seaarea.htm

9IBID

10Cambodia Climate Change Alliance, ”Coastal Adaptation and Recilience Planning Component”, 2010, p. 16




រូបទី១. ការប្រើប្រាស់ដីក្នុងតំបន់ឆ្នេរ

តំបន់ឆ្នេរមានធនធានធម្មជាតិជាច្រើនបែបដូចជាព្រៃឈើកោងកាងនិងស្មៅសមុទ្រ។

## *ព្រៃឈើនិងព្រៃកោងកាង*

ភាគច្រើនបំផុតនៃតំបន់ឆ្នេរគ្របដណ្តប់ដោយព្រៃឈើ។ គម្របព្រៃច្រើនជាងគេមាននៅក្នុងខេត្តកោះកុង (៨៣% ឬ១.០០២.៧២១ហ.ត) បន្ទាប់មកគឺខេត្តព្រះសីហនុ (៥៤% ឬ៨១.៥៣៩ហ.ត) និងកំពត (២១%ឬ៣.៧៣៣ហ.ត)។ ពីឆ្នាំ១៩៩៣ដល់២០០៥វិសាលភាពព្រៃឈើក្នុងតំបន់ឆ្នេរ បានថយចុះពី ៨៤% មក៧១% ភាគច្រើនដោយសារផលិតកម្មកសិកម្ម។[11]

នៅឆ្នាំ២០០៥ ផ្ទៃដី ៥៥.៤១៩ហ.ត នៅតាមឆ្នេរសមុទ្រគ្របដណ្តប់ដោយព្រៃកោងកាង។ ព្រៃកោងកាងរួមជាមួយប្រព័ន្ធអេកូឡូស៊ីរបស់វាមានសារៈសំខាន់ជាសារវន្ត សម្រាប់តំបន់ឆ្នេរដោយសារមូលហេតុចំនួនពីរ។ ទីមួយ ព្រៃកោងកាងមានតួនាទីស្នូលនៅក្នុងការរស់រាន នៃត្រីជាច្រើនប្រភេទនិងសារពាង្គកាយដទៃទៀតក្នុងសមុទ្រ។ ទីពីរ ព្រៃកោងកាងមាននាទីជាខ្សែត្រៀមជួរមុខទប់ទល់នឹងខ្យល់ព្យុះត្រូពិក ព្យុះសមុទ្រ និងកំណើនកំពស់ទឹកសមុទ្រ ដូច្នេះជួយកាត់បន្ថយសំណឹកឆ្នេរ និងការជន់លិចដោយបង្កើតជាតំបន់ទ្រនាប់ដែលការពារឆ្នេរសមុទ្រ។ ទោះជាមានតួនាទីស្នូលសម្រាប់តំបន់ឆ្នេរបែបនេះក៏ដោយ ការសិក្សាខ្លះបានប៉ាន់ស្មានថា រវាងឆ្នាំ១៩៩៣ និង២០០៥ ព្រៃកោងកាងបានបាត់បង់២៥%។ ការថយចុះនេះភាគច្រើនដោយសារការប្រើប្រាស់ព្រៃកោងកាងដោយល្មើសច្បាប់សម្រាប់ជាអុស និងសម្រាប់ការផលិតធ្យូង។មូលហេតុដទៃទៀត រួមមាន

11Cambodia Climate Change Alliance, "Coastal Adaptation and Recilience Planning Component", 2010, p. 14

ការរានឆ្ការព្រៃសម្រាប់យកដី និងការបង្កើតស្រែអំបិលហើយស្រះចិញ្ចឹមបង្គារប្រពលវប្បកម្មក៏ដើរតួសំខាន់នៅក្នុងការថយចុះនៃព្រៃកោងកាងផងដែរ។[12]

*ស្មៅសមុទ្រ*

តំបន់ឆ្នេរកម្ពុជាមានស្មៅសមុទ្រក្នុងវិសាលភាពធំធេង។ នៅតាមឆ្នេរសមុទ្រមានស្មៅសមុទ្រចំនួន៨ប្រភេទ។ ស្មៅសមុទ្រមាននាទីជាទីជម្រកសម្រាប់កូនត្រីដូច្នេះជួយផ្តល់ជាកន្លែងលូតលាស់សម្រាប់ត្រីប្រភេទខុសៗគ្នាជាច្រើនដែលរួមទាំងវង្កសត្វនិងសត្វឥតឆ្អឹងកងផងដែរ។

ស្មៅសមុទ្រកំពុងស្ថិតក្រោមសម្ពាធនៃការខូចគុណភាពទឹក ដោយសារតែការកាប់ឈើការបូមយកខ្សាច់ និងសកម្មភាពរានឆ្ការយកដីក្នុងតំបន់ឆ្នេរ។ លើសពីនេះការនេសាទត្រីតាមបែបបំផ្លាញក៏បង្កការប៉ះពាល់អវិជ្ជមានមកលើវិសាលភាពនៃស្មៅសមុទ្រនៅតាមឆ្នេរសមុទ្រផងដែរ។[13]

## ការប្រែប្រួលអាកាសធាតុនៅកម្ពុជា

ដើម្បីវាយតម្លៃអំពីយុទ្ធសាស្ត្រដោះទ័លទៅនឹងការប្រែប្រួលអាកាសធាតុ នៅក្នុងសហគមន៍តំបនឆ្នេរប្រការសំខាន់ដំបូងគឺត្រូវយល់ថា តើសហគមន៍ទាំងនេះត្រូវទប់ទល់នឹងអ្វី។

កម្ពុជាមិនមែនជាប្រទេសរងឥទ្ធិពលខ្លាំងក្លា ដោយសារផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុដូចប្រទេសដទៃក្នុងតំបន់នេះឡើយដូចជា វៀតណាម និងហ្វីលីពីន។ ប៉ុន្តែកម្ពុជាត្រូវបានចាត់ជាប្រទេសមួយក្នុងចំណោមប្រទេសងាយរងគ្រោះបំផុតលើពិភពលោក ដោយសារការប្រែប្រួលអាកាសធាតុ (លំដាប់ទី៩នៅក្នុងសន្ទស្សន៍ហានិភ័យពិភពលោកឆ្នាំ២០១១ ស្តីពីលំដាប់ថ្នាក់ភាពងាយរងគ្រោះចំពោះគ្រោះមហន្តរាយធម្មជាតិ និងលំដាប់ទី៦ក្នុងសន្ទស្សន៍ Maplecroft ភាពងាយរងគ្រោះនៃការប្រែប្រួលអាកាសធាតុឆ្នាំ២០១២)។[14] ភាពងាយរងគ្រោះរបស់កម្ពុជា កើតឡើងដោយសារតែភាពទន់ខ្សោយនៃហេដ្ឋារចនាសម្ព័ន្ធកម្រិតទាបនៃសមត្ថភាពក្នុងការបន្សាំនឹងឥទ្ធិពល នៃការប្រែប្រួលអាកាសធាតុហើយប្រជាពលរដ្ឋជាច្រើន មានរបរកសិកម្ម និងរស់នៅក្នុងតំបន់ដាច់ស្រយាល។

កម្ពុជា និងរបបអាកាសធាតុមូសុងពឹងផ្អែកជាខ្លាំងលើរដូវវស្សាពីខែឧសភាដល់វិច្ឆិកានិងទឹកជំនន់ប្រចាំរដូវនៃទន្លេមេគង្គ និងបឹងទន្លេសាប។ កត្តាទាំងពីរនេះឥឡូវកាន់តែលែងអាចទុកចិត្តបានទាក់ទងនឹងពេលវេលានិងប្រភពភាពរបស់វា។[15]

សីតុណ្ហភាពមធ្យមប្រចាំឆ្នាំនៅកម្ពុជាត្រូវបានព្យាករណ៍ថានឹងកើនឡើង ០,៧-២,៧$^{0}$C ហូតដល់ទសវត្សរ៍ឆ្នាំ២០៦០។[16]

12 IBID, 2010, p. 15

13IBID, 2010, p. 15 - 16

142/2-2012, http://www.businessinsider.com/climate-change-vulnerability-2011-10

1525/2-2012, http://sdwebx.worldbank.org/climateportalb/home.cfm?page=country_profile

1625/2-2012, http://sdwebx.worldbank.org/climateportalb/home.cfm?page=country_profile

## តំបន់ឆ្នេរ

ក្នុងចំណោមតំបន់ដែលងាយរងគ្រោះជាងគេទៅនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា គឺតំបន់ឆ្នេរ។ ក្នុងចំណោមបញ្ហានានាតំបន់ឆ្នេរត្រូវប្រឈមគឺកំណើនកំពស់ទឹកសមុទ្រ។ ការសិក្សានានាបង្ហាញថា ប្រសិនបើតំបន់ឆ្នេរជួបកំណើនទឹកកំពស់ទឹកសមុទ្រ១មផ្ទៃដី០,៤%នៃខេត្តកោះកុងនឹងត្រូវស្ថិតក្រោមផ្ទៃទឹកជាអចិន្ត្រៃយ៍ នៅក្រោមកំណើនកំពស់ទឹកសមុទ្រ០,១៨ដល់០,៥៦ម រហូតដល់ទសវត្សរ៍ឆ្នាំ២០៩០។[17] គេត្រូវយល់អំពីការគំរាមកំហែងនេះធៀបនឹងបញ្ហាបរិស្ថានសំខាន់ៗដទៃទៀតនៅក្នុងតំបន់ឆ្នេរ។ តំបន់ឆ្នេរបានជួបប្រទះការថយចុះនៃវិសាលភាពព្រៃកោងកាងដោយសារតែការបាត់បង់ព្រៃឈើ និងការថយចុះជាទូទៅនៃជីវៈចម្រុះនៅក្នុងតំបន់ឆ្នេរពោលគឺការថយចុះនៃជីវៈចម្រុះ ដែលដែលអាចនាំទៅរកការការថយចុះដោយស្វ័យប្រវត្តិនៃព្រៃកោងកាង។ រាល់បញ្ហាទាំងនេះរួមគ្នាជាមួយខ្យល់ព្យុះនិងព្យុះសមុទ្រដែលនឹងកើតមានកាន់តែ ញឹកញាប់និងខ្លាំងក្លាបាននាំឲ្យមានការជន់លិចក្នុងតំបន់ឆ្នេរកាន់តែខ្លាំងឡើង។[18] ការជន់លិចតំបន់ឆ្នេរមានឥទ្ធិពលដ៏មហន្តរាយមកលើសហគមន៍នៅតាមខ្សែឆ្នេរសមុទ្រ។ ផលវិបាកមួយគឺការកើនឡើងនៃកម្រិតប្រៃនៃទឹកលើផ្ទៃដីនិងទឹកក្រោមដីដែលមានផលប៉ះពាល់ធ្ងន់ធ្ងរមកលើដីជាតិដីនៃតំបន់ដែលប្រើប្រាស់សម្រាប់ដាំដំណាំ និងមកលើប្រព័ន្ធអេកូឡូស៊ីដែលពឹងផ្អែកលើទឹកសាប។

លើសពីនេះ ភាគច្រើននៃកសិកម្មនៅក្នុងតំបន់ឆ្នេរប្រមូលផ្តុំនៅក្នុងទីទំនាបនៃតំបន់ឆ្នេរ ដូច្នេះសន្តិសុខស្បៀងនៅក្នុងតំបន់នេះអាចស្ថិតក្រោមការគំរាមកំហែង។ ហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់ឆ្នេរក៏ស្ថិតក្រោមការគំរាមកំហែងពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុផងដែរ ដែលអាចនាំឲ្យមានកំណើនភាពងាយរងគ្រោះជាបន្តបន្ទាប់ និងការបាត់បង់ប្រាក់ចំណូលពីទេសចរណ៍។[19]

ការគំរាមកំហែងផ្សេងទៀតពីការប្រែប្រួលអាកាសធាតុនៅក្នុងតំបន់ឆ្នេរគឺ៖[20]

- កំណើនកំពស់ទឹកភ្លៀងពី២ទៅ៦% រហូតដល់ឆ្នាំ២០៥០ដែលនឹងនាំមកនូវជំនន់កាន់តែច្រើន
- ការធ្លាក់ភ្លៀងកាន់តែខ្លាំងនៅក្នុងរយៈពេលខ្លី
- កំណើនសីតុណ្ហភាពមធ្យមប្រចាំឆ្នាំពី០,៧ទៅ២,៧ អង្សារហូតដល់ឆ្នាំ២០៦០ និង១,៤ ដល់ ៤,៣ អង្សារហូតដល់ទសវត្សរ៍ឆ្នាំ២០៩០ដែលនឹងនាំឲ្យមានភាពរាំងស្ងួតកាន់តែខ្លាំង។

## ក្របខ័ណ្ឌស្ថាប័ន

ដើម្បីអាចបន្សាំនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ គេត្រូវការសមត្ថភាពខ្លះៗខាងស្ថាប័ន។ សមត្ថភាពទាំងនេះរួមបញ្ចូលមិនត្រឹមតែជាយុទ្ធសាស្ត្រដោះទ័ល ដែលអនុវត្តដោយអ្នកភូមិនៅក្នុងតំបន់គោលដៅប៉ុណ្ណោះទេ ប៉ុន្តែយុទ្ធសាស្ត្របន្សាំដែលមានលក្ខណៈចម្រុះរួមបញ្ចូលគ្រប់លំដាប់ថ្នាក់ក្នុងសង្គមកម្ពុជា។

---

1717/2-2012, http://www.thegef.org/gef/sites/thegef.org/files/documents/document/2-7-11%20-%20Webposting.pdf

182/2012,http://www.sida.se/Global/Countries%20and%20regions/Asia%20incl.%20Middle%20East/Cambodia/Environmental%20Policy%20Brief%20Cambodia.pdf

1917/2-2012, http://weadapt.org/knowledge-base/vulnerability/Cambodia

2017/2-2012, IBID

*គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ* (NCCC) ដែលបានបង្កើតឡើងនៅខែមេសា ឆ្នាំ២០០៦ គឺជាយន្តការអន្តរក្រសួងមួយដែលមានអាណត្តិរៀបចំ សម្របសម្រួល និងតាមដានការអនុវត្ត គោលនយោបាយយុទ្ធសាស្ត្រលិខិតបទដ្ឋានគតិយុត្តិ ផែនការ និងកម្មវិធី នានារបស់កម្ពុជាដែលទាក់ទងនឹង ការប្រែប្រួលអាកាសធាតុ។ នាយករដ្ឋមន្ត្រីកម្ពុជា សម្តេច **ហ៊ុន សែន** មាននាទីជាប្រធានកិត្តិយសនៃ NCCC ដែលនេះជាការបង្ហាញពីឥទ្ធិពលនយោបាយរបស់ NCCC។ គណៈកម្មាធិការ NCCC មានសមាសភាពជា រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការមកពីក្រសួងស្ថាប័នចំនួន១៩ នៃរាជរដ្ឋាភិបាល។[21]

ក្រៅពី NCCC ក្រសួងចំនួន៣ ដូចខាងក្រោមនេះ មានការទទួលខុសត្រូវចំបងដែលទាក់ទងនឹងការ ប្រែប្រួលអាកាសធាតុធនធានធម្មជាតិនិងការគ្រប់គ្រងនិងអភិវឌ្ឍន៍ប្រព័ន្ធអេកូឡូស៊ីតំបន់ឆ្នេរ។

- **ក្រសួងបរិស្ថាន** (MoE) បានបង្កើតនៅឆ្នាំ១៩៩៣និងមានភារៈទទួលខុសត្រូវលើកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិនៅក្នុងប្រទេស។ MoE ក៏មានភារៈទទួលខុសត្រូវលើការប្រែប្រួល អាកាសធាតុផងដែរហើយនាយកដ្ឋានប្រែប្រួលអាកាសធាតុនៅក្នុង MoE ដើរតួជាលេខាធិការដ្ឋាន សម្រាប់ NCCC។ ទាក់ទងនឹងតំបន់ឆ្នេរ MoE មានអាណត្តិសម្របសម្រួលការគ្រប់គ្រងបរិស្ថាន និង សកម្មភាពអភិវឌ្ឍន៍ក្នុងតំបន់ឆ្នេរអនុលោមតាមសេចក្តីសម្រេចដោយនាយករដ្ឋមន្ត្រី។
- **ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ**(MAFF) មានអាណត្តិគ្រប់គ្រងសកម្មភាពទាំងអស់ ដែលទាក់ ទងនឹងជលផលដែលរួមទាំងការនេសាទសិប្បកម្មព្រៃកោងកាងស្មៅសមុទ្រ និងការនេសាទឧស្សាហកម្ម។ ជាក់ស្តែងក្រសួងនេះមានការទទួលខុសត្រូវលើការគ្រប់គ្រងប្រចាំថ្ងៃលើធនធានភាគច្រើនក្នុងតំបន់ ឆ្នេរដោយគ្មានអាណត្តិសម្របសម្រួលទូទៅសម្រាប់ការគ្រប់គ្រងបរិស្ថានជារួមឡើយ។
- **ក្រសួងធនធានទឹកនិងឧតុនិយម** (MoWRAM) មានភារៈទទួលខុសត្រូវលើការគ្រប់គ្រងរាល់ សកម្មភាពដែលទាក់ទងនឹងការអភិវឌ្ឍទឹកនិងឧតុនិយមនិងគ្រោះមហន្តរាយធម្មជាតិ។ MoWRAM បានចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់ (MoU) ដែលទាក់ទងជាមួយការបែងចែកការ ទទួលខុសត្រូវលើការគ្រប់គ្រងប៉ូលឌែរនៅព្រៃនប់ជាមួយអាជ្ញាធរខេត្តព្រះសីហនុ និងក្រុមសហគមន៍ កសិករប្រើប្រាស់ទឹកនៅប៉ូលឌែរព្រៃនប់។

ស្ថាប័នផ្សេងទៀតនៃរដ្ឋាភិបាលដែលពាក់ព័ន្ធជាមួយការប្រែប្រួលអាកាសធាតុ៖

- ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ (MLMUPC) មានភារៈទទួលខុសត្រូវកសាង ផែនការអភិវឌ្ឍន៍និងផែនការប្រើប្រាស់ដីនៅថ្នាក់ជាតិនិងមូលដ្ឋាន
- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ(NCDM)បានបង្កើតនៅឆ្នាំ១៩៩៥ និងជាស្ថាប័ន អន្តរក្រសួងដែលមាននាយករដ្ឋមន្ត្រីជាប្រធាន។ NCDM ដើរតួគន្លឹះក្នុងការគ្រប់គ្រងគ្រោះ មហន្តរាយដោយធ្វើការទាំងលើការកាត់បន្ថយ/ទប់ស្កាត់ហានិភ័យគ្រោះមហន្តរាយ និងការត្រៀម បង្ការផងដែរ

21Royal Cambodian Government, ”Sub-decree on The Establishment of The National Climate Change Committee”, 2006

- ក្រសួងឧស្សាហកម្មរ៉ែនិងថាមពល (MIME) មានភារៈទទួលខុសត្រូវលើការកសាងផែនការប្រើប្រាស់ទឹកក្នុងឧស្សាហកម្មថាមពលវារីអគ្គិសនីនិងការផ្គត់ផ្គង់ទឹកស្អាតដល់ទីរួមខេត្តនិងចាត់ចែងលើប្រព័ន្ធគោលបំណងតែមួយដែលពាក់ព័ន្ធជាមួយថាមពលវារីអគ្គិសនី
- ក្រសួងសាធារណការនិងដឹកជញ្ជូន (MPWT) មានភារៈទទួលខុសត្រូវលើការសាងសង់ផ្លូវថ្នល់ហេដ្ឋារចនាសម្ព័ន្ធនានាដូចជា ស្ពាន និងកំពង់ផែ
- ក្រសួងអភិវឌ្ឍន៍ជនបទ (MRD)មានភារៈទទួលខុសត្រូវលើការផ្គត់ផ្គង់ទឹកខ្នាតតូចដល់គ្រួសារនានា (ដីកអណ្តូងនិងស្រះ) ការថែទាំសុខភាពបឋមហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច (ផ្លូវស្ពានបំពង់លូ។ល។)

## ក្របខ័ណ្ឌគោលនយោបាយ

កម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ (NAPA) ដើរតួជាក្របខ័ណ្ឌគោលនយោបាយសម្រាប់ NCCC។ NAPA ត្រូវបានរៀបចំឡើងតាមរយៈដំណើរការនៃការប្រមូលព័ត៌មានអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅកម្ពុជា ដើម្បីចាត់ជាអាទិភាពតម្រូវការបន្សាំនៅក្នុងប្រទេស និងដើម្បីបង្កើតភាពបំពេញគ្នាជាមួយកម្មវិធីបរិស្ថាននិងកម្មវិធីអភិវឌ្ឍន៍ដទៃទៀត។[22]

NAPA របស់កម្ពុជាបានកំណត់គោលបំណងនានាដូចតទៅ៖[23]

- ស្វែងយល់ពីសំណុំលក្ខណៈនៃមុខសញ្ញាគ្រោះថ្នាក់ប្រែប្រួលអាកាសធាតុនៅកម្ពុជា
- ស្វែងយល់ពីយន្តការទប់ទល់ចំពោះមុខសញ្ញាគ្រោះថ្នាក់អាកាសធាតុនិងការប្រែប្រួលអាកាសធាតុនៅកម្រិតមូលដ្ឋាន
- ស្វែងយល់ពីកម្មវិធីនិងរចនាសម្ព័ន្ធស្ថាប័នដែលមានស្រាប់សម្រាប់ដោះស្រាយមុខសញ្ញាគ្រោះថ្នាក់អាកាសធាតុនិងការប្រែប្រួលអាកាសធាតុ
- កំណត់អត្តសញ្ញាណនិងចាត់ជាអាទិភាពសកម្មភាពបន្សាំចំពោះមុខសញ្ញាគ្រោះថ្នាក់អាកាសធាតុនិងការប្រែប្រួលអាកាសធាតុ។

ក្រៅពី NAPA ផែនការសកម្មភាពយុទ្ធសាស្ត្រជាតិសម្រាប់ការប្រែប្រួលអាកាសធាតុក៏កំពុងស្ថិតក្នុងការរៀបចំដោយក្រសួងបរិស្ថានផងដែរ។[24]

លើសពីនេះ ផែនការគ្រប់គ្រងបរិស្ថានថ្នាក់ខេត្តសម្រាប់ឆ្នាំ២០១១-២០១៥ កំពុងស្ថិតក្នុងការរៀបចំបង្ហើយ ប៉ុន្តែនៅពុំទាន់បានអនុម័ត។ ទោះជាយ៉ាងណាក៏ដោយ មានការរំពឹងថាផែនការនេះនឹងមានការប្រែប្រួលអាកាសធាតុជាប្រធានបទរួមមួយ និងមាននាទីជាក្របខ័ណ្ឌគោលនយោបាយដ៏សំខាន់សម្រាប់យុទ្ធសាស្ត្របន្សាំនឹងការប្រែប្រួលអាកាសធាតុ។

22 Royal Cambodian Government, "National Adaptation Programme of Actions taken to Climate Change", 2006, p. i

23 IBID, 2006, p. 1-2

24 UN-HABITAT, "Vulnerability Assesment", 2011, p 2

## ការយល់ឃើញរបស់កម្ពុជាអំពីការប្រែប្រួលអាកាសធាតុ

ការសិក្សាមួយចំនួនដែលទាក់ទងនឹងប្រធានបទ "ការយល់ឃើញអំពីការប្រែប្រួលអាកាសធាតុ" ត្រូវបានធ្វើរួចមកហើយនៅកម្ពុជា។ ការសិក្សាទូលំទូលាយបំផុតមួយគឺ*ការស្វែងយល់អំពីទស្សនៈរបស់សាធារណជនអំពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា* (ការសិក្សាKAP) ដែលធ្វើឡើងដោយអុកស្វាមអាមេរិក។ ទិន្នន័យដែលបានពីការសិក្សានេះនិងការសិក្សាផ្សេងទៀតត្រូវបានប្រើប្រាស់នៅក្នុងរបាយការណ៍នេះ។

ផ្តើមចេញពីការសិក្សាដំបូងៗ អំពីការយល់ឃើញអំពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា អង្គការមិនមែនរដ្ឋាភិបាលដាណឺម៉ាក់ DanChurchAid បានរកឃើញថា ដើម្បីសិក្សាប្រធានបទនេះត្រូវតែមានការកែប្រែបច្ចេកស័ព្ទខ្លះៗ។ជំនួសឲ្យការប្រើប្រាស់ពាក្យ "ការប្រែប្រួលអាកាសធាតុ" ពាក្យថា "របបធាតុអាកាស" ត្រូវបានប្រើប្រាស់នៅពេលប្រមូលទិន្នន័យអំពីប្រធានបទនេះ។

ដូចដែលបានកត់សំគាល់នៅក្នុងផ្នែកស្តីពីវិធីសាស្ត្រ នៅពេលអនុវត្តគម្រោងប្រែប្រួលអាកាសធាតុ ប្រការសំខាន់គឺត្រូវយល់ពីទស្សនៈរបស់ប្រជាជនអំពីការប្រែប្រួលអាកាសធាតុ។ ទោះជាយ៉ាងណាក៏ដោយ ទស្សនៈនេះមិនត្រឹមតែរួមបញ្ចូលព្រឹត្តិការណ៍ប្រែប្រួអាកាសធាតុប៉ុណ្ណោះទេ ប៉ុន្តែត្រូវរួមបញ្ចូលផងដែរទស្សនៈដែលទាក់ទងនឹងពាក្យបច្ចេកទេស ដែលប្រើប្រាស់នៅពេលពិភាក្សាអំពីការប្រែប្រួលអាកាសធាតុ។

ផ្អែកលើការសិក្សាដូចដែលបានកត់សំគាល់ពីខាងលើ មានការឯកភាពមតិអំពីប្រធានបទអំពីទស្សនៈរបស់សាធារណជនអំពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា។ ជាទូទៅប្រជាជនកម្ពុជាមានការយល់ដឹងតិចតួចអំពីមូលដ្ឋានវិទ្យាសាស្ត្រនៃការប្រែប្រួលអាកាសធាតុ ប៉ុន្តែការសិក្សានានាក៏បានបង្ហាញផងដែរថាប្រជាជនកម្ពុជាភាគច្រើនបំផុតស្គាល់ពាក្យ "ការប្រែប្រួលអាកាសធាតុ"។[25]

ដោយសារតែការយល់ដឹងតិចតួចអំពីមូលដ្ឋានវិទ្យាសាស្ត្រ សម្រាប់ការប្រែប្រួលអាកាសធាតុការសិក្សានានាបានប្រើប្រាស់ពាក្យ "ការប្រែប្រួលរបបធាតុអាកាស" ជាជំនួសនៅពេលសិក្សាទស្សនៈរបស់សាធារណជនអំពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា។ទោះជាយ៉ាងណាក៏ដោយ ចំណុចនេះបានបង្កជាសំណួរថាតើពាក្យ "ការប្រែប្រួលរបបធាតុអាកាស"នោះមានន័យបែបណា? ជំនួសឲ្យនិយមន័យដែលមានកំណត់ច្បាស់តាមទ្រឹស្តីវាជាពាក្យដែលបានពីការយល់ឃើញរបស់បុគ្គលអ្នកឆ្លើយ និងអ្នកស្រាវជ្រាវដែលបង្កើតបញ្ហាសុពលភាពដូចគ្នានេះនៃការវិភាគការយល់ឃើញដូចដែលពិភាក្សានៅក្នុងផ្នែក "ដែនកំណត់"។

ប្រជាជនកម្ពុជាមួយភាគធំមានការយល់ឃើញថា ការប្រែប្រួលនៃរបបធាតុអាកាសបានកើតឡើងនៅកម្ពុជា។ ជាផលវិបាកនៃការប្រែប្រួលទាំងនេះប្រជាជនកម្ពុជាបានឃើញមានកំណើនព្រឹត្តិការណ៍ធាតុអាកាសមិនប្រក្រតីដូចជាគ្រោះរាំងស្ងួតសីតុណ្ហភាពខ្ពស់ និងការធ្លាក់ភ្លៀងខ្លាំងដែលជាមុខសញ្ញាគ្រោះថ្នាក់ចំបងៗចំនួនបីនៃធាតុអាកាស។[26]

សមាមាត្រយ៉ាងច្រើនមួយ នៃអ្នកឆ្លើយដែលរស់នៅក្នុងសហគមន៍អ្នកនេសាទនៅតំបន់ឆ្នេរបានឃើញសំណឹកឆ្នេរនិងទឹកជោរនិងរលកខ្ពស់ៗ នៅក្នុងបណ្តាឆ្នាំកន្លងទៅថ្មីៗនេះ។ ប្រជាជនកម្ពុជាចាប់អារម្មណ៍ថា

25 Oxfam America, "Understanding Public Perception of Climate Change in Cambodia", p 19, 2011

26 Oxfam America, "Understanding Public Perception of Climate Change in Cambodia", p. 12, 2011

ការប្រែប្រួលទាំងនេះនៃរបបធាតុអាកាសមានផលប៉ះពាល់អវិជ្ជមានមកលើសមត្ថភាពរបស់ពួកគេក្នុងការលើកកំពស់មុខរបរប្រចាំថ្ងៃរបស់ខ្លួន។[27]

លើសពីនេះ ពួកគេយល់ឃើញពាក្យនេះថា ទាក់ទងនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅក្នុងមូលដ្ឋានរបស់ខ្លួនជាងជាបញ្ហាដែលទាក់ទងនឹងមូលហេតុនៅកម្រិតសកល។[28] នៅពេលសួរនៅក្នុងការសិក្សា KAP អំពីមូលហេតុនៃការប្រែប្រួលអាកាសធាតុមានតែអ្នកឆ្លើយប្រមាណ១៥% ដែលបានឆ្លើយថាពួកគេបានយល់អំពីពាក្យនេះដោយកត់សំគាល់អំពីការអភិវឌ្ឍឧស្សាហកម្ម ជាមូលហេតុផ្ទុយនឹងការបាត់បង់ព្រៃឈើដែលអ្នកឆ្លើយ៥៧% ចាត់ទុកថាជាមូលហេតុ។[29] ផ្អែកលើចំណុចនេះ និងចម្លើយដទៃទៀតនៅក្នុងការសិក្សា KAP ការសិក្សានេះបានសន្និដ្ឋានថាអ្នកឆ្លើយទំនងជាឲ្យនិយមន័យពាក្យនេះធៀបនឹងព្រឹត្តិការណ៍ធាតុអាកាសនៅមូលដ្ឋាន និងការប្រែប្រួលធនធានធម្មជាតិនៅក្នុងមូលដ្ឋានរបស់ខ្លួនជាងជាផលប៉ះពាល់និងមូលហេតុនៅថ្នាក់ជាតិ និងអន្តរជាតិ។

## ព័ត៌មានអំពីការប្រែប្រួលអាកាសធាតុ

ដូចដែលបានកំណត់ពីខាងដើមគេចាំបាច់ត្រូវកំណត់និយមន័យយុទ្ធសាស្ត្រដោះទ័ល ដែលគ្រប់គ្រាន់និងដែលមាននិរន្តរភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុដោយផ្អែកលើព័ត៌មានត្រឹមត្រូវ។ ទោះជាយ៉ាងណាក៏ដោយព័ត៌មានអំពីការប្រែប្រួលអាកាសធាតុ ដែលសាធារណជនបានទទួលជាទូទៅមានកម្រិតកំណត់។ លើសពីនេះនៅក្នុងព័ត៌មាន ដែលផ្តល់ឲ្យសារធារណជនទំនងជាមានភាពខ្វះចន្លោះរវាងការយល់ឃើញរបស់សាធារណជនអំពីខ្លឹមសារនៃពាក្យប្រែប្រួលអាកាសធាតុ និងខ្លឹមសារដែលមានការឲ្យនិយមន័យតាមបច្ចេកទេសពីអ្នកជំនាញប្រែប្រួលអាកាសធាតុនិងមន្ត្រីរដ្ឋាភិបាល។[30]

ដោយសារតែមូលហេតុដូចគ្នានេះឯកសារជាច្រើនស្តីពីការប្រែប្រួលអាកាសធាតុនៅកម្ពុជាក៏បានផ្តោតផងដែរលើបញ្ហានេះ។ដូចគ្នានេះដែរមានការឯកភាពមតិជាច្រើននៅក្នុងឯកសារដូចនៅក្នុងការសិក្សា KAPផងដែរ។[31] គេឃើញមានកង្វះខាតយ៉ាងធ្ងន់ធ្ងរនូវព័ត៌មានជាផ្លូវការពីអាជ្ញាធរកម្ពុជាដែលទាក់ទងនឹងមុខសញ្ញាគ្រោះថ្នាក់ធាតុអាកាស និងអំពីខ្លឹមសារជារួមនៃការប្រែប្រួលអាកាសធាតុផងដែរ។ ការស្រាវជ្រាវដែលមានស្រាប់បានបង្ហាញថា ក្នុងចំណោមអ្នកឆ្លើយទាំងនោះ ដែលបានជួបប្រទះធាតុអាកាសមិនប្រក្រតី ៣៦% មិនបានទទួលព័ត៌មានណាមួយអំពីព្រឹត្តិការណ៍ធាតុអាកាសមិនប្រក្រតីឡើយ និងមានតែ៣៥% នៃអ្នកទាំងនោះដែលបានទទួលព័ត៌មានមុនព្រឹត្តិការណ៍នោះកើតឡើង។[32]

ព័ត៌មានភាគច្រើនដែលផ្តល់ទៅឲ្យអ្នកឆ្លើយនៅក្នុងតំបន់រងគ្រោះ ត្រូវបានផ្តល់តាមរយៈមធ្យោបាយមិនផ្លូវការ (តាមការនិយាយតគ្នា) និងវិទ្យុនិងទូរទស្សន៍។ ការសិក្សា KAP នៅថ្នាក់ជាតិបានបង្ហាញថាអ្នកឆ្លើយ ៣% បានបង្ហាញថាពួកគេបានទទួលព័ត៌មានអំពីការប្រែប្រួលអាកាសធាតុពីអាជ្ញាធរ (ដែលរួមទាំងក្រុម

27 IBID, p. 29, 2011

28 IBID p 20, 2011

29 IBID, p. 20, 2011

30 IBID, p. 2, 2011

31 IBID, p. 15, 2011

32 Oxfam America, ”Understanding Public Perception of Climate Change in Cambodia”, p 13, 2011

ប្រឹក្សាឃុំនិងប្រធានភូមិ)។ ម៉្យាងវិញទៀតអ្នកឆ្លើយ ៥០% បានបញ្ជាក់ថាពួកគេបានទទួលព័ត៌មានអំពីការប្រែប្រួលអាកាសធាតុពីអ្នកជិតខាង៥៨% ពីវិទ្យុ និង ៦២% ពីទូរទស្សន៍។[33]

## យុទ្ធសាស្ត្រដោះទ័លនៅខេត្តកោះកុង និងខេត្តព្រះសីហនុ

វេទិកាចំណេះដឹងអំពីការបន្សាំបានធ្វើការសិក្សាមួយប្រហែលគ្នានឹងការសិក្សានេះ នៅក្នុងឆ្នាំ២០១០ នៅក្នុងឃុំគោលដៅចំនួនពីរ (ព្រៃនប់និងមណ្ឌលសីមា)។ ដោយសារតែភាពស្រដៀងគ្នានៃការស្រាវជ្រាវនេះ សេចក្ដីសង្ខេបមួយនៃការស្រាវជ្រាវពីវេទិកាចំណេះដឹងអំពីការបន្សាំមានផ្ដល់ជូនខាងក្រោម។

របាយការណ៍*ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ៖ ការស្វែងរកវិធានការឆ្លើយតបសមស្រប*ពីវេទិកាចំណេះដឹងអំពីការបន្សាំបានផ្អែកលើឧបករណ៍ចំនួន ៦ សម្រាប់ការអង្កេតតាមបែបផែននៃការចូលរួមនៅក្នុងការស្រាវជ្រាវដែលឧបករណ៍ទាំងអស់នោះត្រូវបានយកមកអនុវត្តនៅក្នុងឃុំទាំងពីរនេះ។

យើងស្នើឲ្យអានរបាយការណ៍ពីវេទិកាចំណេះដឹងអំពីការបន្សាំ។ របាយការណ៍នេះ មានសម្រាប់ចម្លងពីវេបសាយដូចខាងក្រោម៖ http://www.climateadapt.asia/resources/publication/view/60

ការយកចិត្តទុកដាក់គួរតែផ្ដោតលើឧបសម្ព័ន្ធ១និង២។

### ខេត្តកោះកុង - ឃុំពាមក្រសោប និងទួលគរគី

យោងតាមឯកសារដែលមានស្រាប់សហគមន៍ពាមក្រសោប និងកោះកុងបានឃើញការប្រែប្រួលបរិស្ថានជាបន្តបន្ទាប់។ ការប្រែប្រួលទាំងនោះខ្លះៗគឺ៖

- កំណើនខ្យល់ព្យុះនៅតំបន់ឆ្នេរ
- គ្រោះរាំងស្ងួតដោយសារទឹកភ្លៀងធ្លាក់តិចជាងមុននៅក្នុងរដូវវស្សា
- ការជ្រាបចូលនៃទឹកប្រៃ
- ជម្ងឺនៅលើសត្វដែលរស់ក្នុងសមុទ្រ
- ទឹកអណ្ដូង/ទឹកក្រោមដីមិនអាចផឹកបានដូចមុន

ក្នុងចំណោមបញ្ហាដទៃទៀត ការប្រែប្រួលទាំងនេះ បាននាំឲ្យមានការចំណាយខ្ពស់លើទឹកសម្រាប់ផឹកក្នុងចំណោមអ្នកភូមិនិងជាលទ្ធផលពួកគេនៅសល់ប្រាក់តិចជាងមុនសម្រាប់ពង្រីកមុខរបរ។

មុខរបររបស់ពួកគេបានប្ដូរពីការដាំដំណាំទៅប្រមូលផលពីសមុទ្រ ដែលនាំឲ្យមានកំណើនសម្ពាធមកលើធនធានធម្មជាតិ។ សម្ពាធមកលើការរស់ក្នុងសមុទ្រ ក៏បានបង្កឲ្យមានកំណើនការចំណាយលើឧបករណ៍នេសាទផងដែរ ដូចជានៅភូមិពាមក្រសោមដែលអ្នកភូមិបានបង្កើនប្រវែងមងរបស់ខ្លួនទ្វេដង និងចំនួនលបក្ដាមរបស់ពួកគេចំនួន៥ដង។

ក្រៅពីពិភាក្សាអំពីការប្រែប្រួលបរិស្ថានជាបន្តបន្ទាប់របាយការណ៍នេះ ក៏ពិនិត្យមើលផងដែរនូវការយល់ឃើញរបស់សហគមន៍ អំពីការប្រែប្រួលនៃប្រព័ន្ធអេកូឡូស៊ីមូលហេតុនៃការប្រែប្រួល និងយុទ្ធសាស្ត្រដោះទ័ល ណាខ្លះដែលមានប្រើប្រាស់។ ការយល់ឃើញ អំពីការប្រែប្រួលទាំងនេះ មានពិភាក្សាដូចខាងក្រោម។

33 IBID p 21, 2011

### *ឃុំពាមក្រសោប*

សម្រាប់ការយល់ឃើញរបស់អ្នកភូមិពាមក្រសោប ការប្រែប្រួលប្រព័ន្ធអេកូឡូស៊ីដែលពួកគេបានឃើញ គឺការថយចុះនៃភាវរស់ក្នុងសមុទ្រ។ អ្នកភូមិបានកត់សំគាល់ អំពីការខកខានមិនបានអនុវត្តច្បាប់ដែលហាមឃាត់ការនេសាទដោយ "អ្នកមកពីខាងក្រៅ" ថាជាមូលហេតុដែលបង្កឲ្យមានសម្ពាធដែលគ្មាននិរន្តរភាពមកលើភាវរស់ក្នុងសមុទ្រ។ លើសពីនេះ ការបូមខ្សាច់ក៏ត្រូវបានកត់សំគាល់ថាជាមូលហេតុ នៃការប្រែប្រួលប្រព័ន្ធអេកូឡូស៊ីផងដែរ។

អ្នកភូមិចាប់អារម្មណ៍ឃើញមានការកែលម្អលើការពង្រឹងការអនុវត្តច្បាប់ដែលការពារព្រៃកោងកាង។

ដោយសារតែអ្នកភូមិពាមក្រសោបបានប្តូរទីកន្លែងពីដីកោះមកដីគោក ឥឡូវនេះ អ្នកភូមិមានលទ្ធភាពក្នុងការដាំដំណាំលើដីក្រោយផ្ទះដែលអាចឲ្យពួកគេអាចដាំឈើហូបផ្លែ និងបន្លែ។ ទោះជាយ៉ាងណាក៏ដោយ អវត្តមានទឹកសាបកំហិតលើផលិតភាព នៃដំណាំនៅក្រោយផ្ទះរបស់ពួកគេ។

ការប្រែប្រួលវិជ្ជមានខ្លាំងមួយសម្រាប់អ្នកភូមិគឺការពង្រីកអេកូទេសចរណ៍។ ដោយសារកំណើនការយល់ដឹងពីលទ្ធភាពអេកូទេសចរណ៍អ្នកភូមិបានចាត់ចែងខ្លួនឯង ដែលឥឡូវនេះទេសចរណ៍បានក្លាយជាប្រភពប្រាក់ចំណូលនៅជិតភូមិជំនួសការធ្វើចំណាកស្រុកដូចពីមុន ដើម្បីស្វែងរកប្រភពប្រាក់ចំណូលជំនួស។

នៅពាមក្រសោបអ្នកភូមិមានយុទ្ធសាស្ត្រដោះទ័លមួយចំនួន សម្រាប់ករណីនៃមុខសញ្ញាគ្រោះថ្នាក់ជាតុអាកាសខុសៗគ្នា។ អ្នកភូមិពាមក្រសោបបានចាប់ផ្តើមសង់ផ្ទះទាបជាងមុនដែលមិនសូវខូចខាតនៅពេលមានព្យុះ។ សម្រាប់មូលហេតុដូចគ្នានេះពួកគេបានដាំដើមឈើដើម្បីការពារផ្ទះ។ លើសពីនេះពួកគេបានទទួលម្លប់នៅក្នុងអំឡុងពេលនៃថ្ងៃក្តៅដែលមានចំនួនកាន់តែកើនឡើងផងដែរ។ លើសពីនេះ មានការសង់ទំនប់ដើម្បីការពារភូមិពីទឹកជំនន់ទោះជាយ៉ាងណាក៏ដោយ ទំនប់នេះមិនមានកំពស់គ្រប់គ្រាន់ដើម្បីទប់ទល់នឹងជំនន់ខ្លាំងនោះឡើយ។

### *ឃុំទួលគរគី*

ឃុំទួលគរគីមានទីតាំងចូលជ្រៅក្នុងដែនគោកជាងនៅពាមក្រសោប ហើយអ្នកភូមិនៅតាចាតបានឃើញការថយចុះយ៉ាងខ្លាំង នៃលទ្ធភាពរបស់ខ្លួនក្នុងការទទួលបានទឹកសាបការរីកស្ងួត នៃប្រភពទឹកសាបប្រចាំឆ្នាំរបស់ពួកគេ។

ការថយចុះនេះនាំមកនូវផលវិបាកមួយចំនួន។ យោងតាមអ្នកភូមិភាវរស់ក្នុងទឹកសាបបានថយចុះជាខ្លាំងដោយសារតែភាពឆ្លាស់គ្នារវាងទឹកសាបនិងទឹកប្រៃលែងទៀងទាត់ដូចមុន។ ឥឡូវនេះ វដ្តទឹកមានរយៈពេលខ្លីជាងមុនសម្រាប់វត្តមានទឹកសាបដោយសារតែគ្រោះរាំងស្ងួតដែលកើតមានកាន់តែញឹកញាប់។ អ្នកភូមិយល់ថាការថយចុះ នៃទឹកសាបជាផលវិបាកមួយ នៃការបាត់បង់ព្រៃឈើនៅក្នុងតំបន់ជិតៗបឹង និងស្ទឹងទឹកសាប។

សម្រាប់ភូមិតាចាត ព្រៃកោងកាងបានបាត់បង់ជាទ្រង់ទ្រាយធំដោយសារតែក្រុមហ៊ុនសម្បទានជាច្រើន។ ទោះជាយ៉ាងណាក៏ដោយអ្នកភូមិខ្លួនឯងក៏ចូលរួមក្នុងការធ្វើឲ្យបាត់បង់ព្រៃកោងកាងផងដែរ ដែលជាផ្នែកមួយនៃការផលិតធ្យូង។ លើសពីនេះ អ្នកភូមិប្រើប្រាស់បច្ចេកទេសកសិកម្មពនេចរដើម្បីយកដីសម្រាប់ធ្វើកសិកម្ម។

ដើម្បីទប់ទល់ចំពោះមុខសញ្ញាគ្រោះថ្នាក់ជាតុអាកាស និងតាមរយៈការគាំទ្រជាហិរញ្ញវត្ថុពីកម្មីមីក្រូហិរញ្ញវត្ថុអ្នកភូមិតាចាតបានជីកស្រះ ដើម្បីរក្សាទឹកសម្រាប់ដំណាំនិងសត្វនៅក្នុងរដូវរាំងស្ងួត។ ចំពោះករណីនៃការហូរច្រោះនៅក្នុងរដូវវស្សា និងតាមរយៈវគ្គបណ្តុះបណ្តាលអំពីបច្ចេកវិទ្យាកសិកម្មអ្នកភូមិបានចាប់ផ្តើមប្រើប្រាស់ជីគីមីនិងថ្នាំកំចាត់សត្វចង្រៃដើម្បីបង្កើនផលិតផលដំណាំ។ លើសពីនេះ អ្នកភូមិក៏បានចាប់ផ្តើមនេសាទផងដែរដើម្បីបំពេញការខ្វះខាតអាហារ។

## ខេត្តព្រះសីហនុ – ឃុំព្រៃនប់ និងអូរឧកញ៉ាហេង

ដូចនៅកោះកុងដែរឃុំព្រៃនប់ និងអូរឧកញ៉ាហេង បានឃើញការប្រែប្រួលមួយចំនួនខាងបរិស្ថាន ជាបន្តបន្ទាប់ដែលរួមមាន៖

- រដូវវស្សាមានរយៈពេលវែងជាងមុន
- ភ្លៀងខ្លាំងនៅក្នុងរដូវវស្សា
- បញ្ហាខាងសុខភាពសត្វដោយសារតែក្តៅជាងមុន
- ប្រព័ន្ធអេកូឡូស៊ីរួមចំណែកតិចជាងមុននៅក្នុងសន្តិសុខស្បៀង
- ការថយចុះជីជាតិដី

ជាផលវិបាកពីផលប៉ះពាល់ទាំងនេះ កសិករត្រូវបានបង្ខំចិត្តបង្កើនការប្រើប្រាស់ថ្នាំកំចាត់កត្តាចង្រៃ ថ្នាំកំចាត់ស្មៅ និងជីគីមី។ ការប្រែប្រួលមួយទៀត គឺថាកសិករត្រូវបង្ខំចិត្តប្តូរទៅទាញយកផលពីធនធានធម្មជាតិដទៃទៀត។

សម្ពាធមកលើផលស្តុកក្នុងសមុទ្របន្តឈានហួសកម្រិតនិរន្តរភាព។ បឹងនានាបានចាប់ផ្តើមស្ថិតក្រោមសម្ពាធពីកំណើនចំនួនគ្រួសារ ដែលព្យាយាមធ្វើការនេសាទនៅតាមបឹង ដើម្បីជំនួសការបាត់បង់ក្នុងមុខរបររបស់ពួកគេ។ អ្នកភូមិក៏កត់សំគាល់ថាផលវិបាកបន្ថែមផងដែរ ពោលគឺការបាត់បង់សាមគ្គីភាពនៅក្នុងឃុំ ដោយសារកំណើនភាពប្រកួតប្រជែង ដើម្បីទទួលបានធនធាន។

គ្មានអ្នកភូមិណាម្នាក់ចូលរួមនៅក្នុងសកម្មភាពអភិវឌ្ឍន៍ណាមួយឡើយនៅក្នុងតំបន់នេះ។

### *ឃុំព្រៃនប់*

ភូមិបឹងក្រាំងក្នុងឃុំព្រៃនប់មានយុទ្ធសាស្ត្រដោះទ័លមួយចំនួនកំពុងអនុវត្ត។ ក្នុងករណីមានទឹកជំនន់ដែលកើតមាន២ទៅ៣ដងក្នុងមួយឆ្នាំអ្នកភូមិបើកទ្វារទឹកនៃទំនប់ ដើម្បីបន្ទាបកម្រិតកំពស់ទឹកជំនន់។ ទោះជាយ៉ាងណាក៏ដោយការធ្វើបែបនេះមានផលអវិជ្ជមានមួយមកលើបរិមាណទឹកសម្រាប់កសិកម្ម។

អ្នកភូមិបានដឹងអំពីហានិភ័យខាងសុខភាពដែលពាក់ព័ន្ធជាមួយទឹកជំនន់។ ដូច្នេះនៅក្រោយមានទឹកជំនន់អ្នកភូមិត្រូវតែសំអាតទីជុំវិញផ្ទះភ្លាមៗនៅក្រោយទឹកជំនន់ស្រកផុត។

គ្មានយុទ្ធសាស្ត្រណាមួយរបស់អ្នកភូមិត្រូវបានមើលឃើញថាជាយុទ្ធសាស្ត្រដោះទ័ល ដែលមាននិរន្តរភាពឡើយ ហើយពួកគេនៅតែប្រឈមការបាត់បង់នៅពេលមានជំនន់កើតឡើង។

## ការប្រមូលទិន្នន័យ

ដូចដែលបានកត់សំគាល់ពីខាងដើម ក្រៅពីការពិនិត្យមើលឯកសារដែលមានស្រាប់របាយការណ៍នេះក៏បានផ្តែកលើការប្រមូលទិន្នន័យនៅខេត្តកោះកុងពនិងព្រះសីហនុផងដែរ។ ផ្នែកនេះនឹងបង្ហាញអំពីទិន្នន័យដែលប្រមូលបាន។

## ខេត្តកោះកុង

នៅកោះកុង ការប្រមូលទិន្នន័យបានធ្វើឡើងនៅក្នុងស្រុកមណ្ឌលសីមា។ បញ្ជីសំណួរសរុបចំនួន ១១៤ ត្រូវបានប្រើប្រាស់នៅក្នុងការសម្ភាសអ្នកឆ្លើយ និងបន្ទាប់មកបញ្ចូលទៅក្នុងតារាងអិចសែល។ ការពិភាក្សាជាក្រុមចំនួនបួនជាមួយគណៈកម្មការសហគមន៍ និងការពិភាក្សាជាក្រុមចំនួនបួនជាមួយក្រុមប្រឹក្សាឃុំក៏បានធ្វើឡើងផងដែរ។ ទិន្នន័យដែលប្រមូលបាននៅក្នុងភូមិចំនួន៦គឺបឹងកាយ៉ាកកោះកាងពាមក្រសោប (ភូមិ១ និង២) ទួលគរគីនិងតាចាត។

## បញ្ជីសំណួរ

ក្នុងចំណោមអ្នកឆ្លើយចំនួន១១៤នាក់៦៦នាក់គឺជាស្ត្រីនិង៤៨នាក់ជាបុរស។

មូលហេតុដែលអ្នកឆ្លើយភាគច្រើនជាស្ត្រី គឺបុរសភាគច្រើនជាប់រវល់នៅឯស្រែឬនៅសមុទ្រចំណែកទិន្នន័យត្រូវបានប្រមូលនៅក្នុងពេលថ្ងៃដូចមានពន្យល់នៅក្នុងផ្នែក "ដែនកំណត់"។

អ្នកឆ្លើយ៦៧% មានរបរចិញ្ចឹមជីវិតដែលផ្អែកលើការនេសាទនិងមានតែ១៨% ដែលផ្អែកលើការដាំដំណាំ។អ្នកក្រៅពីនេះប្រកបរបរនៅក្នុងផ្នែកខុសៗគ្នានិងជាអ្នកលក់របស់តិចតួចជាងកាត់សម្លៀកបំពាក់។ល។ មុខរបរប្រភេទនេះ ត្រូវបានរំពឹងថានឹងផ្អែកលើស្ថានភាពនៅក្នុងសហគមន៍គោលដៅដែលមានពន្យល់នៅខាងដើមដោយបានអធិប្បាយសហគមន៍នេះថាភាគច្រើនមានរបរនេសាទ។

គួរកត់សំគាល់ផងដែរថាជំពូក "កសិករ" និង "អ្នកនេសាទ" បានរួមបញ្ចូលផងដែរអ្នកដាំដំណាំតិចតួចនៅតាមទីធ្លាក្រោយផ្ទះនិងការនេសាទជាទ្រង់ទ្រាយតូច។ ដូច្នេះអ្នកឆ្លើយខ្លះចាត់ទុកខ្លួនឯងថាស្ថិតនៅក្នុងជំពូកទាំងពីរនេះ។

អ្នកឆ្លើយ៧% ស្ថិតក្នុងគ្រួសារដែលមានស្ត្រីជាមេគ្រួសារ។

នៅក្នុងបញ្ជីសំណួរអ្នកឆ្លើយក៏បានបង្ហាញពីប្រភពប្រាក់ចំណូលរបស់ខ្លួននៅក្នុងរដូវវស្សា និងរដូវប្រាំងផងដែរ។ សំណួរនេះមានគោលដៅវិភាគថាតើប្រាក់ចំណូលអាចទាក់ទងនឹងសមត្ថភាពរបស់អ្នកឆ្លើយក្នុងការទប់ទល់ចំពោះផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុឬទេ។ ប្រាក់ចំណូលរបស់អ្នកឆ្លើយត្រូវបានចែកជាក្រុមដូចតទៅ៖

ប្រាក់ចំណូលប្រចាំថ្ងៃនៅរដូវវស្សា៖
អ្នកឆ្លើយ១២នាក់ = ១០០០ –៥០០០រៀល
អ្នកឆ្លើយ៣៨នាក់ = ៥០០០ – ១០.០០០រៀល
អ្នកឆ្លើយ៤៣នាក់ = ១០.០០០_____ រៀល
អ្នកឆ្លើយ២១នាក់ = មិនផ្តល់ចម្លើយ
មូលដ្ឋាន៖អ្នកឆ្លើយទាំងអស់

ប្រាក់ចំណូលប្រចាំថ្ងៃនៅរដូវប្រាំង៖
អ្នកឆ្លើយ៤នាក់ = ១០០០ –៥០០០រៀល
អ្នកឆ្លើយ៣១នាក់ = ៥០០០ – ១០.០០០រៀល
អ្នកឆ្លើយ៦៩នាក់ = ១០.០០០_____ រៀល
អ្នកឆ្លើយ១០នាក់ = មិនផ្តល់ចម្លើយ
មូលដ្ឋាន៖អ្នកឆ្លើយទាំងអស់

ជារួមតួលេខទាំងនេះបង្ហាញថាអ្នកឆ្លើយមានប្រាក់ចំណូលនៅរដូវប្រាំងខ្ពស់ជាងនៅរដូវវស្សា។ ផ្អែកតាមទិន្នន័យនេះទោះបីមិនសមស្របសម្រាប់ការវិភាគបន្ថែមទៀតក៏ដោយទាក់ទងនឹងមូលហេតុលទ្ធផលស្តែងចេញមកបែបនេះក៏ទំនងជាសមរម្យដែរ។ ទោះជាយ៉ាងណាក៏ដោយ សញ្ញាណសមស្របមួយដែលគួរកត់សំគាល់ផងដែរគឺរដូវប្រាំងក៏ជារដូវដែលមានភ្ញៀវទេសចរច្រើនផងដែរនៅពាមក្រសោប ដូច្នេះបង្កើតឱកាសសម្រាប់ប្រាក់ចំណូលក្នុងសហគមន៍។

*ការយល់ឃើញ*

ជាទូទៅទិន្នន័យដែលប្រមូលបានដែលជាផ្នែកមួយនៃប្រធានបទ "ការយល់ឃើញ" មានភាពស្របគ្នាជាមួយការសង្កេតផ្សេងទៀតលើប្រធានបទនេះ។ ទោះជាយ៉ាងណាក៏ដោយគេត្រូវគិតបញ្ចូលផងដែរនូវភាពខុសគ្នាដោយធម្មជាតិនៅក្នុងចម្លើយពីសហគមន៍តំបន់ឆ្នេរមួយនិងសហគមន៍ដែនគោកមួយផងដែរដោយសារតែភាពខុសគ្នានៃប្រព័ន្ធអេកូឡូស៊ីនៅជុំវិញពួកគេ។

អ្នកឆ្លើយ ៩៧% បានឆ្លើយតបនឹងសំណួរ១ ដែលពួកគេបានកត់សំគាល់អំពីការប្រែប្រួលរបបធាតុអាកាសក្នុងរយៈពេល៥ឆ្នាំកន្លងមក។

ក្នុងចំណោមផលវិបាកដែលពួកគេយល់ថាកើតចេញពីការប្រែប្រួលធាតុអាកាសទាំងនេះចម្លើយរបស់ពួកគេត្រូវបានចែកចេញជាជំពូកខុសៗគ្នាដូចតទៅ៖

សំណួរ២អំពី "ការយល់ឃើញអំពីការប្រែប្រួលអាកាសធាតុ"
"បើស្រប (សំណួរ១) ផលវិបាកអ្វីខ្លះដែលបង្កដោយការប្រែប្រួលនេះ?"

- ការប្រែប្រួលកំពស់ទឹកភ្លៀង ៨៤%
- ការប្រែប្រួលសីតុណ្ហភាព ៥៤%
- រាំងស្ងួតជាងមុន ១៦%
- ទឹកជំនន់ច្រើនជាងមុន ២៧%
- ខ្យល់ព្យុះច្រើនជាងមុន ៧៤%
- ការជ្រាបចូលនៃទឹកប្រៃច្រើនជាងមុន ៨៤%
- សត្វចង្រៃបំផ្លាញដំណាំកសិកម្ម ២៤%

មូលដ្ឋាន = អ្នកឆ្លើយទាំងអស់ អាចមានចម្លើយច្រើន

ចម្លើយគឺជាការគូសបញ្ជាក់អំពីអ្វីដែលអាចរំពឹងទុករបស់សហគមន៍តំបន់ឆ្នេរនៅកម្ពុជា។ ការប្រៀបធៀបទិន្នន័យនេះជាមួយទិន្នន័យដែលបានពីការសិក្សា KAP នៅទូទាំងប្រទេស "ការស្វែងយល់ពីទស្សនៈរបស់សាធារណជនអំពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា" ជាការច្បាស់ណាស់ ដែលថាសហគមន៍តំបន់ឆ្នេរយល់ថាផលវិបាកនៃការប្រែប្រួលធាតុអាកាសមានភាពខុសគ្នាមួយកម្រិតពីសាធារណជននៅទូទាំងប្រទេស។ ឧទាហរណ៍មួយគឺជំពូក"រាំងស្ងួតជាងមុន" មានតែ១៦% ដែលចាត់ទុកថាចំណុចនេះជាផលវិបាកនៅខេត្តកោះកុងធៀបនឹង៣៦% នៃចម្លើយ "រាំងស្ងួតជាងមុន" នៅក្នុងការសិក្សា KAP។[34] ដូចគ្នានេះដែរតួលេខនេះអាចជាភាពខុសគ្នាដោយស្វ័យប្រវត្តិរវាងសហគមន៍ដីគោកនិងសហគមន៍តំបន់ឆ្នេរ។

អ្នកឆ្លើយក៏បានបញ្ជាក់ផងដែរនូវភាពខុសគ្នានៃឥទ្ធិពលអវិជ្ជមានពីការប្រែប្រួលរបបធាតុអាកាសមកលើរបរចិញ្ចឹមជីវិតរបស់ពួកគេ។ការយល់ស្របគ្នាចំពោះចម្លើយនេះមានដូចតទៅ។

សំណួរ៣ "ទស្សនៈអំពីការប្រែប្រួលអាកាសធាតុ"
"តើផលវិបាកដូចខាងក្រោមនេះមានការប៉ះពាល់មកលើការចិញ្ចឹមជីវិតរបស់អ្នកឬទេ?"

- មុខរបរ៧៦%
- ប្រាក់ចំណូល៨៨%
- សុខភាព៦១%

មូលដ្ឋាន = អ្នកឆ្លើយទាំងអស់ អាចមានចម្លើយច្រើន

ចម្លើយទាំងនេះបង្ហាញច្បាស់ណាស់ថាអ្នកឆ្លើយយល់ថា ការប្រែប្រួលរបបធាតុអាកាសមានឥទ្ធិពលអវិជ្ជមានមកលើជីវិតរបស់ពួកគេ។

នៅក្នុងការស្វែងយល់អំពីទស្សនៈរបស់សាធារណជនអំពីការប្រែប្រួលអាកាសធាតុនៅកម្ពុជាសេចក្តីសន្និដ្ឋានគឺថា ប្រជាជនយល់ថាការប្រែប្រួលអាកាសធាតុ គឺជាការប្រែប្រួលឬផលប៉ះពាល់នៅមូលដ្ឋាន។ សាធារណជនមិនមានការយល់ឃើញថាការប្រែប្រួលអាកាសធាតុ គឺជាបាតុភូតសកលឡើយនៅពេលនិយាយអំពីមូលហេតុនិងផលវិបាក។ ការសន្និដ្ឋានបែបនេះក៏មានការគាំទ្រផងដែរដោយការប្រមូលទិន្នន័យនៅខេត្តកោះកុង។ នៅក្នុងការឆ្លើយតបទៅនឹងសំណួរអំពីអ្វីដែលអ្នកឆ្លើយយល់ថាជាមូលហេតុចំបងនៃការប្រែប្រួលរបបធាតុអាកាសចម្លើយមានដូចខាងក្រោម៖

សំណួរ៤ "ការយល់ឃើញអំពីការប្រែប្រួលអាកាសធាតុ"
"តើអ្នកគិតថាអ្វីជាមូលហេតុនៃការប្រែប្រួលរបបធាតុអាកាស?"

- ការបាត់បង់ព្រៃឈើ ៥០%
- ឥទ្ធិពលនៅកម្រិតជាតិ ៤៦%
- ឥទ្ធិពលអន្តរជាតិ ៣៧%

មូលដ្ឋាន = ទាំងអស់ ចម្លើយច្រើន

34Oxfam America, "Understanding Public Perception of Climate Change in Cambodia", p 26, 2011

គួរចាប់អារម្មណ៍ផងដែរថាប្រសិនបើមូលដ្ឋាននៃអ្នកដែលឆ្លើយអំពី "ការបាត់បង់ព្រៃឈើ" ត្រូវបានចែកចេញបន្តជាជំពូករងតាមមុខរបរគេអាចឃើញនិន្នាការជាបន្ថែមដូចខាងក្រោម។

| | |
|---|---|
| សំណួរ៤ "ទស្សនៈអំពីការប្រែប្រួលអាកាសធាតុ" | |
| • ការបាត់បង់ព្រៃឈើ | |
| ○ កសិករ | ១០០% |
| ○ អ្នកនេសាទ | ៤៩% |
| មូលដ្ឋាន = "កសិករ" & "អ្នកនេសាទ" | |

យើងអាចពន្យល់បានថា កសិករភ្ជាប់ទំនាក់ទំនងនេះជាមួយនៃការប្រែប្រួលបរិស្ថានការងាររបស់ពួកគេនៅក្នុងមូលដ្ឋានពោលគឺវាលស្រែនិងមជ្ឈដ្ឋានជុំវិញរបស់ពួកគេ។

លើសពីនេះ អ្នកឆ្លើយជាច្រើនដែលជាអ្នកនេសាទបានកត់សំគាល់ថាការបូមយកខ្សាច់ជាមូលហេតុនៃការប្រែប្រួលនេះ។ ដូចគ្នានេះដែរចំណុចនេះអាចពន្យល់បានតាមរយៈប្រការដែលថាអ្នកនេសាទបានឃើញការបូមខ្សាច់នៅតាមឆ្នេរសមុទ្រ។

ជាទូទៅការបូមខ្សាច់ គឺជាកង្វល់រួមរបស់អ្នកឆ្លើយជាច្រើននៅកោះកុង ហើយទិន្នន័យនៅក្នុងបញ្ជីសំណួរក៏មិនបានឆ្លុះបញ្ចាំងពេញលេញផងដែរដោយសារតែវិធីនៃការចាត់ចែងបញ្ជីសំណួរនោះ។ នៅពេលរៀបចំបញ្ជីសំណួរមិនមានការបញ្ចូលប្រធានបទនៃការបូមខ្សាច់ឲ្យបានជាក់លាក់ឡើយដោយសារមិនត្រូវបានយល់ថាជាមូលហេតុនៃការប្រែប្រួលអាកាសធាតុ។ ដូច្នេះ ប្រធានបទនេះត្រូវបានលើកឡើងទៅតាមការស្នើឡើងរបស់អ្នកឆ្លើយផ្ទាល់ដែលអាចអះអាងថាជាការបង្កើតមូលដ្ឋានសម្រាប់បញ្ហា ដែលបានបញ្ចូលក្នុងបញ្ជីសំណួរ នេះ។

### *ព័ត៌មាន*

នៅពេលនិយាយអំពីពាក្យ "ការប្រែប្រួលអាកាសធាតុ" អ្នកឆ្លើយ៧១% បានបង្ហាញថាពួកគេបានឮពាក្យនេះពីមុនមក។តួលេខនេះមានទាបជាងបន្តិចធៀបនឹងតួលេខនៅក្នុងការសិក្សា KAP ដែលមានដល់ ៨៤%។[35]

តួលេខនេះមានកម្រិតខ្ពស់បង្គួរដោយសារមានតែអ្នកឆ្លើយ ២៥% បានចូលរួមនៅក្នុងការបង្កើនការយល់ដឹងនៅក្នុងសហគមន៍។

ទិន្នន័យនេះបង្ហាញថាការប្រែប្រួលអាកាសធាតុ គឺជាប្រធានបទមួយដែលជាទូទៅគឺជាផ្នែកមួយនៃការយល់ដឹងរបស់អ្នកភូមិនៅកោះកុង។

នៅពេលចែកចេញរវាង "បុរស" និង "ស្ត្រី" យើងបានតួលេខដូចខាងក្រោមនេះ៖

35Oxfam America, "Understanding Public Perception of Climate Change in Cambodia", p 19, 2011

សំណួរ២ក "ព័ត៌មាន"
តើអ្នកបានចូលរួមក្នុងសកម្មភាពបង្កើនការយល់ដឹងដែរឬទេ?

| ស្ត្រី (បាន) | បុរស (បាន) |
|---|---|
| ២១ | ៨ |
| ៣២% | ១៧% |

មូលដ្ឋានៈអ្នកឆ្លើយទាំងអស់

ដោយមានតែអ្នកឆ្លើយជាបុរសចំនួន១៧% ដែលបានចូលរួមក្នុងសកម្មភាពបង្កើនការយល់ដឹងធៀបនឹងស្ត្រី៣២% ទិន្នន័យនេះបង្ហាញថារាល់សកម្មភាពបង្កើនការយល់ដឹងត្រូវតែផ្តោតលើការព្យាយាមឲ្យបុរសបានចូលរួម។ នេះពិតជាការលំបាកដោយសារបុរសជាច្រើននៅក្នុងសហគមន៍ត្រូវទៅនេសាទនៅសមុទ្រ ឬនៅតាមវាលស្រែ។ ទោះជាយ៉ាងណាក៏ដោយមានវិធីនានា ដើម្បីជំនះបញ្ហានេះដូចដែលបានពិភាក្សាពីខាងដើម។

លើសពីនេះ គេអាចមើលឃើញថាតួលេខសម្រាប់បុរស និងស្ត្រីនៅមានកម្រិតទាប នៅពេលគិតពីហេតុផលដែលសហគមន៍គោលដៅទាំងនេះធ្លាប់បានចូលរួមក្នុងសកម្មភាពប្រែប្រួលអាកាសធាតុកន្លងមក។

ក្នុងចំណោមអ្នកឆ្លើយ៨នាក់ដែលចាត់ទុកថាជាគ្រួសារដែលមានស្ត្រីជាមេគ្រួសារគ្មានអ្នកណាម្នាក់ក្នុងចំណោមអ្នកទាំងនេះបានចូលរួមក្នុងពិធីបង្កើនការយល់ដឹងពីមុនមកឡើយ។

ប្រធានបទស្នូលមួយសម្រាប់របាយការណ៍នេះគឺការវាយតម្លៃប្រភពព័ត៌មានអំពីមុខសញ្ញាគ្រោះថ្នាក់ធាតុអាកាសដែលអ្នកឆ្លើយបានប្រើប្រាស់និងដែលមានសម្រាប់ពួកគេ។សំណួរ៣នៅក្នុងប្រធានបទនេះ "ព័ត៌មាន" ផ្តល់ជាការចង្អុលបង្ហាញអំពីប្រការនេះ។

សំណួរ៣ "ព័ត៌មាន"
"តើអ្នកបានទទួលព័ត៌មានអំពីមុខសញ្ញាគ្រោះថ្នាក់ធាតុអាកាសនៅក្នុងស្រុករបស់អ្នកដោយរបៀបណានៅ"?

- <u>តាមវិទ្យុ ៧២%</u>
  - វិទ្យុខ្មែរ ៦៥%
  - វិទ្យុថៃ ១៩%
  - វិទ្យុវៀតណាម ២%
- <u>ទូរទស្សន៍ ៤0%</u>
  - ទូរទស្សន៍ខ្មែរ ៣២%
  - ទូរទស្សន៍ថៃ ១២%
  - ទូរទស្សន៍វៀតណាម 0%
- អ្នកជិតខាង ៣៣%
- មន្ត្រីរដ្ឋាភិបាល ២២%

មូលដ្ឋានៈអ្នកឆ្លើយទាំងអស់ អាចមានចម្លើយច្រើន

ផ្អែកតាមទិន្នន័យនេះមានភស្តុតាងបង្ហាញថា វិទ្យុគឺជាប្រភពចំបងនៃព័ត៌មានដែលទាក់ទងនឹងគ្រោះមហន្តរាយធាតុអាកាស។ អ្នកឆ្លើយជាច្រើនបានកត់សំគាល់អំពី *វិទ្យុខ្មែរ* ថា ជាប្រភពព័ត៌មានចំបងរបស់ពួកគេ ដែលទាក់ទងនឹងគ្រោះមហន្តរាយធាតុអាកាស។ ស្ថានភាពដូចគ្នានេះដែរសម្រាប់ទូរទស្សន៍ដោយ *ទូរទស្សន៍ខ្មែរ* ត្រូវបានអ្នកឆ្លើយជាច្រើនកត់សំគាល់ថាជាប្រភពព័ត៌មានដែលពួកគេទទួលបាន។

តួលេខដែលបង្ហាញអំពីព័ត៌មានពី *មន្ត្រីរដ្ឋាភិបាល* មានកម្រិតទាប។ មានតែអ្នកឆ្លើយ២២% ដែលបញ្ជាក់ថាបានទទួលព័ត៌មានពីប្រភពនេះ។ ប្រភពនេះក៏រួមបញ្ចូលផងដែរប្រធានភូមិ និងអាជ្ញាធរឃុំ។ ចំនួននេះបង្ហាញថាពុំមានប្រព័ន្ធចែករម្លែកព័ត៌មាននៅកម្រិតស្ថាប័នឡើយ។ លើសពីនេះអ្នកឆ្លើយត្រូវបានសួរថាតើពួកគេចង់បានទទួលព័ត៌មានពីប្រភពណាដែលទាក់ទងនឹងគ្រោះមហន្តរាយធាតុអាកាស។ ឆ្លើយតបនឹងសំណួរនេះ អ្នកឆ្លើយជាច្រើនបានឲ្យដឹងថាពួកគេចង់បានព័ត៌មានបែបនេះច្រើនបន្ថែមទៀតពីអាជ្ញាធរឃុំ។

ប្រការដែលថានៅមានភាពខ្វះចន្លោះក្នុងការចែករម្លែកព័ត៌មានដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុពីអាជ្ញាធរកម្ពុជាដល់សហគមន៍នៅក្នុងតំបន់ឆ្នេរក៏មានភាពស្របគ្នាជាមួយទិន្នន័យដែលបានពីសំណួរទី៦ផងដែរ។

សំណួរទី៦ "ព័ត៌មាន"
"តើអ្នកដឹងអំពីការងាររបស់រដ្ឋាភិបាលលើការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុឬទេ?"

| ដឹង | មិនដឹង |
|---|---|
| ២២% | ៧៦% |

មូលដ្ឋានៈអ្នកឆ្លើយទាំងអស់

## *យុទ្ធសាស្ត្រដោះទ័ល*

ប្រធានបទចុងក្រោយក្នុងបញ្ជីសំណួរគឺ *យុទ្ធសាស្ត្រដោះទ័ល*។ ដូចដែលបានកត់សំគាល់នៅក្នុងផ្នែក "វិធីសាស្ត្រ" នោះគឺជាការយល់ឃើញរបស់អ្នកឆ្លើយអំពីអ្វីដែលបង្កើតជាយុទ្ធសាស្ត្រដោះទ័ល។ ការយល់ឃើញនេះមិនសុទ្ធតែស្របគ្នាជាមួយនិយមន័យបច្ចេកទេសនៃយុទ្ធសាស្ត្រដោះទ័លឡើយ។

នៅពេលសួរអំពីប្រភេទមុខសញ្ញាគ្រោះមហន្តរាយអាកាសធាតុ ដែលអ្នកឆ្លើយអាចទប់ទល់បាន ចម្លើយដែលបានទទួលទាក់ទងនឹងសមត្ថភាពដើម្បីទប់ទល់គឺៈ

សំណួរ១ "យុទ្ធសាស្រ្តដោះទ័ល"
"នៅក្នុងករណីមុខសញ្ញាគ្រោះថ្នាក់ធាតុអាកាសតើអ្នកមានសមត្ថភាពទប់ទល់ដែរឬទេនៅពេល
វាកើតឡើង ?"

| | |
|---|---|
| • គ្រោះរាំងស្ងួត | ៦% |
| • ទឹកជំនន់ | ១៥% |
| • ខ្យល់ព្យុះ | ៣១% |
| • ការជ្រាបចូលនៃទឹកប្រៃ | ២៥% |
| • សត្វចង្រៃបំផ្លាញដំណាំ | ៨% |
| • គ្មាន | ៤% |
| មូលដ្ឋានៈអ្នកឆ្លើយទាំងអស់ | អាចមានចម្លើយច្រើន |

គេត្រូវយល់ទិន្នន័យនេះដែលទាក់ទងនឹងសំណួរទី២ផងដែរនូវ "ការយល់ឃើញអំពីការប្រែប្រួលអាកាសធាតុ" អំពីមុខសញ្ញាគ្រោះមហន្តរាយអ្វីខ្លះដែលកើតមានញឹកញាប់ជាងមុខសញ្ញាគ្រោះមហន្តរាយដទៃទៀត។

គេក៏ត្រូវគិតផងដែរ អំពីភាពស្មុគស្មាញនៃមុខសញ្ញាគ្រោះមហន្តរាយធាតុអាកាស ដែលអ្នកឆ្លើយត្រូវទប់ទល់។ ចំពោះអ្នកនេសាទវាមិនស្មុគស្មាញខ្លាំងពេកទេក្នុងការទប់ទល់ចំពោះខ្យល់ព្យុះ។ ឲ្យតែអ្នកបានទទួលព័ត៌មានជាមុនអំពីព្យុះ ដែលនឹងកើតឡើងអ្នកមិនចាំបាច់ចេញទៅនេសាទទេ។ ផ្ទុយទៅវិញកសិករធ្លាប់ជួបប្រទះការជ្រាបចូលនៃទឹកប្រៃនៅក្នុងស្រែរបស់ពួកគេដែលជាបញ្ហាស្មុគស្មាញជាងនៅក្នុងការទប់ទល់។

តួលេខដែលទទួលបានមានលក្ខណៈវិជ្ជមានខ្ពស់ជាងបន្តិចបន្តួចធៀបនឹងទិន្នន័យដែលប្រមូលបាននៅក្នុងការសិក្សា KAP។[36]

ដូចដែលបង្ហាញពីខាងដើមអ្នកឆ្លើយត្រូវស្នើសុំឲ្យបញ្ជាក់ពីប្រាក់ចំណូលប្រចាំថ្ងៃរបស់ពួកគេនៅក្នុងរដូវវស្សានិងរដូវប្រាំង។សំណួរនេះមានគោលដៅវិភាគថាតើអាចចាត់ទុកប្រាក់ចំណូលជាកត្តាមួយទាក់ទងនឹងសមត្ថភាពរបស់អ្នកឆ្លើយក្នុងការទប់ទល់នឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុឬទេ។

នៅពេលបែងចែកអ្នកឆ្លើយទៅតាមជំពូកនៃប្រាក់ចំណូលយើងអាចបង្កើតតារាងដូចខាងក្រោមនេះ។ទិន្នន័យនេះបានដកស្រង់ចេញពីជំពូកប្រាក់ចំណូល"ក្នុងរដូវវស្សា"។

សំណួរ១ "យុទ្ធសាស្រ្តដោះទ័ល"
ជំពូកប្រាក់ចំណូលនៅរដូវវស្សា
"ក្នុងករណីគ្រោះមហន្តរាយធាតុអាកាសដូចខាងក្រោមនេះកើតឡើងតើអ្នកមានសមត្ថភាពទប់ទល់ឬទេ ?"

36Oxfam America, "Understanding Public Perception of Climate Change in Cambodia", p 36, 2011

| | ១000-៥000រៀល | ៥000-១0000រៀល | ១0000 – _____ រៀល |
|---|---|---|---|
| គ្រោះរាំងស្ងួត | ៨ % | ១១ % | ៥ % |
| ទឹកជំនន់ | ៣៣ % | ២៩ % | ៤0 % |
| ខ្យល់ព្យុះ | ៤៨ % | ៥៥ % | ៦៧ % |
| ការជ្រាបចូលនៃទឹកប្រៃ | ៥៨ % | ៤៥ % | ៦៧ % |
| សត្វចង្រៃបំផ្លាញដំណាំ | 0 % | ៣៤ % | ១៦ % |
| មូលដ្ឋានៈអ្នកឆ្លើយ អាចមានចម្លើយច្រើន | ១២ | ៣៨ | ៤៣ |

ទិន្នន័យនេះមិនផ្តល់សញ្ញាច្បាស់លាស់អំពីទំនាក់ទំនងរវាងកម្រិតប្រាក់ចំណូលប្រចាំគ្រួសារ និង សមត្ថភាពទប់ទល់នឹងមុខសញ្ញាគ្រោះមហន្តរាយធាតុអាកាសដូចដែលបានបង្ហាញខាងលើឡើយ។ ជាការសន្និដ្ឋានអ្នកឆ្លើយតបដែលមានប្រាក់ចំណូលកាន់តែខ្ពស់មានអារម្មណ៍ថា ខ្លួនមានសមត្ថភាពកាន់តែរឹងមាំក្នុងការទប់ទល់។ ការសន្និដ្ឋាននេះបានផ្អែកលើផលបូកនៃតួលេខក្នុងជំពូកប្រាក់ចំណូលនីមួយៗដែលផ្តល់ពិន្ទុដូចខាងក្រោម។

| កម្រិតប្រាក់ចំណូល | ១000-៥000រៀល | ៥000-១0000រៀល | ១0000 – _____ រៀល |
|---|---|---|---|
| ផលបូក | ១៤៧ | ១៧៤ | ១៩៥ |

ទោះជាយ៉ាងណាក៏ដោយ ដោយសារមូលដ្ឋាននៃអ្នកឆ្លើយសរុបមិនច្រើន ហើយជំពូកនៃប្រាក់ចំណូលបានផ្អែកលើអ្នកឆ្លើយចំនួនត្រឹម១២នាក់ នេះជាការលំបាកក្នុងការសន្និដ្ឋានដែលយកជាការបាន។

នៅក្នុងការពន្យល់ពិស្តារបន្ថែមទៀតអំពីយុទ្ធសាស្រ្តដោះទ័លនេះ អ្នកឆ្លើយបានកត់សំគាល់អំពីយុទ្ធសាស្រ្តដោះទ័លដូចតទៅៈ

សំណួរ១ "ការពន្យល់ពិស្តារ" "យុទ្ធសាស្ត្រដោះទ័ល"
នៅក្នុងករណីគ្រោះមហន្តរាយដូចខាងក្រោមកើតឡើងតើអ្នកមានសមត្ថភាពទប់ទល់ឬទេ (បើមានសូមបញ្ជាក់)?

- សង់ទំនប់តូចៗនៅជុំវិញផ្ទះ
- ទិញទឹកសាប
- ទៅរកភ្នំនៅក្រោយភូមិសម្រាប់ជាទីទួលសុវត្ថិភាព
- ជីកស្រះ
- ត្រៀមទូកសម្រាប់ការភៀសខ្លួន
- ប្រើជីគីមីដើម្បីការពារដំណាំពីសត្វចង្រៃ

មូលដ្ឋានៈអ្នកឆ្លើយទាំងអស់

យុទ្ធសាស្ត្រដោះទ័លទាំងអស់លើកលែងតែការប្រើប្រាស់ថ្នាំគីមី ពុំត្រូវការសមត្ថភាពបច្ចេកទេសកម្រិតខ្ពស់ឡើយ ប៉ុន្តែគឺជាលទ្ធផលដែលបានតាមរយៈមធ្យោបាយដែលអ្នកភូមិមាន។ យុទ្ធសាស្ត្រដោះទ័លទាំងនេះមានពិភាក្សាពិស្តារបន្ថែមទៀត ក្នុងបទបង្ហាញនៃការពិភាក្សាជាក្រុមជាមួយគណៈកម្មការសហគមន៍។

ទោះជាយ៉ាងណាក៏ដោយយុទ្ធសាស្ត្រដោះទ័លទាំងនេះមិនអាចទប់ស្កាត់គ្រួសារនានាពីការជួបប្រឈមនឹងការបាត់បង់ខាងសេដ្ឋកិច្ចឡើយ។ប្រការនេះមានបង្ហាញក្នុងចម្លើយតបនឹងសំណួរទី៣។

សំណួរ៣ "យុទ្ធសាស្ត្រដោះទ័ល"
"នៅពេលគ្រោះមហន្តរាយកើតឡើងកាលពីលើកមុនតើវាបង្កការបាត់បង់ដល់គ្រួសារអ្នកឬទេ?"

| បាត់បង់ | គ្មានទេ |
|---|---|
| ៥៤% | ២៣% |

មូលដ្ឋានៈអ្នកឆ្លើយទាំងអស់

**ការពិភាក្សាជាក្រុម - គណៈកម្មការសហគមន៍នៅ មណ្ឌលសីមា**

តួលេខដែលបង្ហាញខាងលើដែលបានមកពីបញ្ជីសំណួរបង្ហាញឲ្យឃើញពីនិន្នាការនៅក្នុងសហគមន៍គោលដៅនៅក្នុងប្រធានបទចំនួនបីនៃបញ្ជីសំណួរ។ ទោះជាយ៉ាងណាក៏ដោយ បញ្ជីសំណួរនេះមិនផ្តល់ការឆ្លុះបញ្ចាំងពិស្តារអំពីយុទ្ធសាស្ត្រដោះទ័លដែលមានស្រាប់នៅក្នុងសហគមន៍ឡើយ។ ដើម្បីទទួលបានការឆ្លុះបញ្ចាំងនានាទាំងនេះ ការពិភាក្សាជាក្រុមមួយដែលផ្តោតលើយុទ្ធសាស្ត្រដោះទ័លត្រូវបានធ្វើឡើងជាមួយគណៈកម្មការសហគមន៍នៅក្នុងឃុំចំនួន២ពោលគឺពាមក្រសោបនិងទួលគរគី។ ដូចដែលបានកត់សំគាល់នៅក្នុងផ្នែក ស្តីពីវិធីសាស្ត្រការពិភាក្សាជាក្រុមបានផ្អែកលើតារាងម៉ាទ្រិកមួយដែលបានពិភាក្សានិងចែងពន្យល់ពិស្តារ។

ការពិភាក្សាជាក្រុមបានធ្វើឡើងដោយផ្អែកលើប្រភេទនៃមុខសញ្ញាគ្រោះមហន្តរាយ។ ផ្នែកនេះបង្ហាញពីលទ្ធផលចំបងៗពីតារាងម៉ាទ្រិកដែលបានពីការពិភាក្សាជាក្រុម។

ទោះជាយ៉ាងណាក៏ដោយ មានការលើកស្នើថាអ្នកអានគួរតែពិនិត្យមើលតារាងម៉ាទ្រិកនៅក្នុងឧបសម្ព័ន្ធ ដោយសារតារាងម៉ាទ្រិកខ្លះទាំងនោះមានទិន្នន័យបន្ថែម។

*គណៈកម្មការសហគមន៍ពាមក្រសោប*

ដូចដែលអាចឃើញនៅក្នុងឧបសម្ព័ន្ធតារាងម៉ាទ្រិក ត្រូវបានរៀបចំឡើងដោយផ្អែកលើជំពូកខុសគ្នានៃមុខសញ្ញាគ្រោះថ្នាក់ជាតុអាកាសដែលបានពិភាក្សាទាក់ទងនឹងប្រធានបទមួយចំនួន។ ខាងក្រោមនេះគឺសេចក្ដីសង្ខេបនៃរបកគំហើញចំបងៗ និងប្រការសំខាន់បំផុតគឺរបកគំហើញដែលបានពីការពិភាក្សាជាក្រុមជាមួយគណៈកម្មការសហគមន៍ពាមក្រសោប។

*គ្រោះរាំងស្ងួតៈ*

ដើម្បីចាប់ផ្ដើមអនុវត្តសកម្មភាពនៅមុនមានគ្រោះរាំងស្ងួត គណៈកម្មការសហគមន៍បានផ្ដោតលើផ្នែកនានាដូចតទៅៈ (១) ធានាផ្ដល់ប្រភពទឹកសម្រាប់សហគមន៍ដោយសាងសង់អាងសម្រាប់ស្តុកទឹកផឹកនៅក្នុងសហគមន៍ (២) ត្រៀមថ្នាំសម្រាប់សហគមន៍ទាំងសម្រាប់មនុស្សនិងសត្វ (៣) ធានាការត្រៀមលក្ខណៈនៅក្នុងកណីមានភ្លើងឆេះព្រៃ។

គណៈកម្មការសហគមន៍បានដឹងយ៉ាងច្បាស់អំពីហានិភ័យនៃសត្វមានជម្ងឺដោយសារតែគ្រោះរាំងស្ងួត និងមានវិធីនានា ដើម្បីធានាថាប្រសិនបើសត្វមានជម្ងឺពួកគេត្រូវដុតសត្វទាំងនោះភ្លាម ដើម្បីទប់ស្កាត់ការរាតត្បាតនៃជម្ងឺ។

គណៈកម្មការសហគមន៍មានថវិកាដែលពួកគេស្វែងរកបានពីអាជ្ញាធរស្រុក សម្រាប់ប្រើប្រាស់នៅក្នុងករណីមានគ្រោះរាំងស្ងួត។ ថវិកានេះសម្រាប់ទិញថ្នាំនិងសម្រាប់ដាំដើមឈើ។

យោងតាមគណៈកម្មការសហគមន៍សកម្មភាពទាំងនេះ បាននាំឲ្យមានការដាំដើមឈើលើផ្ទៃដីទំហំ ១៦០ ហ.ត សត្វងាប់ត្រឹមតិចជាង ៥០% នៅក្នុងរដូវរាំងស្ងួត និងអណ្ដូងសហគមន៍មួយបានត្រូវសាងសង់។

*ការជ្រាបចូលនៃទឹកសមុទ្រ/ទឹកជំនន់*

គណៈកម្មការសហគមន៍មានទំនប់ការពារទឹកប្រៃប្រវែង៥គ.ម ដែលបានសាងសង់ដោយប្រើប្រាស់ថវិកាសហគមន៍ និងវិភាគទានពីអ្នកភូមិ។ លើសពីនេះគណៈកម្មការសហគមន៍នឹងជូនដំណឹងដល់គ្រួសារនានាដើម្បីសាងសង់ទីទួលសម្រាប់ទុកដាក់សត្វនៅក្នុងពេលមានទឹកជំនន់។ ទូកក៏ត្រូវបានត្រៀមទុកផងដែរសម្រាប់ដាក់ទ្រព្យរបស់អ្នកភូមិ។

គណៈកម្មការសហគមន៍ជូនដំណឹងដល់អ្នកភូមិអំពីសារៈសំខាន់នៃការសំអាតផ្ទះសំបែង នៅក្នុងពេល និងក្រោយពេលមានទឹកជំនន់។

គណៈកម្មការសហគមន៍ផ្ដល់ការគាំទ្រហិរញ្ញវត្ថុដល់អ្នកភូមិដើម្បីជួសជុលផ្ទះដែលខូចខាត។

*ខ្យល់ព្យុះនិងរន្ទះ*

គណៈកម្មការសហគមន៍មានយុទ្ធសាស្ត្រដោះទ័លក្នុងកម្រិតកំណត់សម្រាប់ករណីព្យុះនិងរន្ទះ។ នៅឆ្នាំ២០១១ ផ្ទះចំនួន៣៨ខ្នងត្រូវបានបំផ្លាញព្រៃកោងកាង១៤.០០០ម² ត្រូវបានបំផ្លាញទូកនេសាទ ២គ្រឿងលិច និងភ្លើងឆេះព្រៃកើតឡើងប្រមាណ ៣០លើក។

គណៈកម្មការសហគមន៍ណែនាំអ្នកភូមិឲ្យស្តាប់វិទ្យុ និងទូរទស្សន៍ ដើម្បីទទួលបានព័ត៌មានថ្មីៗ។ នៅពេលមានព្យុះបោកបក់មកលើសហគមន៍ អ្នកភូមិបានទទួលព័ត៌មានឲ្យជម្លៀសខ្លួនទៅរកទីជម្រកដែលបានត្រៀមជាមុន។

យោងតាមគណៈកម្មការសហគមន៍ ដោយសារតែការចែករម្លែកព័ត៌មានគ្មានអ្នកនេសាទណាម្នាក់ចេញទៅនេសាទនៅសមុទ្រឡើយ។ គ្រួសារចំនួន៩០% ស្តាប់វិទ្យុនិងទូរទស្សន៍ដើម្បីទទួលបានព័ត៌មានថ្មីៗ។

គ្រួសារចំនួន១០% បានទិញឧបករណ៍ការពាររន្ទះ។

*គណៈកម្មការសហគមន៍ទួលគរគី*

ការពិភាក្សាដូចគ្នានឹងនៅពាមក្រសោបក៏បានធ្វើជាមួយគណៈកម្មការសហគមន៍ទួលគរគីផងដែរ។

*គ្រោះរាំងស្ងួត*

ក្នុងករណីមានគ្រោះរាំងស្ងួត គណៈកម្មការសហគមន៍ស្តារប្រព័ន្ធផ្លូវទឹក និងការពារប្រភពទឹកស្អាតសម្រាប់ផឹក។ លើសពីនេះគណៈកម្មការនេះបានចាត់ចែងឲ្យមានរបងការពារជុំវិញស្រះផងដែរ។

*ការជ្រាបចូលនៃទឹកប្រៃ/ទឹកជំនន់*

ក្នុងករណីធ្ងន់ធ្ងរអ្នកភូមិត្រូវជម្លៀសចេញទៅរកទីសុវត្ថិភាពដែលបានបង្កើតទុកជាមុន។ ប្រសិនបើប្រព័ន្ធទំនប់ការពារទឹកប្រៃមានការខូចខាត គណៈកម្មការជានាឲ្យមានការជួសជុលទាំងនៅមុនក្នុងពេល និងក្រោយពេលមានព្រឹត្តិការណ៍ទឹកប្រៃជ្រាបចូល/ទឹកជំនន់។

ទំនប់ទឹកប្រៃដែលសហគមន៍បានសាងសង់មានប្រវែង៦០០ម និងកំពស់១ម។

*ខ្យល់ព្យុះនិងរន្ទះ*

អាទិភាពមួយសម្រាប់គណៈកម្មការសហគមន៍គឺ ធ្វើយ៉ាងណាឲ្យអ្នកភូមិបានទទួលដំណឹងថ្មីៗពីទូរទស្សន៍និងវិទ្យុអំពីខ្យល់ព្យុះ និងឲ្យពួកគេត្រៀមខ្លួនសម្រាប់ការជន្លៀសទៅទីសុវត្ថិភាព។

លើសពីនេះគណៈកម្មការបានបង្កើនការយល់ដឹងអំពីសារៈសំខាន់នៃការមិនកាប់ដើមឈើនៅជុំវិញភូមិដោយសារវាជួយការពារគ្រួសារនានាពីខ្យល់ព្យុះ។

នៅក្នុងករណីរន្ទះអ្នកភូមិខ្លះបានទិញឧបករណ៍ការពារទល់នឹងរន្ទះ។

*ការធ្លាក់ភ្លៀងខ្លាំង*

គណៈកម្មការសហគមន៍បានឲ្យនិយមន័យការធ្លាក់ភ្លៀងខ្លាំងថា ជាដំណាក់កាលដែលមានភ្លៀងធ្លាក់ជាប់គ្នា២ខែ។ សម្រាប់អ្នកភូមិភ្លៀងបែបនេះធ្វើឲ្យខូចខាតកសិផលដោយបង្កើនការបំផ្លាញពីសត្វចង្រៃមកលើដំណាំ។

មន្ត្រីកសិកម្មស្រុកគឺជាសមត្ថភាពសំខាន់សម្រាប់សហគមន៍។ គណៈកម្មការសហគមន៍ទាក់ទងមន្ត្រីទាំងនេះនៅពេលដែលពួកគេបានរកឃើញបញ្ហាសត្វចង្រៃបំផ្លាញដំណាំភ្លាម។ បន្ទាប់ពីនោះមន្ត្រីកសិកម្មផ្តល់ការណែនាំដល់សហគមន៍អំពីវិធីកាត់បន្ថយបញ្ហាសត្វចង្រៃ។

យោងតាមគណៈកម្មការសហគមន៍ ការផ្តោតលើការកាត់បន្ថយសត្វចង្រៃនិងយន្តការនានាដែលមានសម្រាប់អនុវត្តដើម្បីកំចាត់សត្វចង្រៃបានធានាថា៧០%នៃផលដំណាំដែលរំពឹងថាផលិតបាននឹងអាចការពារពីសត្វចង្រៃ។

### ការពិភាក្សាជាក្រុម - ក្រុមប្រឹក្សាឃុំនៅពាមក្រសោប

បន្ថែមលើការពិភាក្សាជាក្រុមនៅកម្រិតគណៈកម្មការសហគមន៍ ការពិភាក្សាជាក្រុមក៏បានធ្វើផងដែរជាមួយក្រុមប្រឹក្សាឃុំ។ ការពិភាក្សាជាក្រុមបែបនេះបានផ្អែកលើ១០សំណួរ ដែលត្រូវបានពិភាក្សាដោយមានធ្វើកំណត់ហេតុ។ ខាងក្រោមនេះជាសេចក្តីសង្ខេបនៃប្រធានបទចំបងៗនៅក្នុងការពិភាក្សាជាមួយក្រុមប្រឹក្សាឃុំពាមក្រសោប និងទួលគរគី។

ការយល់ដឹងរបស់ក្រុមប្រឹក្សាឃុំទាំងពីរអំពីការប្រែប្រួលអាកាសធាតុ ហាក់ដូចជាពិស្តារជាងអ្វីដែលមាននៅក្នុងបញ្ជីសំណួរ។ ទោះជាយ៉ាងណាក៏ដោយក្រុមប្រឹក្សាឃុំទាំងពីរបានចូលរួមនៅក្នុងសិក្ខាសាលាស្តីពីការប្រែប្រួលអាកាសធាតុនៅខេត្តកោះកុង។ លើសពីនេះ ការយល់ដឹងរបស់ក្រុមប្រឹក្សាទាំងនេះអំពីការប្រែប្រួលអាកាសធាតុបានកើតឡើងតាមរយៈព័ត៌មានក្នុងព្រឹត្តិបត្រព័ត៌មានប្រចាំខែអំពីបញ្ហាអភិវឌ្ឍន៍ ដែលរាជរដ្ឋាភិបាលកម្ពុជាចែកផ្សាយទៅក្រុមប្រឹក្សាឃុំ។

ក្រុមប្រឹក្សាឃុំទាំងពីរបានចូលរួមនៅក្នុងសកម្មភាពបន្សាំដែលអនុវត្តដោយ IUCN និង ADB។ នៅពាមក្រសោមសកម្មភាពទាំងនេះរួមមានការសាងសង់ទំនប់ទ្វារទឹកនិងអាងទឹក។ នៅទួលគរគីសកម្មភាពនានារួមមានការសាងសង់ទំនប់ដើម្បីការពារពីទឹកប្រៃការសាងសង់អាងទឹក និងប្រឡាយដើម្បីរក្សាប្រភពទឹកសាបការកែលម្អប្រព័ន្ធស្រោចស្រពដើម្បីអាចផ្តល់ទឹកសម្រាប់ប្រើប្រាស់តាមគ្រួសារនៅរដូវប្រាំង។ លើសពីនេះក្រុមប្រឹក្សាឃុំទួលគរគីបានចូលរួមយ៉ាងសកម្មក្នុងកិច្ចការពារព្រៃឈើផងដែរ។

ក្រុមប្រឹក្សាឃុំបានសម្របសម្រួលឲ្យមានប្រព័ន្ធចែកចាយព័ត៌មានជាមួយអាជ្ញាធរជាតិ និងខេត្តដែលទាក់ទងនឹងព័ត៌មានថ្មីៗស្តីពីមុខសញ្ញាគ្រោះថ្នាក់។ ព័ត៌មានដែលពួកគេទទួលបានគឺពីទូរទស្សន៍និងវិទ្យុ។ ប្រសិនបើក្រុមប្រឹក្សាឃុំទទួលព័ត៌មានដែលទាក់ទងនឹងមុខសញ្ញាគ្រោះថ្នាក់ជាតុអាកាស ពួកគេព្យាយាមជូនដំណឹងដល់អ្នកភូមិ។ ទោះជាយ៉ាងណាក៏ដោយពុំមានការបង្កើតប្រព័ន្ធព័ត៌មាននៅក្នុងភូមិនៅឡើយទេ។

គ្មានក្រុមប្រឹក្សាឃុំណាមួយ បានរួមបញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍ឃុំឡើយក្នុងពេលបច្ចុប្បន្ននេះ។ ទោះជាយ៉ាងណាក៏ដោយក្រុមប្រឹក្សាឃុំទាំងពីរបានស្នើសុំឲ្យមានការរួមបញ្ចូលបែបនេះដើម្បីឲ្យផែនការអភិវឌ្ឍន៍ឃុំអាចបញ្ចូលវិធានការដាក់លាក់អំពីការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។

### *បញ្ជីសំណួរ*

លើសពីនេះសមាជិកក្រុមប្រឹក្សាឃុំម្នាក់ៗ បានទទួលបញ្ជីសំណួរសម្រាប់ដាក់ពិន្ទុលើសំណួរចំនួន៥។លទ្ធផលពីបញ្ជីសំណួរមានដូចតទៅ៖

ក្រុមប្រឹក្សាឃុំ៖ទួលគគី

(1=គ្មានទេនិង 10= ខ្លាំងណាស់, _ = ចំនួនចម្លើយ

1.តើអ្នកដឹងកម្រិតណាអំពីការប្រែប្រួលអាកាសធាតុ?

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|
| 1 | | | 2 | | 2 | 1 | | | |

2. តើឃុំរបស់អ្នកត្រៀមខ្លួនបានកម្រិតណាដើម្បីទប់ទល់នឹងមុខសញ្ញាគ្រោះថ្នាក់ធាតុអាកាស?

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|
| | | 2 | | 2 | | 3 | | | |

3. តើអ្នកពេញចិត្តកម្រិតណាជាមួយព័ត៌មានដែលក្រុមប្រឹក្សាឃុំទទួលបានស្តីពីមុខសញ្ញាគ្រោះថ្នាក់ធាតុអាកាសពីស្ថាប័នផ្សេងទៀតនៅថ្នាក់ជាតិ?

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|
| | | 1 | | 3 | 1 | 1 | 1 | | |

4. តើអ្នកគិតថាក្រុមប្រឹក្សាឃុំផ្តល់ការគាំទ្រដល់អ្នកភូមិបានល្អកម្រិតណានៅពេលមានគ្រោះមហន្តរាយ?

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|
| | 1 | | 2 | 1 | 1 | 2. | | | |

5.តើការសម្របសម្រួលជាមួយវិស័យដទៃទៀតបានល្អកម្រិតណា (ដូចជាNGO និងវិស័យឯកជន) ទាក់ទងនឹងមុខសញ្ញាគ្រោះថ្នាក់ធាតុអាកាស?

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|
| | 2 | | 1 | 2 | | 2 | | | |

មូលដ្ឋាន = សមាជិក៧រូបមកពីក្រុមប្រឹក្សាឃុំ

**ក្រុមប្រឹក្សាឃុំពាមក្រសោប**

(1=គ្មានទេនិង 10= ខ្លាំងណាស់, _ = ចំនួនចម្លើយ

1. តើអ្នកដឹងកម្រិតណាអំពីការប្រែប្រួលអាកាសធាតុ?

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|
| | | | 4 | | 2 | | | | |

2. តើឃុំរបស់អ្នកត្រៀមខ្លួនបានកម្រិតណាដើម្បីទប់ទល់នឹងមុខសញ្ញាគ្រោះថ្នាក់ធាតុអាកាស?

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|
| | | 5 | | 1 | | | | | |

3តើអ្នកពេញចិត្តកម្រិតណាជាមួយព័ត៌មានដែលក្រុមប្រឹក្សាឃុំទទួលបានស្តីពីមុខសញ្ញាគ្រោះថ្នាក់ធាតុអាកាសពីស្ថាប័នផ្សេងទៀតនៅថ្នាក់ជាតិ?

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|
| | 1 | 3 | | 1 | 1 | | | | |

4. តើអ្នកគិតថាក្រុមប្រឹក្សាឃុំផ្តល់ការគាំទ្រអ្នកភូមិបានល្អកម្រិតណានៅពេលមានគ្រោះមហន្តរាយ?

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|
| | 2 | | 2 | 2 | | | | | |

5. .តើការសម្របសម្រួលជាមួយវិស័យដទៃទៀតបានល្អកម្រិតណា (ដូចជាNGO និងវិស័យឯកជន) ទាក់ទងនឹងមុខសញ្ញាគ្រោះថ្នាក់ធាតុអាកាស?

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|
| | | | | 5 | | 1 | | | |

មូលដ្ឋាន = សមាជិក៧រូបមកពីក្រុមប្រឹក្សាឃុំ

តាមរយៈទិន្នន័យខាងលើនិងការពិភាក្សាជាក្រុមនៅក្នុងឃុំ គេហាក់ដូចជាឃើញមានមូលដ្ឋានសម្រាប់អភិវឌ្ឍន៍សមត្ថភាពបច្ចេកទេសកាន់តែច្រើន អំពីការប្រែប្រួលអាកាសធាតុនៅក្នុងក្រុមប្រឹក្សាឃុំ។ សូម្បីការចែករម្លែកព័ត៌មានអំពីមុខសញ្ញាគ្រោះមហន្តរាយធាតុអាកាសមិនមានរចនាសម្ព័ន្ធច្បាស់លាស់ក៏ដោយ ក្រុមប្រឹក្សាឃុំគួរតែផ្សារភ្ជាប់រវាងការចែករម្លែកព័ត៌មានអំពីមុខសញ្ញាគ្រោះថ្នាក់ធាតុអាកាសមកពីអាជ្ញាធរថ្នាក់ជាតិ និងស្រុក និងអ្នកភូមិនានាក្នុងតំបន់រងគ្រោះ។

## ការសន្និដ្ឋានលើទិន្នន័យដែលបានពីកោះកុង

ក្នុងឃុំគោលដៅនៅកោះកុង អ្នកភូមិបានជួបប្រទះនិន្នាការច្បាស់លាស់មួយនៃការប្រែប្រួលរបបធាតុអាកាសដែលនឹងនាំឲ្យមានមុខសញ្ញាគ្រោះថ្នាក់ធាតុអាកាសកាន់តែញឹកញាប់។

ទាំងនៅឃុំពាមក្រសោប និងទួលគរគីសុទ្ធតែមានយុទ្ធសាស្ត្រដោះទ័លសម្រាប់ប្រើប្រាស់ដែលការពារអ្នកភូមិពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ ទោះជាយ៉ាងណាក៏ដោយគ្មានយុទ្ធសាស្ត្រដោះទ័លទាំងនេះណាមួយការពារអ្នកភូមិពីផលវិបាកអវិជ្ជមានដែលទាក់ទងនឹងសេដ្ឋកិច្ចមុខរបរ និងសុខភាពរបស់ពួកគេបានឡើយ។

គណៈកម្មការសហគមន៍នៅពាមក្រសោប ហាក់ដូចជាមានការយល់ឃើញពិស្តារជាងអំពីការប្រែប្រួលអាកាសធាតុធៀបនឹងទិន្នន័យដទៃទៀត។ ការយល់ឃើញពិស្តារបែបនេះនាំឲ្យមានការយល់ដឹងអំពីថាតើគណៈកម្មការសហគមន៍ធ្វើបែបណាទើបអាចគាំទ្រដល់អ្នកភូមិក្នុងការអនុវត្តយុទ្ធសាស្ត្រដោះទ័ល ដែលមានស្រាប់។

គណៈកម្មការសហគមន៍នៅទួលគរគីបានចូលរួមយ៉ាងសកម្មជាមួយអាជ្ញាធរនានា ក្នុងការប្រើប្រាស់សមត្ថភាពដែលមានក្នុងស្ថាប័ននានា។ សហគមន៍ធ្វើ

បែបនេះដោយប្រើប្រាស់មន្ត្រីកសិកម្មថ្នាក់ខេត្តដែល
ផ្តល់ការណែនាំអំពីការប្រយុទ្ធប្រឆាំងរបស់អ្នកភូមិទល់នឹងការរាតត្បាតនៃសត្វចង្រៃមកលើដំណាំដោយផ្តល់លទ្ធផលវិជ្ជមាន។

ជាទូទៅចាប់ពីក្រុមប្រឹក្សាឃុំនិងថ្នាក់ទាបជាងនេះ គេឃើញមានការយល់ដឹងអំពីសារៈសំខាន់នៃការចែករម្លែកព័ត៌មាន ដើម្បីជានាឲ្យមានយុទ្ធសាស្ត្រដោះទ័លប្រកបដោយជោគជ័យ។ ទោះជាយ៉ាងណាក៏ដោយគ្មានសហគមន៍ណាមួយក្នុងចំណោមសហគមន៍គោលដៅ មានប្រព័ន្ធមួយដែលគាំទ្រដល់ការចែករម្លែកព័ត៌មានដែលចាំបាច់ទាំងនៅផ្ទៃក្នុងនៃសហគមន៍និងក្នុងទំនាក់ទំនងជាមួយអាជ្ញាធរខេត្តនិងជាតិផងដែរ។

## ខេត្តព្រះសីហនុ

នៅខេត្តព្រះសីហនុការប្រមូលទិន្នន័យបានធ្វើឡើងនៅស្រុកព្រៃនប់ក្នុងឃុំចំនួន៦ ពោលគឺទឹកថ្លា ទឹកល្អក់សាមគ្គី ទួលទទឹង អូរឧកញ៉ាហេង និងព្រៃនប់។ ជាសរុបមានបញ្ជីសំណួរចំនួន២៥៧ដែលប្រើប្រាស់សម្រាប់ប្រមូលព័ត៌មាននៅក្នុងភូមិបឹងរាំង ឈរលួង កំពង់ស្មាច់តូច តាឱនធំ បែកក្រាន បត់គរគី បត់សិរមាន់ ជំពូខ្មៅអូរចំណារអូរតាប៉ាងព្រៃនប់និងទួលទទឹង។ ការពិភាក្សាជាប្រាំមួយក្រុមជាមួយគណៈកម្មការសហគមន៍បានធ្វើឡើង ហើយវគ្គពិភាក្សាចំនួន៦ផ្សេងទៀតបានធ្វើជាមួយក្រុមប្រឹក្សាឃុំផងដែរ។

**បញ្ជីសំណួរ**

ក្នុងចំណោមអ្នកឆ្លើយចំនួន២៥៧នាក់មានស្ត្រី១៣៩នាក់និងបុរស១១៧នាក់។ ការញែកដាច់គ្នារវាងបុរសនិងស្ត្រីស្ទើរតែដូចគ្នាទាំងស្រុងធៀបនឹងនៅកោះកុង។

ផ្ទុយនឹងកោះកុង អ្នកឆ្លើយភាគច្រើនជាប់រវល់ក្នុងកសិកម្ម។ ក្នុងចំណោមអ្នកឆ្លើយចំនួន២៥៧នាក់ អ្នកដែលរបរចិញ្ចឹមជីវិតផ្អែកតែលើការដាំដំណាំមាន៤៦% ចំណែកអ្នកពឹងផ្អែកលើការដាំដំណាំនិងប្រភពចំណូលដទៃទៀតដូចជាការនេសាទមាន៥០%។ មានអ្នកឆ្លើយតែ ៧% ពឹងផ្អែកតែលើការនេសាទជាប្រភពចំបងនៃការចិញ្ចឹមជីវិត។

អ្នកឆ្លើយ៩% គឺជាគ្រួសារតែមានស្ត្រីជាមេគ្រួសារ។

ដូចនៅកោះកុងដែរអ្នកឆ្លើយត្រូវបានស្នើសុំឲ្យផ្តល់យោបល់ដើម្បីផ្តល់ព័ត៌មានដែលទាក់ទងនឹងប្រាក់ចំណូលប្រចាំថ្ងៃរបស់ពួកគេនៅក្នុងរដូវវស្សានិងរដូវប្រាំង។អ្នកឆ្លើយអាចត្រូវបែងចែកដូចតទៅ៖

| ប្រាក់ចំណូលប្រចាំថ្ងៃនៅរដូវវស្សា៖ | ប្រាក់ចំណូលប្រចាំថ្ងៃនៅរដូវប្រាំង៖ |
|---|---|
| អ្នកឆ្លើយ៦៩នាក់ = ១០០០-៥០០០នាក់ | អ្នកឆ្លើយ៧២នាក់ = ១០០០-៥០០០នាក់ |
| អ្នកឆ្លើយ៥០នាក់= ៥០០០-១០០០០នាក់ | អ្នកឆ្លើយ៥៤នាក់ = ៥០០០-១០.០០០នាក់ |
| អ្នកឆ្លើយ៨០នាក់= ១០០០០-________រៀល | អ្នកឆ្លើយ១០៨នាក់= ១០០០០-________រៀល |
| អ្នកឆ្លើយ៥៨នាក់ = គ្មានចម្លើយ | ឆ្លើយ២៣នាក់ = គ្មានចម្លើយ |
| មូលដ្ឋាន៖អ្នកឆ្លើយទាំងអស់ | មូលដ្ឋាន៖អ្នកឆ្លើយទាំងអស់ |

ជារួមតួលេខទាំងនេះបង្ហាញថា អ្នកឆ្លើយមានប្រាក់ចំណូលនៅក្នុងរដូវប្រាំងខ្ពស់ជាងក្នុងរដូវវស្សា។ ទោះជាយ៉ាងណាក៏ដោយអ្នកឆ្លើយក្នុងចំនួនក្រាស់ក្រែលមិនបានផ្តល់ចម្លើយឡើយ។ ដូច្នេះតួលេខនេះនៅត្រូវការឲ្យមានការវិភាគបន្ថែមទៀត។

***ការយល់ឃើញ***

ដូចដែលបានសន្និដ្ឋានសម្រាប់ទិន្នន័យមកពីកោះកុងទិន្នន័យដែលប្រមូលបានសម្រាប់ប្រធានបទ "ការយល់ឃើញ" នៅខេត្តព្រះសីហនុមានភាពស្របគ្នាជាមួយឯកសារយោងនានា។

សំណួរ២ក្នុង "ការយល់ឃើញអំពីការប្រែប្រួលអាកាសធាតុ"
"បើមាន (សំណួរ១) តើផលវិបាកអ្វីខ្លះដែលការប្រែប្រួលនោះបង្កឡើង?"

| | |
|---|---|
| • ប្រែប្រួលរបបទឹកភ្លៀង | ៩៤% |
| • ការប្រែប្រួលសីតុណ្ហភាព | ៦២% |
| • រាំងស្ងួតជាងមុន | ២២% |
| • ទឹកជំនន់ច្រើនជាងមុន | ៣៩% |
| • ខ្យល់ព្យុះច្រើនជាងមុន | ៩១% |
| ការជ្រាបចូលទឹកសមុទ្រខ្លាំងជាងមុន | ៥៦% |
| • សត្វចង្រៃបំផ្លាញដំណាំ | ៦៦% |
| មូលដ្ឋាន = អ្នកឆ្លើយ២៥៥នាក់ | អាចមានចម្លើយច្រើន |

ក្នុងចំណោមអ្នកឆ្លើយទាំងអស់នេះ៩៩% បានឆ្លើយថាពួកគេបានកត់សំគាល់អំពីការប្រែប្រួលរបបធាតុអាកាសនៅក្នុងរយៈពេល៥ឆ្នាំចុងក្រោយធៀបនឹង៩៧% នៅកោះកុង។

ក្នុងចំណោមផលវិបាកដែលរំពឹងទុកបណ្តាលពីការប្រែប្រួលធាតុអាកាស ចម្លើយដែលទទួលបានអាចបែងចែកជាក្រុមដូចតទៅៈ

ចម្លើយមានភាពប្រហែលគ្នានឹងការសិក្សា KAP ជាងលទ្ធផលដែលបានពីខេត្តកោះកុង។ ចំណុចនេះអាចពន្យល់បានថាមុខរបររបស់អ្នកឆ្លើយជាទូទៅមានភាពស្របគ្នាជាមួយតួលេខនៅកម្រិតជាតិ។

ទិន្នន័យពីខេត្តព្រះសីហនុមានភាពគួរឲ្យជឿបាននិងពុំបន្សល់ទុកការសង្ស័យច្រើនទេ ដែលថាអ្នកភូមិនៅព្រៃនប់ពិតជាយល់ថា ការប្រែប្រួលធាតុអាកាសបានកើតឡើងនិងបាននាំឲ្យមានមុខសញ្ញាគ្រោះថ្នាក់ធាតុអាកាសដូចដែលបានចាត់ជាក្រុមខាងលើ។

នៅកោះកុងអ្នកឆ្លើយយល់ថា មុខសញ្ញាគ្រោះថ្នាក់ធាតុអាកាសដែលបានចាត់ជាក្រុមខាងលើមានផលប៉ះពាល់អវិជ្ជមានមកលើការចិញ្ចឹមជីវិតរបស់ពួកគេ។

សំណួរ៣ "ការយល់ឃើញអំពីការប្រែប្រួលអាកាសធាតុ"
តើផលវិបាកទាំងនេះមានការប៉ះពាល់មកលើការចិញ្ចឹមជីវិតរបស់អ្នកឬទេ?

- មុខរបរ ៦០%
- ប្រាក់ចំណូល ៧៨%
- សុខភាព ៥១%

មូលដ្ឋាន = អ្នកឆ្លើយ២៥៥នាក់ អាចមានចម្លើយច្រើន

ដូចបានកត់សំគាល់ពីខាងដើម ការយល់ឃើញរបស់សាធារណជនអំពីមូលហេតុ នៃការប្រែប្រួលអាកាសធាតុមានការទាក់ទងនឹងការប្រែប្រួលនៅមូលដ្ឋានឬមិនសូវទាក់ទងនឹងការប្រែប្រួលជាសាកលឡើយ។ ប្រការនេះ មានភាពស្របគ្នាជាមួយទិន្នន័យពីខេត្តព្រះសីហនុ ដូចដែលអាចឃើញតាមរយៈចម្លើយតបនឹងសំណួរអំពីអ្វីខ្លះដែលអ្នកឆ្លើយគិតថាជាមូលហេតុចំបងនៃការប្រែប្រួលរបបធាតុអាកាស។

សំណួរ៤ "ការយល់ឃើញអំពីការប្រែប្រួលអាកាសធាតុ"
"តើអ្នកគិតថាអ្វីខ្លះបង្កការប្រែប្រួលទាំងនេះនៃរបបធាតុអាកាស?"

- ការបាត់បង់ព្រៃឈើ ៥១%
- ឥទ្ធិពលនៅថ្នាក់ជាតិ ៤៤%
- បឥទ្ធិពលនៅកម្រិតអន្តរជាតិ ៤២%

មូលដ្ឋាន = អ្នកឆ្លើយ២៥៥នាក់ អាចមានចម្លើយច្រើន

### *ព័ត៌មាន*

នៅពេលសួរថាតើអ្នកឆ្លើយធ្លាប់ឮពាក្យ "ការប្រែប្រួលអាកាសធាតុ"ដែរឬទេលទ្ធផលមានកម្រិតទាបគួរឲ្យភ្ញាក់ផ្អើលធៀបនឹងការសិក្សា KAP និងទិន្នន័យពីកោះកុង។ មានតែ៥៥% ដែលឆ្លើយថា "ធ្លាប់ឮ" ចំណែក ៤៣% "ឆ្លើយថា "មិនធ្លាប់ទេ"។ នៅក្នុងការសិក្សាKAP៨៤% បានឆ្លើយថា "ធ្លាប់ឮ" និងនៅកោះកុង៧១% បានឆ្លើយថា "ធ្លាប់ឮ" ។[37]

តួលេខដែលមានកម្រិតទាបនេះគួរតែអាចយល់បានធៀបនឹងសំណួរ២ក ដែលសួរថាតើពួកគេបានចូលរួមនៅក្នុងសកម្មភាពបង្កើនការយល់ដឹងណាមួយ ដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុដែរឬទេ។ ទិន្នន័យពីព្រៃនប់មានតួលេខទាបដូចដែលអាចឃើញក្នុងតារាងខាងក្រោម។

សំណួរ២ក "ព័ត៌មាន"
តើអ្នកបានចូលរួមនៅក្នុងសកម្មភាពបង្កើនការយល់ដឹងដែរឬទេ ?

| ស្ត្រី | បុរស |
|---|---|
| ៦ | ៦ |
| ២% | ២% |

មូលដ្ឋានៈអ្នកឆ្លើយទាំងអស់

ក្នុងចំណោមអ្នកឆ្លើយទាំង២៤នាក់ ដែលត្រូវបានចាត់ចូលជាគ្រួសារដែលមានស្ត្រីជាមេគ្រួសារ២នាក់បានឆ្លើយ "ធ្លាប់" បានចូលរួមក្នុងពិធីបង្កើនការយល់ដឹងមួយ។

ចំពោះសំណួរដែលថាប្រភពណាមួយ ប្រសិនបើមានដែលអ្នកឆ្លើយបានទទួលព័ត៌មានអំពីមុខសញ្ញាគ្រោះថ្នាក់ធាតុអាកាសទិន្នន័យនេះមានភាពស្របគ្នាច្រើនជាមួយទិន្នន័យមកពីកោះកុង។ ទោះជាយ៉ាងណាក៏ដោយទិន្នន័យពីខេត្តព្រះសីហនុបង្ហាញតួលេខដែលមានកម្រិតទាបគួរឲ្យកត់សំគាល់។ មានតែអ្នកឆ្លើយ២%

សំណួរ៣ "ព័ត៌មាន"
តើអ្នកបានទទួលព័ត៌មានដោយរបៀបណាអំពីមុខសញ្ញាគ្រោះថ្នាក់ធាតុអាកាសនៅក្នុងស្រុករបស់អ្នក ?

- <u>វិទ្យុ ៦០%</u>
  - វិទ្យុខ្មែរ ៥៨%
  - វិទ្យុថៃ ២%
  - វិទ្យុវៀតណាម ២%
- <u>ទូរទស្សន៍ ២៥%</u>
  - ទូរទស្សន៍ខ្មែរ ២៥%
  - ទូរទស្សន៍ថៃ 0%
  - ទូរទស្សន៍វៀតណាម 0%
- អ្នកជិតខាង ២៧%
- មន្ត្រីរដ្ឋាភិបាល ២%

មូលដ្ឋានៈអ្នកឆ្លើយទាំងអស់ អាចមានចម្លើយច្រើន

---

37Oxfam America, "Understanding Public Perception of Climate Change in Cambodia", p 19, 2011

ដែលបានទទួលព័ត៌មានដែលទាក់ទងនឹងមុខសញ្ញាគ្រោះថ្នាក់ធាតុអាកាសពីមន្ត្រីរដ្ឋាភិបាល។ ដូចក្នុងករណីកោះកុងផងដែរតួលេខនេះបង្ហាញថា គ្មានមធ្យោបាយសម្រាប់ចែករំលែកព័ត៌មានឡើយនៅកម្រិតស្ថាប័ន។ នៅពេលឆ្លើយតបនឹងសំណួរ៤អ្នកឆ្លើយជាច្រើនសួររកព័ត៌មានបែបនេះពីអាជ្ញាធរឃុំ។

ដោយសារមានតែអ្នកឆ្លើយចំនួនតិចតួច ដែលបានទទួលព័ត៌មានពីមន្ត្រីរដ្ឋាភិបាលដែលទាក់ទងនឹងមុខសញ្ញាគ្រោះថ្នាក់ធាតុអាកាស ឬបានចូលរួមនៅក្នុងសកម្មភាពបង្កើនការយល់ដឹងគ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលទេដែលថាមានអ្នកឆ្លើយត្រឹម ៩% បានដឹងអំពីការងារណាមួយរបស់រដ្ឋាភិបាលទាក់ទងនឹងការបន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ។

## *យុទ្ធសាស្ត្រដោះទ័ល*

ទោះបីអ្នកឆ្លើយនៅស្រុកព្រៃនប់ផ្តល់ពិន្ទុទាបអំពីចំណេះដឹងអំពីសញ្ញាណនៃការប្រែប្រួលអាកាសធាតុក៏ដោយអ្នកឆ្លើយនៅតែមានការយល់ដឹងដែលអាចទប់ទល់នឹងមុខសញ្ញាខ្លះៗ នៃគ្រោះថ្នាក់ធាតុអាកាសដូចមានបង្ហាញក្នុងទិន្នន័យខាងក្រោម។

សំណួរ១ "យុទ្ធសាស្ត្រទប់ទល់"
"ក្នុងករណីមានគ្រោះមហន្តរាយធាតុអាកាសកើតឡើងដូចខាងក្រោមតើអ្នកមានសមត្ថភាពទប់ទល់ឬទេ?"

| | |
|---|---|
| • គ្រោះរាំងស្ងួត | ៥% |
| • ទឹកជំនន់ | ១១% |
| • ខ្យល់ព្យុះ | ២៨% |
| • ការជ្រាបចូលនៃទឹកប្រៃ | ២៦% |
| • សត្វចង្រៃបំផ្លាញដំណាំ | ៣០% |
| • គ្មាន | ១៤% |

មូលដ្ឋានៈអ្នកឆ្លើយទាំងអស់ អាចមានចម្លើយច្រើន

អ្នកឆ្លើយភាគច្រើនគិតថាពួកគេអាចទប់ទល់នឹងបញ្ហាខ្យល់ព្យុះ។ ដូចដែលបានអធិប្បាយនៅក្នុងទិន្នន័យពីកោះកុងខ្យល់ព្យុះមិនសូវស្មុគស្មាញក្នុងការបន្ស៊ាំឡើយធៀបនឹងមុខសញ្ញាគ្រោះថ្នាក់ដទៃទៀត។ ទោះជាយ៉ាងណាក៏ដោយអ្នកឆ្លើយ២៦% ឲ្យដឹងថាពួកគេអាចទប់ទល់នឹងការជ្រាបចូលនៃទឹកប្រៃហើយភាគរយនេះមានកម្រិតខ្ពស់។ ទោះជាយ៉ាងណាគេអាចយល់បានចំណុចនេះធៀបនឹងសកម្មភាពយ៉ាងច្រើននៃការស្តារប្រព័ន្ធទំនប់ដែល AFD បានធ្វើឡើងនៅក្នុងរយៈពេល៤ឆ្នាំនៅព្រៃនប់។

ខាងក្រោមនេះជាយុទ្ធសាស្ត្រដោះទ័លខ្លះៗដែលអ្នកឆ្លើយបានកត់សំគាល់។

សំណួរ១ "ការបង្ហាញពិស្តារ" "យុទ្ធសាស្ត្រដោះទ័ល"
ក្នុងករណីនៃគ្រោះមហន្តរាយធាតុអាកាសដូចខាងក្រោមនេះតើអ្នកមានសមត្ថភាពទប់ទល់ឬទេ នៅពេលវាកើតឡើង (បើមានសូមពន្យល់)?

- សង់ទំនប់នៅជុំវិញស្រែ
- សង់ទំនប់ជុំវិញផ្ទះ
- ផ្តួលស្រូវ
- មិនចេញទៅនេសាទ
- ស្នើឲ្យបើកទ្វារទឹក
- ប្រើប្រាស់ជីគីមីដើម្បីទប់ស្កាត់សត្វចង្រៃពីការបំផ្លាញដំណាំ

មូលដ្ឋានៈអ្នកឆ្លើយទាំងអស់

ឧទាហរណ៍ទាំងនេះអំពីយុទ្ធសាស្ត្រដោះទ័ល ប្រហែលគ្នានឹងយុទ្ធសាស្ត្រដែលប្រើប្រាស់នៅពាមក្រសោប។ យុទ្ធសាស្ត្រដោះទ័លទាំងអស់លើកលែងតែការប្រើប្រាស់ជីគីមីពុំត្រូវការសមត្ថភាពបច្ចេកទេសកម្រិតខ្ពស់ឡើយ ប៉ុន្តែគឺជាលទ្ធផលនៃមធ្យោបាយដែលមាននៅក្នុងភូមិ។ យុទ្ធសាស្ត្រដោះទ័លទាំងនេះនឹងមានពិភាក្សាពិស្តារបន្ថែមទៀតនៅក្នុងបទបង្ហាញនៃការពិភាក្សាជាក្រុមជាមួយគណៈកម្មការសហគមន៍។

សំណួរ៣ "យុទ្ធសាស្ត្រដោះទ័ល"
"នៅពេលគ្រោះមហន្តរាយធាតុអាកាសកើតឡើងចុងក្រោយបង្អស់តើវាធ្វើឲ្យគ្រួសារអ្នកបាត់បង់អ្វីខ្លះដែរឬទេ?"

| បាត់បង់ | គ្មានទេ |
|---|---|
| ៥៣% | ៣៥% |

មូលដ្ឋានៈអ្នកឆ្លើយទាំងអស់

ដូចនៅខេត្តកោះកុងដែរបើទោះជាមានយន្តការដោះទ័លខ្លះ ហើយក៏ដោយអ្នកឆ្លើយភាគច្រើនមានការបាត់បង់ដោយសារតែគ្រោះមហន្តរាយដែលបានកើតឡើងចុងក្រោយបង្អស់។

### ការពិភាក្សាជាក្រុម នៃគណៈកម្មការសហគមន៍ នៅព្រៃនប់

ការពិភាក្សាបានធ្វើឡើងជា៦ក្រុមជាមួយអ្នកភូមិបឹងរាំង ទឹកល្អក់ ទឹកថ្លា ទួលទទឹង អូរឧកញ៉ាហេង និងព្រៃនប់។ តារាងម៉ាទ្រិកមានបង្ហាញជូនក្នុងឧបសម្ព័ន្ធ។ អ្នកអាចគួរតែពិនិត្យមើលតារាងម៉ាទ្រិកនេះ។ ផ្នែកនេះនឹងសង្ខេបរបកគំហើញចំបងៗតែប៉ុណ្ណោះ។

ជាទូទៅមានការរកឃើញថាគណៈកម្មការសហគមន៍ទាំង៦ ពុំមានការយល់ដឹងក្នុងកម្រិតដូចគ្នាដូចគណៈកម្មការសហគមន៍នៅកោះកុងឡើយ។ ប្រការនេះក៏ដោយសារតែគណៈកម្មការសហគមន៍មិនអាចផ្តល់ការឆ្លុះបញ្ចាំងសម្រាប់ជួរឈរមួយចំនួននៅក្នុងតារាងម៉ាទ្រិក។ ដូច្នេះមានរបកគំហើញតិចតួចជាងដែលអាចស្រង់ចេញពីក្រុមពិភាក្សានេះ។

*ខ្យល់ព្យុះ*

ដូចនៅកោះកុងដែរ ព័ត៌មានដែលអ្នកភូមិទទួលបានគឺជាព័ត៌មានថ្មីៗតាមវិទ្យុនិងទូរទស្សន៍ ហើយពួកគាត់មិនចេញទៅនេសាទនៅសមុទ្រឡើយ។ ប្រសិនបើបានជូនដំណឹងមុនពេលមានខ្យល់ព្យុះអ្នកភូមិខ្លះបានបង្កើតយុទ្ធសាស្ត្រដោះទ័លដោយប្រើប្រាស់ឈើដើម្បីផ្តួលស្រូវក្នុងស្រែដើម្បីកុំឲ្យបាក់នៅពេលមានព្យុះ។

នៅទឹកថ្លាគណៈកម្មការសហគមន៍ជួយអ្នកភូមិដែលផ្ទះខូចខាតដោយសារខ្យល់ព្យុះ។ លើសពីនេះនៅទឹកថ្លាគណៈកម្មការសហគមន៍ជូនដំណឹងដល់អាជ្ញាធរស្រុកអំពីផលប៉ះពាល់ពីខ្យល់ព្យុះ។

*ការជ្រាបចូលនៃទឹកប្រៃ*

នៅក្នុងករណីនៃការជ្រាបចូលទឹកប្រៃ យុទ្ធសាស្ត្រដោះទ័លមានលក្ខណៈប្រហែលគ្នានឹងនៅកោះកុងដែរ។ ការសាងសង់ទំនប់ដើម្បីការពារទល់នឹងទឹកសមុទ្រគឺជាយុទ្ធសាស្ត្រចំបងមួយ នៅក្នុងសហគមន៍នានាប៉ុន្តែក៏រួមទាំងការត្រៀមទុកសម្រាប់ជន្លៀសអ្នកភូមិនិងទ្រព្យសម្បត្តិរបស់ពួកគេផងដែរ។

**ការពិភាក្សាជាក្រុម នៃក្រុមប្រឹក្សាឃុំ**

ការពិភាក្សាជាក្រុមជាមួយក្រុមប្រឹក្សាឃុំបានធ្វើឡើងដូចនៅកោះកុងដែរ និងមានសំណួរ១០ដូចគ្នា។ នៅខេត្តព្រះសីហនុក្រុមប្រឹក្សាឃុំទាំង៦នៃឃុំទឹកថ្លា ទឹកល្អក់ សាមគ្គី ទួលទទឹង អូរឧកញ៉ាហេង និងព្រៃនប់ បានចូលរួមនៅក្នុងលំហាត់នេះ។

ការយល់ដឹងរបស់ក្រុមប្រឹក្សាឃុំទាំង៦មានភាពស្របគ្នា ជាមួយលទ្ធផលពីបញ្ជីសំណួរជាងនៅកោះកុង។ សមាជិកក្រុមប្រឹក្សាយល់ថាការប្រែប្រួលអាកាសធាតុមានការពាក់ព័ន្ធនឹងផលប៉ះពាល់នៅមូលដ្ឋានដែលផ្ទុយពីក្រុមប្រឹក្សានៅកោះកុងដែលមានទស្សនៈថា ការប្រែប្រួលអាកាសធាតុក៏ពាក់ព័ន្ធផងដែរជាមួយបរិបទពិភពលោកផងដែរ។

ឃុំសាមគ្គីគឺជាឃុំតែមួយគត់ក្នុងចំណោមឃុំទាំង៦ ដែលមានបញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍ឃុំនិងបានបង្កើតគណៈកម្មការត្រៀមបង្ការគ្រោះមហន្តរាយនិងសង្គ្រោះ។ គណៈកម្មការនេះបានកំណត់អត្តសញ្ញាណកន្លែងដែលមានសុវត្ថិភាពសម្រាប់អ្នកភូមិ ដើម្បីជ្រកកោណនៅក្នុងពេលមានគ្រោះមហន្តរាយធាតុអាកាសដូចជាខ្យល់ព្យុះ។

ឃុំចំនួនបីគឺទឹកថ្លា ទឹកល្អក់ និងសាមគ្គីធ្លាប់បានចូលរួមក្នុងសកម្មភាពប្រែប្រួលអាកាសធាតុដែលចាត់ចែងឡើងដោយក្រសួងបរិស្ថាន (MoE) និងអាជ្ញាធរខេត្ត។ សកម្មភាពនានាទាក់ទងនឹងការណែនាំ ដើម្បីបង្កើនការយល់ដឹងអំពីការជ្រើសរើសពូជនិងការដាំដើមកោងកាង។

ឃុំចំនួន២គឺទឹកថ្លានិងទឹកល្អក់បានទទួលព័ត៌មានពីក្រសួងធនធានទឹក និងឧតុនិយម និងអាជ្ញាធរខេត្តនៅមុនមានគ្រោះមហន្តរាយធាតុអាកាស។

ដូចនៅកោះកុងដែរ សមាជិកម្នាក់ៗនៃក្រុមប្រឹក្សាឃុំត្រូវបានស្នើសុំឲ្យបំពេញនៅក្នុងបញ្ជីសំណួរបន្ថែមលើសំណួរទាំង១០។ លទ្ធផលនៃការដាក់ពិន្ទុសម្រាប់បញ្ជីសំណួរទាំងនេះមានដូចតទៅ៖

ឃុំទឹកថ្លា

(1=គ្មានសោះនិង10= ខ្លាំងបំផុត), _ =ចំនួនចម្លើយ

**1.** តើអ្នកយល់ដឹងបានកម្រិតណាអំពីពាក្យការប្រែប្រួលអាកាសធាតុ

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|
| | | | | | 3 | 1 | | | |

**2.** តើឃុំរបស់អ្នកត្រៀមខ្លួនជាស្រេចបានកម្រិតណាក្នុងការដោះស្រាយបញ្ហាគ្រោះមហន្តរាយធាតុអាកាស ?

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|
| | | | 3 | 1 | | | | | |

**3.** តើអ្នកពេញចិត្តកម្រិតណាចំពោះព័ត៌មានដែលក្រុមប្រឹក្សាឃុំបានទទួលពីអាជ្ញាធរនៅថ្នាក់ជាតិ ?

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|
| | | | | 3 | 1 | | | | |

**4.** តើអ្នកគិតថាក្រុមប្រឹក្សាឃុំជួយគាំទ្រអ្នកភូមិបានល្អកម្រិតណាក្នុងករណីមានគ្រោះមហន្តរាយធាតុអាកាស ?

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|
| | | 1 | 3 | | | | | | |

**5.** តើការសម្របសម្រួលជាមួយវិស័យដទៃទៀតបានល្អកម្រិតណា ( ដូចជាNGOនិងវិស័យឯកជន ) ទាក់ទងនឹងបញ្ហាគ្រោះមហន្តរាយធាតុអាកាស ?

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | 3 | 1 | |

មូលដ្ឋានៈសមាជិកចំនួនបួនរូបក្នុងក្រុមប្រឹក្សាឃុំ

ឃុំសាមគ្គី

(1=គ្មានសោះនិង10= ខ្លាំងបំផុត), _ =ចំនួនចម្លើយ

**1.** តើអ្នកយល់ដឹងបានកម្រិតណាអំពីពាក្យការប្រែប្រួលអាកាសធាតុ

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|
| | | | 3 | 5 | | | | | |

**2.** តើឃុំរបស់អ្នកត្រៀមខ្លួនជាស្រេចបានកម្រិតណាក្នុងការដោះស្រាយបញ្ហាគ្រោះមហន្តរាយធាតុអាកាស ?

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|
| | | | | 1 | | 1 | 1 | | |

**3.**តើអ្នកពេញចិត្តកម្រិតណាចំពោះព័ត៌មានដែលក្រុមប្រឹក្សាឃុំបានទទួលពីអាជ្ញាធរនៅថ្នាក់ជាតិ ?

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|
| | 1 | 1 | 1 | | | | | | |

**4.** តើអ្នកគិតថាក្រុមប្រឹក្សាឃុំជួយគាំទ្រអ្នកភូមិបានល្អកម្រិតណាក្នុងករណីមានគ្រោះមហន្តរាយធាតុអាកាស ?

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|
| | | | | 1 | 2 | | | | |

**5.**តើការសម្របសម្រួលជាមួយវិស័យដទៃទៀតបានល្អកម្រិតណា ( ដូចជាNGOនិងវិស័យឯកជន ) ទាក់ទងនឹងបញ្ហាគ្រោះមហន្តរាយធាតុអាកាស ?

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|
| | 2 | | 1 | | | | | | |

មូលដ្ឋានៈសមាជិកចំនួនបីរូបក្នុងក្រុមប្រឹក្សាឃុំ

ឃុំទឹកល្អក់

(1=គ្មានសោះនិង10= ខ្លាំងបំផុត), _ =ចំនួនចម្លើយ

**1.** តើអ្នកយល់ដឹងបានកម្រិតណាអំពីពាក្យការប្រែប្រួលអាកាសធាតុ

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|
| | | | 2 | 1 | | 2 | | | |

**2.** តើឃុំរបស់អ្នកត្រៀមខ្លួនជាស្រេចបានកម្រិតណាក្នុងការដោះស្រាយបញ្ហាគ្រោះមហន្តរាយធាតុអាកាស?

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|
| | 1 | | 1 | 1 | 2 | | | | |

**3.** តើអ្នកពេញចិត្តកម្រិតណាចំពោះព័ត៌មានដែលក្រុមប្រឹក្សាឃុំបានទទួលពីអាជ្ញាធរនៅថ្នាក់ជាតិ ?

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|
| | | 1 | 2 | | 1 | 1 | | | |

**4.** តើអ្នកគិតថាក្រុមប្រឹក្សាឃុំជួយគាំទ្រអ្នកភូមិបានល្អកម្រិតណាក្នុងករណីមានគ្រោះមហន្តរាយធាតុអាកាស ?

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|
| | | 1 | 2 | 1 | 1 | | | | |

**5.** តើការសម្របសម្រួលជាមួយវិស័យដទៃទៀតបានល្អកម្រិតណា ( ដូចជា NGOនិងវិស័យឯកជន ) ទាក់ទងនឹងបញ្ហាគ្រោះមហន្តរាយធាតុអាកាស ?

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|
| | | | 1 | 3 | | 1 | | | |

មូលដ្ឋាន៖សមាជិកចំនួនប្រាំរូបក្នុងក្រុមប្រឹក្សាឃុំ

ឃុំទួលទទឹង

(1=គ្មានសោះនិង10= ខ្លាំងបំផុត), _ =ចំនួនចម្លើយ

**1.** តើអ្នកយល់ដឹងបានកម្រិតណាអំពីពាក្យការប្រែប្រួលអាកាសធាតុ1 2 3 4 5

6 7 8 9 10

2 1 1

**2.** តើឃុំរបស់អ្នកត្រៀមខ្លួនជាស្រេចបានកម្រិតណាក្នុងការដោះស្រាយបញ្ហាគ្រោះមហន្តរាយធាតុអាកាស ?

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|
| | | | | | 2 | 1 | 1 | | |

**3.** តើអ្នកពេញចិត្តកម្រិតណាចំពោះព័ត៌មានដែលក្រុមប្រឹក្សាឃុំបានទទួលពីអាជ្ញាធរនៅថ្នាក់ជាតិ ?

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|
| | | | | 2 | 2 | | | | |

**4.** តើអ្នកគិតថាក្រុមប្រឹក្សាឃុំជួយគាំទ្រអ្នកភូមិបានល្អកម្រិតណាក្នុងករណីមានគ្រោះមហន្តរាយធាតុអាកាស ?

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|
| | | | 3 | 1 | | | | | |

**5.** តើការសម្របសម្រួលជាមួយវិស័យដទៃទៀតបានល្អកម្រិតណា ( ដូចជាNGOនិងវិស័យឯកជន ) ទាក់ទងនឹងបញ្ហាគ្រោះមហន្តរាយធាតុអាកាស ?

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | 4 | | |

មូលដ្ឋាន៖សមាជិកចំនួនបួនរូបក្នុងក្រុមប្រឹក្សាឃុំ

### ឃុំអូរឧកញ៉ាហេង

(1=គ្មានសោះនិង10= ខ្លាំងបំផុត), _ =ចំនួនចម្លើយ

**1.** តើអ្នកយល់ដឹងបានកម្រិតណាអំពីពាក្យការប្រែប្រួលអាកាសធាតុ

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | 1 | | 3 |

**2.** តើឃុំរបស់អ្នកត្រៀមខ្លួនជាស្រេចបានកម្រិតណាក្នុងការដោះស្រាយបញ្ហាគ្រោះមហន្តរាយធាតុអាកាស ?

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|
| 1 | 1 | 1 | | | | 1 | | | |

**3.** តើអ្នកពេញចិត្តកម្រិតណាចំពោះព័ត៌មានដែលក្រុមប្រឹក្សាឃុំបានទទួលពីអាជ្ញាធរនៅថ្នាក់ជាតិ ?

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|
| 1 | | | | 2 | | | | | 1 |

**4.** តើអ្នកគិតថាក្រុមប្រឹក្សាឃុំជួយគាំទ្រអ្នកភូមិបានល្អកម្រិតណាក្នុងករណីមានគ្រោះមហន្តរាយធាតុអាកាស ?

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|
| 1 | | 1 | | | 1 | 1 | | | |

**5.** តើការសម្របសម្រួលជាមួយវិស័យដទៃទៀតបានល្អកម្រិតណា ( ដូចជាNGOនិងវិស័យឯកជន ) ទាក់ទងនឹងបញ្ហាគ្រោះមហន្តរាយធាតុអាកាស ?

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|
| | | | | 1 | 1 | 1 | 1 | | |

មូលដ្ឋាន៖សមាជិកចំនួនបួនរូបក្នុងក្រុមប្រឹក្សាឃុំ

### ឃុំព្រៃនប់

(1=គ្មានសោះនិង10= ខ្លាំងបំផុត), _ =ចំនួនចម្លើយ

**1.** តើអ្នកយល់ដឹងបានកម្រិតណាអំពីពាក្យការប្រែប្រួលអាកាសធាតុ

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|
| | | | | | | 3 | 1 | | |

**2.** តើឃុំរបស់អ្នកត្រៀមខ្លួនជាស្រេចបានកម្រិតណាក្នុងការដោះស្រាយបញ្ហាគ្រោះមហន្តរាយធាតុអាកាស ?

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|
| | | 1 | | | | 3 | | | |

**3.** តើអ្នកពេញចិត្តកម្រិតណាចំពោះព័ត៌មានដែលក្រុមប្រឹក្សាឃុំបានទទួលពីអាជ្ញាធរនៅថ្នាក់ជាតិ ?

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|
| | | | 1 | | 2 | | | 1 | |

**4.** តើអ្នកគិតថាក្រុមប្រឹក្សាឃុំជួយគាំទ្រអ្នកភូមិបានល្អកម្រិតណាក្នុងករណីមានគ្រោះមហន្តរាយធាតុអាកាស ?

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|
| | | | 1 | | 2 | 1 | | | |

**5.** តើការសម្របសម្រួលជាមួយវិស័យដទៃទៀតបានល្អកម្រិតណា ( ដូចជាNGOនិងវិស័យឯកជន ) ទាក់ទងនឹងបញ្ហាគ្រោះមហន្តរាយធាតុអាកាស ?

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|
| 2 | | 2 | | | | | | | |

មូលដ្ឋាន៖សមាជិកចំនួនបួនរូបក្នុងក្រុមប្រឹក្សាឃុំ

ពិន្ទុដែលសមាជិកក្រុមប្រឹក្សាឃុំផ្តល់សម្រាប់ចម្លើយទាំងនោះ ទំនងជាខ្ពស់បន្តិចធៀបនឹងទិន្នន័យពីបញ្ជីសំណួរ។ ចំណុចនេះអាចពន្យល់បានថា ការដាក់ពិន្ទុបានផ្អែកលើការយល់ឃើញផ្ទាល់ខ្លួនរបស់សមាជិកក្រុមប្រឹក្សាឃុំដោយពុំមានការឆ្លុះបញ្ចាំងបន្ថែមអំពីសំណួរទាំងនេះធៀបនឹងការពិភាក្សាជាក្រុម ដែលជាការពិភាក្សាដែលមានការសម្របសម្រួល ដែលក្នុងនោះសមាជិកត្រូវធ្វើការពិភាក្សាឆ្លុះបញ្ចាំងបានម៉ត់ចត់។ ដូច្នេះការវិភាគពិន្ទុនេះ ត្រូវធ្វើឡើងដោយធៀបជាមួយការពិភាក្សាជាក្រុមដូចដែលមានបង្ហាញដោយក្រុមប្រឹក្សាឃុំ។ ដោយសារការវិភាគកម្រិតនៃការឆ្លុះបញ្ចាំងនៅក្នុងក្រុមប្រឹក្សាឃុំនៅខេត្តព្រះសីហនុ មានភាពស្របគ្នាជាងធៀបនឹងទិន្នន័យពីបញ្ជីសំណួរដែលមានកម្រិតកំណត់ជាង។ ដូច្នេះកម្រិតនៃពិន្ទុដែលបានផ្អែកលើការយល់ឃើញរបស់សមាជិកក្រុមប្រឹក្សាឃុំក្នុងខេត្តព្រះសីហនុនៅក្នុងរបាយការណ៍នេះ ត្រូវបានចាត់ទុកថាមានកម្រិតខ្ពស់ជ្រុលបន្តិច។

## ការសន្និដ្ឋានអំពីទិន្នន័យក្នុងខេត្តព្រះសីហនុ

ដូចក្នុងខេត្តកោះកុងដែរ សហគមន៍គោលដៅក្នុងខេត្តព្រះសីហនុបានជួបប្រទះការប្រែប្រួលនៃរបបធាតុអាកាស។ ការប្រែប្រួលនេះមានផលប៉ះពាល់អវិជ្ជមានទាក់ទងនឹងសេដ្ឋកិច្ចសុខភាព និងមុខរបររបស់អ្នកឆ្លើយ។ បើទោះជាផលប៉ះពាល់អវិជ្ជមានទាំងនេះបណ្តាលពីការប្រែប្រួលរបបធាតុអាកាសក៏ដោយអ្នកភូមិនៅព្រៃនប់ ពិតជាមានយុទ្ធសាស្ត្រដោះទ័លសម្រាប់ប្រើប្រាស់ដែលប្រហែលគ្នានឹងនៅឃុំពាមក្រសោប និងទួលគរគី ផងដែរ។

ធៀបនឹងកោះកុងសហគមន៍គោលដៅនៅខេត្តព្រះសីហនុ បានទទួលការគាំទ្រពីយន្តការបន្សាំរឹងមាំដែលមានប្រព័ន្ធទ្វារទឹកធំទូលាយដែលសាងសង់ដោយ ADF ។ ទោះជាយ៉ាងណាក៏ដោយប្រព័ន្ធទ្វារទឹកនេះនៅត្រូវការឲ្យមានការអភិវឌ្ឍបន្ថែមទៀតដើម្បីអាចជួយឲ្យមានដំណើរការល្អសម្រាប់ជាយន្តការបន្សាំដែលអាចដំណើរការបានល្អ។

នៅខេត្តព្រះសីហនុទិន្នន័យនេះបានឆ្លុះបញ្ចាំងពីកម្រិតទាបនៃការយល់ដឹងអំពីពាក្យប្រែប្រួលអាកាសធាតុធៀបនឹងទិន្នន័យពីកោះកុង និងធៀបជាមួយទិន្នន័យពីការសិក្សា KAP នៅកម្រិតប្រទេសផងដែរ។ កម្រិតយល់ដឹងទាបបែបនេះ ក៏មានភាពស្របគ្នាជាមួយការពិភាក្សាជាក្រុមជាមួយក្រុមប្រឹក្សាឃុំផងដែរ ដែលផ្អែកលើទិន្នន័យទាំងនេះ។ របាយការណ៍នេះសន្និដ្ឋានថា ក្រុមប្រឹក្សាឃុំទាំងនេះមានការយល់ដឹងកម្រិតទាបធៀបនឹងក្រុមប្រឹក្សាឃុំនៅពាមក្រសោប។

ដូចនៅពាមក្រសោបដែរ ការចែករម្លែកព័ត៌មាននៅមានកម្រិតទាបហើយផ្អែកលើការពិភាក្សាជាក្រុមជាមួយក្រុមប្រឹក្សាឃុំគេអាចឃើញថា កម្រិតនេះក៏ទាបជាងនៅពាមក្រសោបផងដែរ។ កម្រិតទាបបែបនេះនៃការចែករម្លែកព័ត៌មានមានការពាក់ព័ន្ធជាមួយការប្រាស្រ័យទាក់ទងផ្ទៃក្នុងនៅក្នុងឃុំ នៅក្នុងពេលមានគ្រោះមហន្តរាយ។ នៅព្រៃនប់គ្មានប្រព័ន្ធព័ត៌មានពីអាជ្ញាធរនានាដែលទាក់ទងនឹងគ្រោះមហន្តរាយធាតុអាកាសឡើយ។ ទោះជាយ៉ាងណាក៏ដោយ នៅព្រៃនប់ក្រុមប្រឹក្សាឃុំបានទទួលព័ត៌មានមិនទៀងទាត់ពីអាជ្ញាធរនានាដែលទាក់ទងនឹងគ្រោះមហន្តរាយធាតុអាកាស ដែលនេះមិនមែនជាផ្នែកមួយនៃប្រព័ន្ធចែករម្លែកព័ត៌មានឡើយ។

## ការវាយតម្លៃ

ផ្នែកចុងក្រោយនៃរបាយការណ៍នេះ គឺការវាយតម្លៃអំពីកម្រិតយុទ្ធសាស្ត្រដោះទ័លនៅក្នុងសហគមន៍គោលដៅនានា។ ការវាយតម្លៃនេះធ្វើទៅតាមលំនាំដូចគ្នានឹងប្រធានបទទាំងបីនៃការប្រមូលទិន្នន័យផងដែរ៖

- យុទ្ធសាស្ត្រដោះទ័ល
- ការយល់ឃើញ
- ព័ត៌មាន

ជាផ្នែកមួយនៃការវាយតម្លៃនេះអនុសាសន៍នានាក៏មានផ្តល់ជូនផងដែរ។

អ្នកអានរបាយការណ៍នេះគួរអានរបាយការណ៍ចំនួនពីរខាងក្រោម ស្តីពីយុទ្ធសាស្ត្រដោះទ័លក្នុងតំបន់ឆ្នេរផងដែរ។ របាយការណ៍ទាំងពីរនេះផ្តល់ការវិភាគពាក់ព័ន្ធនិងអនុសាសន៍នានា ដោយផ្អែកលើសំណួរស្រាវជ្រាវប្រហែលគ្នានឹងរបាយការណ៍នេះផងដែរ។ លើសពីនេះ របាយការណ៍ទាំងពីរបានធ្វើឡើងនៅក្នុងតំបន់តែមួយជាមួយរបាយការណ៍នេះផងដែរ។

របាយការណ៍ទាំងពីរនោះគឺ៖

- កំណត់ត្រាគោលនយោបាយដោយវេទិកាបន្សាំនឹងការប្រែប្រួលអាកាសធាតុថ្នាក់តំបន់ http://www.climateadapt.asia/resources/publication/view/62
- "របាយការណ៍បណ្តោះអាសន្នស្តីពីភាពងាយរងគ្រោះចំពោះការប្រែប្រួលអាកាសធាតុនៅក្រុងព្រះសីហនុ", 2012 ដោយ UN-HABITAT

ការវាយតម្លៃក្នុងរបាយការណ៍នេះបានផ្អែកលើទិន្នន័យដែលបានបង្ហាញជូនដូចខាងលើ ទោះជាយ៉ាងណាក៏ដោយ មានការសង្កត់ធ្ងន់លើទិន្នន័យតាមទីតាំងជាក់លាក់ដែលប្រមូលបានពីរបាយការណ៍នេះ។

ការវាយតម្លៃនេះបានធ្វើឡើងទៅតាមទស្សនវិស័យរួមមួយ អំពីកម្រិតនៃយុទ្ធសាស្ត្រដោះទ័លនៅក្នុងឃុំគោលដៅចំនួនពីរ។ ការវាយតម្លៃនេះ ពិភាក្សាអំពីកម្រិតទូទៅនៃយុទ្ធសាស្ត្រដោះទ័លនៅក្នុងសហគមន៍ គោលដៅ នៅខេត្តព្រះសីហនុ និងកោះកុង ដោយមានបង្ហាញពីឧទាហរណ៍អំពីយុទ្ធសាស្ត្រដោះទ័លផងដែរ។

### យុទ្ធសាស្ត្រដោះទ័ល

ជាទូទៅនៅក្នុងឃុំគោលដៅទាំងនេះគ្មានយុទ្ធសាស្ត្រដោះទ័ល ដែលផ្តល់កិច្ចការពារពេញលេញពីផលប៉ះពាល់អវិជ្ជមាននៃគ្រោះមហន្តរាយធាតុអាកាសដែលកើតឡើងនៅក្នុងតំបន់ឆ្នេរឡើយ។

ជាមួយការព្យាករណ៍អំពីគ្រោះមហន្តរាយធាតុអាកាសកាន់តែខ្លាំងជាងមុន ទៅអនាគតផលប៉ះពាល់អវិជ្ជមានទាំងនេះ ក៏អាចព្យាករណ៍ថាកាន់តែធ្ងន់ធ្ងរផងដែរ។ ដូច្នេះកម្រិតយុទ្ធសាស្ត្រដោះទ័លក៏ត្រូវតែបង្កើនផងដែរ ដើម្បីអាចឆ្លើយតបនឹងការប្រឈមនានាទៅអនាគត។

ដើម្បីសម្រេចបែបនេះបានប្រការសំខាន់ គឺសហគមន៍គោលដៅមិនត្រឹមតែត្រូវបង្កើតយុទ្ធសាស្ត្រដោះទ័លរបស់ខ្លួនដែលផ្អែកលើទស្សនទានរយៈពេលខ្លីឡើយ ប៉ុន្តែក៏ត្រូវតែបង្កើតយុទ្ធសាស្ត្រដែលផ្អែកលើទស្សនទានរយៈពេលវែងផងដែរ។

បញ្ហាមួយផ្សេងទៀតដែលទាក់ទងនឹងទស្សនទានរយៈពេលវែងនៃយុទ្ធសាស្ត្រដោះទ័ល គឺថាដោយសារតែទស្សនទានរយៈពេលខ្លីនេះហើយ ទើបយុទ្ធសាស្ត្រដោះទ័លខ្លះ បង្កជាសម្ពាធបន្ថែមមកលើប្រព័ន្ធអេកូឡូស៊ី ដូច្នេះធ្វើឲ្យស្ថានភាពកាន់តែអាក្រក់ទៅអនាគតរយៈពេលវែងខាងមុខ។ ឧទាហរណ៍មួយគឺនៅពេលដែលអ្នកភូមិប្តូរមុខរបរពីការដាំដំណាំទៅធ្វើនេសាទដែលជាលទ្ធផលនៃការប្រែប្រួលរបបធាតុអាកាសនេះ គឺជាការបន្ថែមសម្ពាធមកលើធនធាននេះដូចដែលបានជួបប្រទះនៅព្រៃនប់។ ដូច្នេះគួរមានការសង្កត់ធ្ងន់លើសកម្មភាពបង្កើនការយល់ដឹងដែលពាក់ព័ន្ធ ដើម្បីផ្តោតលើចំណងទាក់ទងរវាងយុទ្ធសាស្ត្រដោះទ័លនឹងការប្រែប្រួលអាកាសធាតុ និងបញ្ហាអភិវឌ្ឍន៍ដទៃទៀត។

ទោះបីពុំមានយុទ្ធសាស្ត្រដោះទ័ល ដែលអាចការពារបានពេញលេញទល់នឹងគ្រោះមហន្តរាយធាតុអាកាសក៏ដោយសហគមន៍គោលដៅទាំងពីរនៅតែមានយុទ្ធសាស្ត្រដោះទ័លសម្រាប់អនុវត្តដែរ ដែលអាចកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ។ ខាងក្រោមនេះ គឺជាយុទ្ធសាស្ត្រចំបងៗ ដែលបានវាយ តម្លៃ។

ការកំណត់អត្តសញ្ញាណកន្លែងសុវត្ថិភាពអាចជាយុទ្ធសាស្ត្រដោះទ័លដ៏មានប្រសិទ្ធភាពមួយ ទល់នឹងខ្យល់ព្យុះ និងគ្រោះមហន្តរាយធាតុអាកាសធ្ងន់ធ្ងរដទៃទៀត។ យុទ្ធសាស្ត្រនេះធានាឲ្យមានសុវត្ថិភាពចំពោះមុខសម្រាប់អ្នកភូមិ។ តាមធម្មតាយុទ្ធសាស្ត្រសមស្របបំផុតគឺអ្នកភូមិត្រូវតែមានផ្ទះរឹងមាំដែលអាចស្នាក់នៅក្នុងផ្ទះនៅក្នុងពេលមានខ្យល់ព្យុះ និងគ្រោះមហន្តរាយធាតុអាកាសដទៃទៀត។ យុទ្ធសាស្ត្រដោះទ័លដែលផ្តល់កន្លែងដែលមានសុវត្ថិភាពគួរតែបានបង្កើតឡើងទាក់ទងនឹងមជ្ឈដ្ឋានរូបវន្តនៅជុំវិញនិងប្រព័ន្ធព័ត៌មានផងដែរ ដោយត្រូវជូនដំណឹងដល់អ្នកភូមិដើម្បីត្រៀមខ្លួនជន្លៀសទៅទីសុវត្ថិភាព។

ការកសាងនិងថែទាំប្រព័ន្ធទំនប់គឺជាយុទ្ធសាស្ត្រដោះទ័លដ៏សំខាន់មួយផ្សេងទៀត សម្រាប់សហគមន៍គោលដៅ។ បើទោះជាប្រព័ន្ធទំនប់ទាំងនេះមិនអាចទប់ស្កាត់បានពេញលេញនូវទឹកជំនន់និងការជ្រាបចូលនៃទឹកប្រៃក៏ដោយ អ្នកភូមិនៅក្នុងសហគមន៍គោលដៅនៅតែអាចចាត់ទុកប្រព័ន្ធទំនប់ទាំងនេះ ជាយុទ្ធសាស្ត្រដោះទ័លសំខាន់មួយផងដែរ។ ដូចគ្នានេះដែរ យុទ្ធសាស្ត្រដោះទ័លនេះមានចំណុចដែលនៅត្រូវការឲ្យកែលម្អនៅលំដាប់ថ្នាក់ជាច្រើន។ កម្រិតបច្ចេកទេស នៃប្រព័ន្ធទំនប់នេះ ហាក់ដូចជានៅសាមញ្ញពេកនៅឡើយ។ សហគមន៍ទំនងជានៅពុំបានធ្វើការអភិវឌ្ឍន៍គុណភាពទំនប់នេះឡើយ ជាជំនួសសហគមន៍បានព្យាយាមជួសជុលនៅកម្រិតបច្ចេកទេសដដែលដូចមុនពេលមានការខូចខាតដូច្នោះដែរនៅពេលដែលទំនប់នៅតែត្រូវបំផ្លាញដោយគ្រោះមហន្តរាយធាតុអាកាស។ ដូច្នេះគេនៅត្រូវកែលម្អយុទ្ធសាស្ត្រដោះទ័លនេះនៅកម្រិតបច្ចេកទេស។ ការកែលម្អបែបនេះមានការផ្សារភ្ជាប់ជិតស្និទ្ធជាមួយធនធានហិរញ្ញវត្ថុដែលមានដូច្នេះចាំបាច់ត្រូវបង្កើតមូលនិធិដើម្បីកែលម្អប្រព័ន្ធទំនប់នេះ។លើសពីនេះសមត្ថភាពបច្ចេកទេសដើម្បីអភិវឌ្ឍន៍ប្រព័ន្ធទំនប់នេះ ក៏ត្រូវតែមាននៅកម្រិតស្ថាប័នផងដែរដើម្បីធានាថាប្រព័ន្ធទំនប់ត្រូវបានអភិវឌ្ឍន៍ដោយផ្អែកលើជំនាញសមស្រប។

បញ្ហាមួយសម្រាប់កសិករគឺផលដំណាំស្រូវរបស់ពួកគេត្រូវខូចខាតនៅពេលមានខ្យល់ព្យុះ។ កសិករខ្លះបានបង្កើតយុទ្ធសាស្ត្រដោះទ័លងាយៗបំផុតដោយប្រើដើមឫស្សីថ្នលដើមស្រូវមុនពេលខ្យល់មកដល់។ ទោះបីមានលក្ខណៈងាយបែបនេះក៏ដោយ យុទ្ធសាស្ត្រនេះទំនងជាមានប្រសិទ្ធភាពដែលជាទូទៅត្រូវបានកសិករប្រើប្រាស់នៅក្នុងសហគមន៍គោលដៅ។

ប្រសិនបើយុទ្ធសាស្ត្រដោះទ័លនេះ ត្រូវបានអភិវឌ្ឍន៍ជាបន្ថែមទៀតនិងអនុវត្តតាមវិធី ដែលមានរចនាសម្ព័ន្ធត្រឹមត្រូវយុទ្ធសាស្ត្រនេះអាចផ្តល់ជាយុទ្ធសាស្ត្រដោះទ័លដ៏មានប្រសិទ្ធភាពសម្រាប់កសិករ។

ការប្រើប្រាស់សារធាតុគីមីជាយុទ្ធសាស្ត្រដោះទ័លចំពោះសត្វចង្រៃបំផ្លាញដំណាំ ទំនងជាគ្មានប្រសិទ្ធភាពឡើយដោយសារតែការធ្លាក់ភ្លៀងជោគជាំ ឧទា. នៅទទួលគរគីដែលគណៈកម្មការឃុំបានប៉ាន់ស្មាន អំពីការប្រើប្រាស់ថ្នាំគីមីដើម្បីសង្គ្រោះផលស្រូវ៧០% ដែលរងការវាយប្រហារដោយសត្វចង្រៃ។ ប្រសិទ្ធភាពនៃយុទ្ធសាស្ត្រដោះទ័លនេះបានផ្អែកលើកត្តាចំនួនពីរ១) ចំណេះដឹងអំពីរបៀបប្រើប្រាស់ថ្នាំគីមីប្រកបដោយប្រសិទ្ធភាព២) វត្តមានថ្នាំគីមីសម្រាប់កសិករ។ កត្តាទាំងពីរនេះមានភាពជាក់លាក់ ដើម្បីធានាថាពួកគេអាចសម្រេចតាមគោលដៅទៅបាន។ ដូច្នេះ យុទ្ធសាស្ត្រដោះទ័លនេះ អាចនិងគួរតែទទួលបានការជួយជ្រោមជ្រែងដោយសមត្ថភាពខាងស្ថាប័ន ដែលកំពុងអនុវត្តបានមួយកម្រិតរួចមកហើយដូចដែលមានបង្ហាញជូនតាមរយៈទិន្នន័យពីកោះកុង។

យុទ្ធសាស្ត្រដោះទ័លទាំងនេះអាចឃើញមានក្នុងសហគមន៍គោលដៅទាំងពីរ។ ទោះជាយ៉ាងណាក៏ដោយគេឃើញមានភាពខុសគ្នាអំពីរបៀប នៃការដាក់បញ្ចូលយុទ្ធសាស្ត្រដោះទ័លទាំងនេះ និងកម្រិតដែលយុទ្ធសាស្ត្រទាំងនេះបានផ្អែកលើកិច្ចប្រឹងប្រែងរួមគ្នានៅក្នុងសហគមន៍។ សហគមន៍នៅពាមក្រសោបហាក់ដូចជាមានការចាត់ចែងបានល្អជាងនៅក្នុងសហគមន៍ដទៃទៀត។

តារាងម៉ាទ្រិកដែលបានពីការពិភាក្សាជាក្រុមជាមួយគណៈកម្មការសហគមន៍នៅកោះកុងផ្តល់ការយល់ដឹងអំពីសហគមន៍មួយដែលធ្វើការជាមួយគ្នាក្នុងការពង្រឹងកម្រិតទូទៅនៃយុទ្ធសាស្ត្រដោះទ័លសម្រាប់សហគមន៍។ លើសពីនេះ ការវិភាគបានរកឃើញថាចំណេះដឹងអំពីការប្រែប្រួលអាកាសធាតុនៅពាមក្រសោប ទំនងជាមានកម្រិតខ្ពស់ជាងធៀបនឹងនៅក្នុងឃុំគោលដៅផ្សេងទៀត។

កម្រិតចំណេះដឹងត្រូវបានចាត់ទុកថាជាកត្តាសំខាន់ជាសារវន្តនៅក្នុងការលើកកំពស់កម្រិត នៃយុទ្ធសាស្ត្រដោះទ័លរបស់សហគមន៍។

ឃុំសាមគ្គី គឺជាឃុំតែមួយគត់ដែលបានរួមបញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ និងបានបង្កើតគណៈកម្មការត្រៀមបង្ការគ្រោះមហន្តរាយ និងសង្គ្រោះ។ វិធានការដែលឃុំសាមគ្គីបានអនុវត្តមានលក្ខណៈវិជ្ជមានក្នុងនាមជាឃុំដែលមានការចាត់ចែងបានល្អខាងយុទ្ធសាស្ត្រដោះទ័ល។ ទោះជាយ៉ាងណាក៏ដោយ ក្រៅពីស្វែងរកកន្លែងសុវត្ថិភាពដែលបានអនុវត្តផងដែរនៅក្នុងឃុំដទៃទៀត គណៈកម្មការនេះទំនងជាបានទទួលលទ្ធផលក្នុងកម្រិតកំណត់នៅឡើយ។ ទោះជាយ៉ាងណាក៏ដោយ គួរមានការវិភាគបន្ថែមទៀតអំពីជំហានចាត់ចែងបែបនេះ និងរបៀបដែលធ្វើឲ្យវិធីនេះមានប្រសិទ្ធភាពដូចមានពិភាក្សាខាងក្រោម។

ផ្អែកលើប្រព័ន្ធទ្វារទឹកដែលបានជួសជុលឡើងវិញ ព្រៃនប់បានទទួលការឧបត្ថម្ភតាមរយៈសមត្ថភាពបន្សាំរឹងមាំធៀបនឹងមណ្ឌលសីមា។ តាមពិតគេត្រូវដឹងផងដែរថាប្រព័ន្ធទ្វារទឹកមិនអាចទប់ស្កាត់បានទាំងស្រុងចរន្តទឹកហូរលើខ្នងទំនប់បានឡើយ។ ទោះជាយ៉ាងណាក៏ដោយ វានៅតែជាសមត្ថភាពបន្សាំដែលគាំទ្រដល់អ្នកភូមិនៅព្រៃនប់ទោះបីប្រព័ន្ធទ្វារទឹកត្រូវការឲ្យមានការអភិវឌ្ឍជាបន្ថែម ដើម្បីអាចបំពេញមុខនាទីជាសមត្ថភាពបន្សាំសម្រាប់ផលប៉ះពាល់ទៅអនាគតបណ្តាលពីការប្រែប្រួលអាកាសធាតុ។ ជាការគួរឲ្យចាប់អារម្មណ៍ដែលអ្នកឆ្លើយជាច្រើននៅព្រៃនប់យោងទៅប្រព័ន្ធទ្វារទឹកថាជាយុទ្ធសាស្ត្រដោះទ័ល ទោះបីវាគួរតែត្រូវបានចាត់ទុក

ជាយន្តការបន្សាំ។ ទោះជាការឲ្យនិយមន័យប្រព័ន្ធទ្វារទឹកថាជាយុទ្ធសាស្ត្រដោះទ័លឬយន្តការបន្សាំផ្ទាល់មិនផ្តល់ជាចំណាប់អារម្មណ៍ក៏ដោយប្រការសំខាន់គឺត្រូវជានាថាកិច្ចការនេះត្រូវបានធ្វើសម្រាប់ជាយន្តការគាំទ្រដល់យុទ្ធសាស្ត្រដោះទ័លដែលមានស្រាប់ ឬជាកត្តាជម្រុញសម្រាប់បង្កើតយុទ្ធសាស្ត្រដោះទ័លថ្មីៗ ផងដែរ។ ហានិភ័យគឺការបង្កើតយន្តការបន្សាំដែលធ្វើឲ្យសហគមន៍គោលដៅគិតថាវាជួយដោះស្រាយរាល់ បញ្ហាដែលទាក់ទងនឹងគ្រោះមហន្តរាយធាតុអាកាស។ ប្រការនេះអាចនាំឲ្យសហគមន៍គោលដៅមិនសូវសកម្មទាក់ទងនឹងការអភិវឌ្ឍយុទ្ធសាស្ត្រដោះទ័លរបស់ខ្លួនជាបន្ថែមទៀត។ នេះមិនមែនជាករណីនៅព្រៃនប់ឡើយហើយការសន្និដ្ឋានបែបនេះមិនត្រឹមត្រូវឡើយ បើផ្អែកតាមទិន្នន័យដែលប្រមូលបានសម្រាប់របាយការណ៍នេះ។ ទោះជាយ៉ាងណាក៏ដោយ វាជាសញ្ញាណមួយដែលត្រូវផ្តល់ជាការសន្និដ្ឋានផងដែរ។ សញ្ញាណមួយផ្សេងទៀតដែលត្រូវកត់សំគាល់ផងដែរនោះ ទាក់ទងនឹងការបង្កើតយន្តការបន្សាំ គឺថានៅពេលបង្កើតយន្តការបន្សាំប្រការសំខាន់គឺត្រូវជានាថាយន្តការ ទាំងនេះមិនដាក់សម្ពាធមកលើធនធានរបស់អ្នកភូមិដែលត្រូវបានប្រើប្រាស់សម្រាប់ជាយុទ្ធសាស្ត្រដោះទ័លរបស់ពួកគេផ្ទាល់ដោយសារតែតម្រូវការឲ្យអ្នកភូមិថែទាំយន្តការបន្សាំនោះឡើយ។

បញ្ហាមួយផ្សេងទៀត គឺថាសហគមន៍ពុំមានសមត្ថភាពស្ថាប័នដើម្បីគាំទ្រដល់ពួកគេដើម្បីរួមបញ្ចូលនិងបង្កើតយុទ្ធសាស្ត្រដោះទ័លរបស់ពួកគេឡើយ។ សមត្ថភាពភាគច្រើនដែលមានភាគតែលើការបង្កើតហេដ្ឋារចនាសម្ព័ន្ធដូចជាប្រព័ន្ធទ្វារទឹកនៅព្រៃនប់។ ទោះជាយ៉ាងណាក៏ដោយគេចាំបាច់ត្រូវបង្កើតសមត្ថភាពបច្ចេកទេសបន្ថែមទៀតដូចជាអ្នកជំនាញនៅថ្នាក់ខេត្ត ដែលអាចផ្តល់ការគាំទ្រដល់សហគមន៍នៅក្នុងករណីដែលជួបប្រទះផលប៉ះពាល់ស្មុគស្មាញ នៃគ្រោះមហន្តរាយធាតុអាកាស ដូចជាសត្វចង្រៃបំផ្លាញដំណាំការ កែប្រែមុខដំណាំជម្ងឺក្នុងចំណោមអ្នកភូមិនិងសត្វចិញ្ចឹម។ ឧទា. នៅឃុំទួលគរគីឃុំបានប្រើប្រាស់មន្ត្រីកសិកម្មខេត្ត ដើម្បីផ្តល់ផលវិជ្ជមាននៅក្នុងកិច្ចប្រឹងប្រែងរបស់ឃុំក្នុងការកំចាត់សត្វចង្រៃបំផ្លាញដំណាំ។

កម្រិតនៃការចាត់ចែងដូចដែលបានកត់សំគាល់ពីខាងដើមនៅកម្រិតក្រុមប្រឹក្សាឃុំ និងគណៈកម្មការសហគមន៍ត្រូវអ្នកនិពន្ធរបាយការណ៍នេះចាត់ទុកថាជាកត្តាសំខាន់ ជាសារវន្តនៅក្នុងការបង្កើនកម្រិតនៃយុទ្ធសាស្ត្រដោះទ័លដែលមានស្រាប់ក្នុងតំបន់ឆ្នេរ។ ឧទាហរណ៍មួយ គឺការសាងសង់ និងការថែទាំប្រព័ន្ធទំនប់នៅក្នុងសហគមន៍គោលដៅ។ ប្រការសំខាន់ គឺត្រូវមានការកំណត់ច្បាស់លាស់ ថាតើអ្នកណាទទួលខុសត្រូវលើការការសាងសង់និងការថែទាំប្រព័ន្ធទំនប់ខុសៗគ្នា និងប្រព័ន្ធទ្វារទឹក។ នៅពេលធ្វើបែបនេះរួចហើយជំហានបន្ទាប់គឺត្រូវជានាឲ្យមានចំណេះដឹង និងធនធានសម្រាប់អ្នកពាក់ព័ន្ធនានា។ បច្ចុប្បនេះ ការទទួលខុសត្រូវថែទាំប្រព័ន្ធទំនប់គឺជាបន្ទុករបស់គណៈកម្មការសហគមន៍ ប៉ុន្តែទិន្នន័យសម្រាប់របាយការណ៍នេះ បង្ហាញថាគណៈកម្មការសហគមន៍ពុំមានសមត្ថភាព ដើម្បីជួសជុលប្រព័ន្ធនេះតាមវិធី ដែលធានាការពារពីការជន់លិចជាបន្តបន្ទាប់នោះឡើយ។ ដូច្នេះ ចំណោទគឺ ថាតើគណៈកម្មការសហគមន៍ដោយផ្អែកលើកម្រិតបច្ចុប្បន្ននៃសមត្ថភាពមាន កម្រិតសមត្ថភាពចាត់ចែងបានសមស្រប ដើម្បីទទួលខុសត្រូវលើការថែទាំប្រព័ន្ធទំនប់នេះដែរឬទេ។

ដូច្នេះ CARP គួរផ្តោតការយកចិត្តទុកដាក់លើសមត្ថភាពនៅកម្រិតចាត់ចែងស្ថាប័នក្នុងចំណោមអ្នកពាក់ព័ន្ធទាំងពីរក្រុមនេះ។ ជំហានចំនួនបីដូចខាងក្រោមនេះត្រូវបានស្នើឡើងសម្រាប់ CARP ដើម្បីប្រើប្រាស់ជាវិធីសម្រាប់បង្កើនកម្រិតនៃការចាត់ចែងនៅកម្រិតឃុំនិងសហគមន៍។

១. ជំហានដំបូង គឺត្រូវកំណត់ថាតើអ្នកពាក់ព័ន្ធទាំងពីរក្រុមនេះមានតួនាទីអ្វីខ្លះក្នុងការការពារតំបន់ឆ្នេរទល់នឹងការប្រែប្រួលអាកាសធាតុ

២. ជំហានទីពីរ គួរពិនិត្យមើលថាតើអ្នកពាក់ព័ន្ធទាំងពីរក្រុមនេះគួរចាត់ចែងផ្ទៃក្នុងបែបណានិងមានការទាក់ទងបែបណាជាមួយអ្នកពាក់ព័ន្ធផ្សេងទៀត ដូចជាគួរមានការតែងតាំងអ្នកជំនាញប្រែប្រួលអាកាសធាតុម្នាក់នៅក្នុងចំណោមក្រុមអ្នកពាក់ព័ន្ធទាំងនេះដែរឬទេ។

៣. ទីបីនិងជំហានចុងក្រោយដែលត្រូវផ្អែកលើជំហាន១ និង ២ គឺតើគួរចាត់ចែងនិងអនុវត្តដំណើរការកសាងសមត្ថភាពដែរឬទេ។

**ព័ត៌មាន**

បញ្ហាគន្លឹះនៅក្នុងសហគមន៍គោលដៅទាំងពីរ គឺអវត្តមានប្រព័ន្ធសម្រាប់ការចែករំលែកព័ត៌មានដែលពាក់ព័ន្ធរវាងអ្នកពាក់ព័ន្ធនានាឡើយ។ ដូចដែលបានបង្ហាញនៅក្នុងរបាយការណ៍នេះ យុទ្ធសាស្ត្រដោះទ័លណាមួយត្រូវតែផ្អែកលើប្រវត្តិនៃព័ត៌មានទាំងនៅមុនក្នុងអំឡុងពេល និងក្រោយពេលគ្រោះមហន្តរាយធាតុអាកាសបានកើតឡើង។

ទិន្នន័យពីបញ្ជីសំណួរផ្តល់សេចក្តីពន្យល់ច្បាស់អំពីប្រភពដែលអ្នកឆ្លើយបានទទួលព័ត៌មានរបស់ខ្លួនទាក់ទងនឹងគ្រោះមហន្តរាយធាតុអាកាស។ មកទល់ពេលនេះ វិទ្យុ និងទូរទស្សន៍ គឺជាប្រភពព័ត៌មានចំបងពីរ។ លើសពីនេះអ្នកឆ្លើយបានទទួលព័ត៌មានពីអ្នកជិតខាងនិងអាជ្ញាធរមូលដ្ឋានប៉ុន្តែប្រភពនេះមានកម្រិតកំណត់។ មានតែអ្នកឆ្លើយតិចតួចប៉ុណ្ណោះ ដែលបានទទួលព័ត៌មានអំពីគ្រោះមហន្តរាយធាតុអាកាសពីអាជ្ញាធរនៅថ្នាក់ជាតិ។

លើសពីនេះ អ្នកឆ្លើយបានឲ្យយោបល់ថាទៅអនាគតពួកគេចង់ទទួលព័ត៌មានបន្ថែមពីអាជ្ញាធរមូលដ្ឋាន។

ចំពោះក្រុមប្រឹក្សាឃុំប្រភពព័ត៌មានដូចគ្នានឹងសម្រាប់អ្នកភូមិដែរ។ គ្មានក្រុមប្រឹក្សាឃុំណាមួយមានប្រព័ន្ធសម្របសម្រួលព័ត៌មានជាមួយអាជ្ញាធរនៅថ្នាក់ជាតិឬថ្នាក់ខេត្តឡើយ។ ទោះជាយ៉ាងណាក៏ដោយ ក្រុមប្រឹក្សាឃុំចំនួនពីរនៅឃុំទឹកថ្លា និងឃុំទឹកល្អក់កាលពីមុនធ្លាប់បានទទួលព័ត៌មានពីក្រសួងធនធានទឹក និងឧតុនិយម (MoWRAM) និងពីអាជ្ញាធរខេត្ត មុនគ្រោះមហន្តរាយធាតុអាកាសកើតឡើង។ លើសពីនេះ នៅឃុំទឹកថ្លា គណៈកម្មការសហគមន៍បានជូនដំណឹងទៅអាជ្ញាធរស្រុកអំពីផលប៉ះពាល់នៃខ្យល់ព្យុះ។ ទោះជាយ៉ាងណាក៏ដោយ ទិន្នន័យសម្រាប់របាយការណ៍មិនបង្ហាញច្បាស់លាស់ឡើយថា តើអាជ្ញាធរនានាប្រើប្រាស់ព័ត៌មាននេះបែបណា លើកលែងតែថាគ្មានប្រព័ន្ធសម្រាប់សម្របសម្រួលព័ត៌មានឡើយ។ ប្រសិនបើក្រុមប្រឹក្សាឃុំទទួលព័ត៌មាន ដែលទាក់ទងនឹងគ្រោះមហន្តរាយធាតុអាកាសពួកគេព្យាយាមជូនដំណឹងដល់អ្នកភូមិ ប៉ុន្តែដូចគ្នានេះដែរ ពុំមានប្រព័ន្ធដែលបង្កើតឡើងសម្រាប់ចែកចាយព័ត៌មានដែលទទួលបានទាំងនេះឡើយ។

ចំណុចនេះនាំទៅរកការពិភាក្សាមួយផ្សេងទៀត ពោលគឺតើត្រូវការព័ត៌មានបែបណានិងព័ត៌មានច្រើនប៉ុណ្ណាសម្រាប់ផ្តល់ជា"ព័ត៌មានគោល" ដែលទាក់ទងនឹងជំពូកទាំងបី (នៅមុនក្នុងពេលនិងក្រោយពេល)?

ការប្រមូលទិន្នន័យសម្រាប់របាយការណ៍នេះ មិនបានផ្តល់ចម្លើយពេញលេញតបនឹងសំណួរនេះឡើយ។ ទោះជាយ៉ាងណាក៏ដោយគេអាចកំណត់សញ្ញាណខ្លះៗ។

ជាទូទៅ ប្រព័ន្ធព័ត៌មានមួយគួរតែធានាថា មិនគ្រាន់តែបញ្ជូនឬទទួលព័ត៌មានដែលពាក់ព័ន្ធជាបន្តទៅឬមកពីអ្នកភូមិប៉ុណ្ណោះទេ។ នៅពីក្រោយសកម្មភាពនេះគឺការវាយតម្លៃអំពីប្រភេទព័ត៌មានដែលទាក់ទងនឹងជំពូកទាំងបីទៅតាមពេលវេលាដែលប្រព័ន្ធមួយគួរតែសម្របសម្រួលឲ្យបាន។

*នៅមុន*មានគ្រោះមហន្តរាយធាតុអាកាសប្រព័ន្ធព័ត៌មានមួយគួរតែជានាថា ព័ត៌មាន/ការព្យាករណ៍ណាមួយ ដែលមានទាក់ទងនឹងគ្រោះមហន្តរាយធាតុអាកាសត្រូវបានចែករម្លែកជាមួយសហគមន៍ ដែលនឹងអាចរងឥទ្ធិពលពីគ្រោះមហន្តរាយនោះ។ ជាផ្នែកមួយនៃការងារកំពុងអនុវត្តក្នុងការបង្កើតឲ្យមានការព្យាករណ៍ធាតុអាកាសប្រកបដោយគុណភាពខ្ពស់ និងការនិទស្សន៍អំពីគ្រោះមហន្តរាយធាតុអាកាសប្រព័ន្ធព័ត៌មានចំនួនពីរគឺវិទ្យុ និងទូរទស្សន៍គួរតែមានតួនាទីគន្លឹះក្នុងការជូនដំណឹងដល់សហគមន៍គោលដៅ នៅមុនគ្រោះមហន្តរាយធាតុអាកាសកើតឡើង។ ក្នុងករណីមានគ្រោះមហន្តរាយធាតុអាកាសមិនប្រក្រតីព័ត៌មានបែបនេះគួរតែបានផ្តល់ដោយផ្ទាល់ពីអាជ្ញាធរពាក់ព័ន្ធ។ ចំណុចនេះអាចធ្វើបានតាមវិធីមួយចំនួន។ វិធីមួយគឺអាជ្ញាធរត្រូវមានអ្នកសម្រាប់ទទួលព័ត៌មាននៅក្នុងក្រុមប្រឹក្សាឃុំដែលអាចទាក់ទងបានតាមទូរស័ព្ទ និងជូនដំណឹងអំពីគ្រោះមហន្តរាយធាតុអាកាសដែលបានព្យាករណ៍។ អ្នកទទួលព័ត៌មាននេះត្រូវមានភារៈទទួលខុសត្រូវចែករម្លែកព័ត៌មាននេះទៅគណៈកម្មការសហគមន៍ដែលបន្ទាប់មកត្រូវផ្តួចផ្តើមឲ្យមានសកម្មភាពពាក់ព័ន្ធ។

*នៅក្នុងអំឡុងពេល*នៃគ្រោះមហន្តរាយធាតុអាកាសប្រការសំខាន់ គឺថានៅក្នុងសហគមន៍ណាមួយត្រូវមានប្រព័ន្ធមួយសម្រាប់អនុវត្តដែលជានាថា អ្នកភូមិបានទទួលព័ត៌មានដូចជាក្នុងករណីត្រូវជន្លៀសទៅកាន់ទីសុវត្ថិភាព។

*នៅក្រោយពេលដែល*គ្រោះមហន្តរាយធាតុអាកាសកើតឡើងប្រការសំខាន់ គឺត្រូវបញ្ជូនព័ត៌មានដែលពាក់ព័ន្ធពីអ្នកភូមិទៅអាជ្ញាធរនានា។ ព័ត៌មានបែបនេះទំនងបំផុតថានឹងទាក់ទងជាមួយផលប៉ះពាល់នៃគ្រោះមហន្តរាយធាតុអាកាស។ ព័ត៌មាននេះអាចឲ្យអាជ្ញាធរយកទៅប្រើប្រាស់ដើម្បីធ្វើការប៉ាន់ប្រមាណអំពីទំហំនៃការខូចខាតនិងការបាត់បង់ខាងសេដ្ឋកិច្ចដោយសារតែគ្រោះមហន្តរាយធាតុអាកាស។ លើសពីនេះទិន្នន័យនេះអាចគាំទ្រដល់ការបង្កើតកម្រងទិន្នន័យអំពីបញ្ហានេះ។ កម្រងទិន្នន័យបែបនេះអាចមាននាទីជាទិន្នន័យគោលសម្រាប់សូចនាករមួយចំនួនដែលទាក់ទងនឹងគ្រោះមហន្តរាយធាតុអាកាសដូចជាកម្រិតញឹកញាប់ផលប៉ះពាល់ និងកម្រិតជោគជ័យតាមរយៈសមត្ថភាពបន្សាំនិងយុទ្ធសាស្ត្រដោះទ័លខ្លះៗ។ ទិន្នន័យទាំងនេះអាចមាននាទីជាធាតុចូលយ៉ាងសំខាន់សម្រាប់ការស្រាវជ្រាវទៅអនាគត។

តាមយោបល់របស់អ្នកនិពន្ធរបាយការណ៍នេះ ការបង្កើតប្រព័ន្ធព័ត៌មានផ្តល់ប្រយោជន៍សំខាន់ណាស់ក្នុងការជានាឲ្យមានការកែលម្អយុទ្ធសាស្ត្រដោះទ័លដែលមានស្រាប់ និងការបង្កើតយុទ្ធសាស្ត្រដោះទ័លថ្មីៗ។ ដូច្នេះការវិភាគគួរតែបានធ្វើឡើងដោយផ្អែកលើដំណើរការតាមបែបផែននៃការចូលរួមនៃអ្នកពាក់ព័ន្ធនានាដើម្បីវិភាគអំពីវិធីល្អបំផុតសម្រាប់បង្កើតនិងរួមបញ្ចូលប្រព័ន្ធព័ត៌មាន។

ប្រការសំខាន់មួយដែរគឺប្រព័ន្ធព័ត៌មានបែបនេះ គួរតែបានបង្កើតឡើងនិងរួមបញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ។

## ការយល់ឃើញ

ដូចមានចែងនៅក្នុងវិធីសាស្ត្រ ការយល់ឃើញរបស់អ្នកឆ្លើយអាចមិនស្របគ្នាជាមួយនិយមន័យតាមទ្រឹស្តីអំពីការប្រែប្រួលអាកាសធាតុ។ ចំណុចនេះទំនងជាបង្ហាញជាក់ស្តែងនៅក្នុងទិន្នន័យ ដែលប្រមូលបាន។ យើងឃើញមាននិន្នាការច្បាស់លាស់នៅក្នុងទិន្នន័យដែលប្រមូលបាន ដែលអ្នកឆ្លើយចាត់ទុកការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់របស់វាទាក់ទងនឹងបរិស្ថានក្នុងមូលដ្ឋាននិងមិនមានការយល់ដឹងអំពីការប្រែប្រួលអាកាស

ជាតុនៅក្នុងបរិបទសកលឡើយ។ ទាក់ទងនឹងការវាយតម្លៃយុទ្ធសាស្ត្រដោះទ័ល ដែលមានស្រាប់នៅក្នុងសហគមន៍គោលដៅការយល់ឃើញនេះ អំពីការប្រែប្រួលអាកាសធាតុ ថាជាបាតុភូតនៅក្នុងមូលដ្ឋានមិនត្រូវបានចាត់ទុកថាមានឥទ្ធិពលមកលើយុទ្ធសាស្ត្រដោះទ័លដែលមានស្រាប់ឡើយ ដែលអាចកើតឡើងបានដោយសារនៅក្នុងពេលអនុវត្តយុទ្ធសាស្ត្រដោះទ័លខ្លះ អាចត្រូវគេយល់ថាពាក់ព័ន្ធនឹងវិស័យច្រើនដូចជាការគ្រប់គ្រងធនធានទឹក។

ទោះជាយ៉ាងណាក៏ដោយ មានហានិភ័យខ្លះៗ ដែលទាក់ទងនឹងសហគមន៍ដែលផ្អែកលើការយល់ឃើញរបស់ខ្លួនអំពីការប្រែប្រួលអាកាសធាតុថាជាព្រឹត្តិការណ៍នៅមូលដ្ឋាន។ ហានិភ័យមួយក្នុងចំណោមហានិភ័យទាំងនេះ គឺថាការប្រែប្រួលអាកាសធាតុក្លាយជាប្រភព នៃគ្រប់បញ្ហាទាំងអស់ នៃបរិស្ថាននៅក្នុងមូលដ្ឋាន។ ប្រសិនបើនិន្នាការនៃការយល់ឃើញបែបនេះ កើតមានជាទូទៅដែលមិនទំនងជាមិនអាចកើតមាននោះ វានឹងអាចបង្កើតឲ្យមានការលំបាកមិនត្រឹមតែសម្រាប់គម្រោងប្រែប្រួលអាកាសធាតុប៉ុណ្ណោះទេ ប៉ុន្តែក៏សម្រាប់គម្រោងអភិវឌ្ឍន៍ដទៃទៀតផងដែរ ដែលអនុវត្តនៅក្នុងសហគមន៍គោលដៅទាំងនេះ។ ការលំបាកនេះត្រូវតែជំនះឲ្យបានដោយធានាថាអ្នកទទួលផលផ្តោតបានច្បាស់លាស់លើគោលដៅនៃគម្រោងអភិវឌ្ឍន៍ ដែលត្រូវអនុវត្ត និងមិនត្រូវចាត់ទុកគម្រោងអភិវឌ្ឍន៍ នៅក្នុងបរិបទផ្សេងពីអ្វីដែលជាគោលដៅដែលគ្រោងទុកនោះឡើយ។ ឧទាហរណ៍ មួយគឺបញ្ហានៃការបូមខ្សាច់ដែលយោងតាមអ្នកឆ្លើយជាច្រើននៅកោះកុងគឺជាមូលហេតុដែលនាំឲ្យមានផលប៉ះពាល់ នៃការប្រែប្រួលអាកាសធាតុ។ គេមិនគួរយល់ថាការបូមខ្សាច់គឺជាមូលហេតុនៃការប្រែប្រួលអាកាសធាតុឡើយ។ ប៉ុន្តែដោយសារតែមានការយល់ឃើញបែបនេះនៅកោះកុងវាបង្កើតជាបញ្ហាមួយសម្រាប់ CARP នៅក្នុងការអនុវត្តរបស់ខ្លួនដោយសារតែអ្នកឆ្លើយមានការយល់ឃើញខុសគ្នាអំពីមូលហេតុ នៃការប្រែប្រួលអាកាសធាតុ ធៀបនឹងការយល់ឃើញរបស់ CARP ដូច្នេះភាពខុសគ្នានេះអាចនាំឲ្យមានការយល់ខុសគ្នានៅក្នុងការប្រាស្រ័យទាក់ទងពោលគឺរវាង CARP និងសហគមន៍គោលដៅនៅកោះកុង ដែលនិយាយភាសាដូចគ្នាតែមានន័យខុសគ្នា។

ដូច្នេះប្រការសំខាន់គឺ CARP ត្រូវធានាឲ្យមានការប្រាស្រ័យទាក់ទងគ្នាបានល្អនិងការបង្កើនការយល់ដឹងដល់សហគមន៍គោលដៅអំពីគោលបំណងនានារបស់ CARP ។ ការធ្វើបែបនេះអាចរាប់បញ្ចូលការជៀសវាងនូវការប្រាស្រ័យទាក់ទងរវាងអ្នកពាក់ព័ន្ធ ដែលផ្អែកលើបញ្ហានៃការយល់ឃើញដូចដែលបានកត់សំគាល់ពីខាងដើម។ ការប្រាស្រ័យទាក់ទងមិនត្រឹមត្រូវបែបនេះអាចមានផលប៉ះពាល់មកលើលទ្ធផលនៃ CARP។ ការយល់ដឹងបែបនេះទាមទារឲ្យមានកម្រិតសមស្របនៃភាពស្មុគស្មាញ។ ការបង្ហាញពីគោលបំណងទាំងអស់នៃ CARP ពិស្តារ និងតាមវិធីដែលលំបាកយល់សម្រាប់សហគមន៍គោលដៅអាចនឹងធ្វើឲ្យមានការយល់ខុសកាន់តែខ្លាំងថែមទៀត។ ដូច្នេះប្រការសំខាន់គឺអ្នកពាក់ព័ន្ធខាងបច្ចេកទេសជាមួយ CARP ធ្វើការវិភាគបញ្ហានេះនិងបង្កើតជាផែនការប្រាស្រ័យទាក់ទងមួយដើម្បីជំនះបញ្ហានេះ។

CARP គួរបញ្ចូលគោលបំណងមួយនៃការបង្កើនកម្រិតទូទៅនៃការយល់ដឹងដែលទាក់ទងនឹងយុទ្ធសាស្ត្រដោះទ័លដែលមានស្រាប់នៅក្នុងសហគមន៍គោលដៅ។ ដើម្បីធ្វើបែបនេះបានគួររៀបចំសម្ភារៈសម្រាប់បង្កើនការយល់ដឹងដោយផ្អែកលើទម្រង់ពីរបែប (១)បញ្ជីយុទ្ធសាស្ត្រដោះទ័លដែលមានបង្ហាញពីយុទ្ធសាស្ត្រដោះទ័លដែលបានបង្កើតនៅក្នុងសហគមន៍គោលដៅ (២) បង្កើតផ្ទាំងព័ត៌មាន(Poster) ដែលបង្ហាញពីយុទ្ធសាស្ត្រដោះទ័ល។ សម្ភារៈនេះគួរតែចែកចេញជាជំពូកខុសៗគ្នាទៅតាមពេលវេលាពោលគឺនៅមុនក្នុងអំឡុងពេល និងក្រោយពេលនៃគ្រោះមហន្តរាយ។

# ឯកសារយោង

*Adaptation knowledge Platform*, "Climate Change Adaptation: Finding the appropriate responses", 2010.

*Adaptation Knowledge Platform*, "Climate Change Adaptation: Factors of Choice, Effectiviness and Supporting Systems, 2011

*Adaptation Knowledge Platform,* "Climate Change Resilience in Coastal Cambodia: Adaptive Capacity & Human Development", 2011

*Cambodian Climate Change Alliance*, "Coastal Adaptation and Resilience Planning Component, 2010.

*Cambodian National Mekong Committee*, "The state of Climate Change Management in Cambodia", 2012

*Intergovernmental Panel on Climate Change*, "The Fourth Assessment Report of the Intergovernmental Panel on Climate Change", 2007.

*Oxfam America*, "Understanding Public Perception of Climate Change in Cambodia, 2012.

*Royal Cambodian Government*, "National Adaptation Programme of Actions taken to Climate Change", 2006

*UN-Habitat*, "Interim Report on Vulnerability to Climate Change in Sihanoukville

Municipality", 2012

*UNISDR*, "UNISDR Termenology on Disaster Risk Reduction", 2009

**Web-pages**

http://www.businessinsider.com/climate-change-vulnerability-2011-10, 2/2-2012

http://sdwebx.worldbank.org/climateportalb/home.cfm?page=country_profile, 25/2-2012,

http://www.thegef.org/gef/sites/thegef.org/files/documents/document/2-7-11%20-%20Webposting.pdf, 17/2-2012

http://www.sida.se/Global/Countries%20and%20regions/Asia%20incl.%20Middle%20East/Cambodia/Environmental%20Policy%20Brief%20Cambodia.pdf, 2/2-2012

http://www.wepa-db.net/policies/state/cambodia/seaarea.htm, 3/2-2012,